ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 25-Jul-2012, 09:40
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១២**

**ម៉ោង ០៩:០២ នាទី**

**សវនាការលើកទី៨២**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធួ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ដាវ អានសាន

លោក អេនឌ្រូ ចេមស៍ ម៉ាគីនថាយអ័រ
*(Andrew James MCINTYRE)*

លោក ស៊ីម៉ុន មេសិនប៊ឺង
*(Mr. Simon MEISENBERG)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ត់

កញ្ញា សុង ឆរ័ន្តិ

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

លោក សាលីម ណាកចាវ៉ានី
*(Mr. Salim NAKHJAVANI )*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ(*Mr Jasper PAUW)*

លោក អេនឌ្រូ អ៊ីនូហ្ស៊ី
*(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន
*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស
*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ទី ស្រ៊ីនណា

លោក វ៉ែន ពៅ

លោក ឡោ ជុនធី

លោក សំ សុគង់

លោកស្រី ជេត វណ្ណលី

លោក ហុង គឹមសួន

លោក អូលីវីយេ បាហ៊្វូញ
*(Mr. Olivior BAHOUGNE)*

លោក គ្រីស្ទីន ម៉ាទីណូ
*(Mr. Chritine MARTINAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ថារីក អាប់ឌុលឡាក់ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក ហ្សាស្ដើ ប៉ៅ | អង់គ្លេស |
| លោក អេនឌ្រូ អ៊ីនូហ្ស៊ី | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក អូលីវីយេ៉ បាហ៊ូញ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក នួន ជា | ខ្មែរ |
| លោក ដេវីដ ឆេនដ័ល័រ (TCE-11) | អង់គ្លេស |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅអ្នកជំនាញ៖ លោក ដេវីដ ឆេនដ័ល័រ** (TCE-11)

សួរដោយលោក សុន អរុណ ផ្ដើមពី ........................................................ទំព័រ ២

សួរដោយលោក ហ្សាស្ដើ ប៉ៅ ផ្ដើមពី ........................................................ទំព័រ ១៥

សួរដោយលោក អេនឌ្រូ អ៊ីនូហ្វ៊ី ផ្ដើមពី ........................................................ទំព័រ ៦៨

សួរដោយលោក ម៉ៃខល កាណាវាស ផ្ដើមពី ........................................................ទំព័រ ៧៥

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:៣០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះ កិច្ចដំណើរការនីតិវិធីសវនាការបន្តស្តាប់សក្ខីកម្មអ្នកជំនាញ ដេវីដ ឆេនដ៍ល័រ ដែលនឹងចាប់ផ្តើមសួរសំណួរដេញដោលដោយក្រុមមេធាវីការពារក្តីលោក នួន ជា មុនមេធាវីការពារក្តីពីរក្រុមទៀត។ ហើយមុននឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា អង្គជំនុំជម្រះសូមអញ្ជើញលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលត្រូវកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

[០៩:០៣:៣៤]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន គ្រប់ភាគីទាំងអស់នៅក្នុងរឿងក្តីនេះមានវត្តមាន។ លើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការ ដោយជនជាប់ចោទបានស្នើសុំលះបង់សិទ្ធិតាមរយៈមេធាវីរបស់គាត់ក្នុងការចូលរួមដំណើរការនីតិវិធីសវនាការ ដោយផ្ទាល់ ពីបន្ទប់សវនាការសម្រាប់រយៈពេញមួយថ្ងៃនៃថ្ងៃសវនាការនេះ។ លិខិតលះបង់សិទ្ធិរបស់ ជនជាប់ចោទបានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្តីរបស់គាត់ សុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់ដំណើរការសវនាការដេញដោលពេញមួយថ្ងៃនេះ ដោយមូលហេតុបញ្ហាសុខភាព មិនអាចអង្គុយតាមដានកិច្ចដំណើរការសវនាការដោយផ្ទាល់បាន។ លោកវេជ្ជបណ្ឌិត លឹម ស៊ីវុត្ថា ដែលទទួលបន្ទុកពិនិត្យថែទាំសុខភាពជនជាប់ចោទនៅមន្ទីរឃុំឃាំង អ.វ.ត.ក បានផ្តល់អនុសាសន៍ថា

ជនជាប់ចោទ អៀង សារី នៅព្រឹកនេះមានអាការៈវិលមុខ អស់កម្លាំង នឿយហត់ខ្លាំង គួរតែត្រូវបានអនុញ្ញាតឲ្យគាត់នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់មួយស្ថិតនៅក្រោមសាលសវនាការនេះ។

[០៩:០៥:០០]

អង្គជំនុំជម្រះយល់ឃើញថា នាពេលនេះជនជាប់ចោទ អៀង សារី ដែលមានបញ្ហាសុខភាព ហើយគាត់បានលះបង់សិទ្ធិចូលរួមកិច្ចដំណើរការសវនាការដោយផ្ទាល់ តែគាត់អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសាលសវនាការនេះ។ ហើយតាមរយៈឧបករណ៍សោតទស្សន៍នឹងអាចសម្រួលដល់ទំនាក់ទំនងរវាងគាត់ ជាមួយនឹងក្រុមមេធាវីការពាររបស់គាត់បាន។

ហេតុដូច្នេះ អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះ ឲ្យលោក អៀង សារី នៅតាមដានកិច្ចដំណើរការសវនាការ ពីចម្ងាយពីបន្ទប់ឃុំមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលដំណើរការសវនាការពេញមួយថ្ងៃនេះ។ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ អៀង សារី អាចបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយនៅក្នុងអំឡុងពេលធ្វើសវនាការសម្រាប់ថ្ងៃនេះ។

ហើយកិច្ចជាកិច្ចបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី នួន ជា ដើម្បីមានលទ្ធភាពតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។ សូមអញ្ជើញ!

[០៩:០៦:២៧]

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក សុន អរុណ៖**

**ស៖** សួស្តីលោក ដេវីដ ឆេនដ៍ល័រ។ ជាបឋមនេះ ខ្ញុំមានសំណួរចំនួនមួយចំនួន។ សំណួរទីមួយរបស់ខ្ញុំ សួរលោក ឆេនដ៍ល័រ ថាក្នុងឋានៈលោកជាស្រាវជ្រាវ ជាអ្នកនិពន្ធ តើលោកមានជំនឿប៉ុន្មានភាគរយក្នុងការសិក្សាស្រាវជ្រាវ ពេលដែលលោកបានសម្ភាស បានស្រាវជ្រាវឯកសារផ្សេងៗ បានទៅ

មើលដល់កន្លែងផ្ទាល់របស់ឯកសារនោះ? លោកមានជំនឿទៅលើឯកសារនោះ មានប៉ុន្មានភាគរយ?

**លោក ដេវីដ ឆេនដ័ល័រ៖**

**ឆ៖** សូមអរគុណ។ ខ្ញុំមិនច្បាស់ថា លោកសួរមានន័យដូចម្ដេច? ថាតើខ្ញុំទាញសេចក្ដីសន្និដ្ឋានដូចម្ដេច? ថាតើសេចក្ដីសន្និដ្ឋានផ្អែកលើឯកសារប៉ុន្មាន ឬការសិក្សាប៉ុន្មាន? តើសំណួរដូចម្ដេច? អ៊ីចឹងសូមឆ្លើយថា ផ្អែកពីសៀវភៅមួយទៅសៀវភៅមួយ ហើយខ្ញុំបានសម្ភាស ហើយនិងមើលឯកសារច្រើនសរសេរសៀវភៅ "សំឡេងចេញពី ស-២១" ហើយសៀវភៅមួយនិយាយពី "សោកនាដកម្មប្រវត្តិសាស្ត្រកម្ពុជា" ហើយឯកសារដែលខ្ញុំមើលហ្នឹងសម្រាប់គាំទ្រការសរសេរនេះ គឺមានចំនួនច្រើន គឺប្រហែលជា៧៥ និងការសម្ភាសជាច្រើនផងដែរ សម្រាប់គាំទ្រ គឺ៨០ ទៅ៨២០ ឯកសារជាដើម។ បាទ អ៊ីចឹងបានប្រើឯកសារច្រើនណាស់ជាបង្អែកនៃការសរសេរសៀវភៅរបស់ខ្ញុំនេះ។

[០៩:០៨:៤៦]

**ស៖** នៅក្នុងការសរសេរសៀវភៅរបស់លោក។ សៀវភៅទាំងអស់ដែលលោកបានសរសេរហើយមកនោះ។ លោកស្រាវជ្រាវ លោកមិនបានទៅមើលដល់កន្លែងផ្ទាល់ លោកអាច -- ខ្ញុំអាចថា លោកបានឮគេប្រាប់ ឬក៏ពីឯកសារកន្លែងផ្សេងៗ យកមកចងក្រងជាសៀវភៅ។ ឯកសារទាំងអស់នោះ ខ្ញុំបញ្ជាក់នៅលើសំណួរលើកទីមួយរបស់ខ្ញុំនឹង ថាតើលោកមានជំនឿទៅលើឯកសារទាំងអស់ហ្នឹង ថាពិតប្រាកដ ត្រឹមត្រូវ ដូចឯកសារហ្នឹងនិយាយប៉ុន្មានភាគរយ?

**ឆ៖** នេះហើយជាចំណុចដែលអ្នកប្រវត្តិសាស្ត្រត្រូវការជ្រើសរើស រវាងឯកសារដែលខ្លួនជឿជាក់ថាស៊ីសង្វាក់គ្នា ឯកសារដែលខ្លួនទុកចិត្ត ដែលបង្ហាញពីការពិត ហើយនិងតាមរយៈការសម្ភាសមួយទៀត ដើម្បីបញ្ជាក់ ហើយនិងយើងត្រូវពឹងផ្អែកទៅលើការផ្ដល់សម្ភាស តើវាពិត មិនពិត? ហើយយើងមានជម្រើស បើនិយាយពីការកំណត់ទីតាំង ឬក៏ទៅមើលទីតាំងដោយខ្ញុំបានសរសេរនោះ គឺថាកត្តាពេលវេលា ខ្ញុំមិនអាចទៅមើលទីតាំងបានទេ មិន -- ក្នុងឆ្នាំ១៩៥០ ខ្ញុំមិនអាចទៅប្រទេសបារាំងបាន ប៉ុន្តែនៅក្នុងសម័យវាលពិឃាដនោះ ខ្ញុំមិនអាចចូលមកប្រទេសកម្ពុជាបានដើម្បីពិនិត្យទេ។ ហើយក្រោយពីឆ្នាំ១៩៨០ គឺខ្ញុំអាចមកកម្ពុជាផ្ទាល់ដើម្បីពិនិត្យមើល ហើយជួបសាក្សី ហើយជួបអ្នកដែលខ្ញុំត្រូវសម្ភាស ហើយឯកសារដែលចេញពីមកមនុស្សមួយចំនួន ខ្ញុំបានជួបមនុស្សច្រើន។ នេះជាកត្តាសំខាន់ៗដែលនាំឲ្យខ្ញុំសរសេរសៀវភៅនេះបាន។

**ស៖** សូមអរគុណ។ សំណួរទីពីររបស់ខ្ញុំ កាលពីថ្ងៃទី១៨ ខែនេះ ខែ៧ នេះ លោកបានឆ្លើយទៅ

នឹងលោកស្រីចៅក្រមថា “ពេលនោះ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ពិភពលោកគេមិនស្គាល់ទេ”។ តើលោកចង់និយាយពន្យល់តុលាការយ៉ាងណា ន័យរបស់លោកក្នុងពេលនោះ?

[០៩:១១:៤២]

**ឆ៖** ខ្ញុំត្រូវ ថាតើពេលណាដែលលោកចង់លើកហ្នឹង? ហើយនិយាយពីកម្ពុជាប្រជាធិបតេយ្យ មិនទទួលស្គាល់មន្ត្រីការទូតមានពីប្រទេសផ្សេងៗទៀតទេ លើកលែងតែ ចិន កូរ៉េខាងជើង វៀតណាម ឡាវ ហើយនិងមានស្ថានទូតមួយចំនួនមានរយៈពេលខ្លីទេ ហើយក្រោយមកក៏ត្រូវបិទទៅវិញ។ ហើយគេមិនទទួលស្គាល់ទេ វាអាស្រ័យទៅលើពេលវេលា តើលោកចង់និយាយខែមេសា ឆ្នាំ១៩៧៥ ឬពេលណា? ហើយខ្ញុំនឹងចង់បញ្ជាក់អ្វីដែលខ្ញុំលើកឡើង គឺថារបបកម្ពុជាប្រជាធិបតេយ្យមិនយកចិត្តទុកដាក់សំខាន់អំពីការទទួលស្គាល់ការទូតពីប្រទេសផ្សេងៗទៀតនោះទេ ដែលថាប្រទេសដែលគេមិនមានទំនាក់ទំនងជិតស្និទ្ធគេមិនខ្វល់ខ្វាយទេ។

**ស៖** អរគុណ។ នៅក្នុងរយៈពេលអំណាចរបស់កម្ពុជាប្រជាធិបតេយ្យ មានន័យថាចាប់ពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៩។ រយៈពេលហ្នឹង បើតាមឯកសារផ្សេង បានចែងមកច្រើនមកហើយ ថានៅក្នុងកម្ពុជាប្រជាធិបតេយ្យហ្នឹងមានៗធ្វើចំណងទូតជាមួយនឹងទូតបរទេស ជាពិសេសទូតកុម្មុយនីស្ត បក្សកុម្មុយនីស្តមានច្រើនណាស់ បក្ស -- ប្រទេសមកពីៗខាងអឺរ៉ុបខាងកើត។ ហើយប្រទេសដែលចូលបក្សកុម្មុយនីស្ត បើតាមខ្ញុំចាំមានប្រហែលជា២០ជាង ប្រហែលជិត៣០ ក្នុងពិភពលោក ប៉ុន្តែមានប្រទេសនៅអឺរ៉ុបខាងកើត មានមួយចំនួនធំ ដែលបានចងចំណងទូតជាមួយនឹងកម្ពុជាប្រជាធិបតេយ្យ។

[០៩:១៣:៤៨]

ហើយខ្ញុំសួរថា មានទូតមួយចំនួនធំ ពិសេស -- កុម្មុយនីស្តបក្សកុម្មុយនីស្ត ប្រទេសកាន់លទ្ធិកុម្មុយនីស្តដូចកម្ពុជាប្រជាធិបតេយ្យដែរ បានទទួលស្គាល់ បានធ្វើទំនាក់ទំនងពាណិជ្ជកម្ម បានធ្វើទំនាក់ទំនងផ្លូវទូតជាមួយគ្នា។ ហើយនៅអង្គការសហប្រជាជាតិក៏នៅលើកទង់ជ័យកម្ពុជាប្រជាធិបតេយ្យដែរក្នុងរយៈពេលនោះ។ អ៊ីចឹងហើយបានខ្ញុំសួរត្រឡប់មកវិញថា តើលោកដែលមានប្រសាសន៍ជម្រាបទៅចៅក្រម អំលោកស្រីចៅក្រម ខាតវ៉ាយថ៍ ថ្ងៃទី១៨ ខែ៧ ហ្នឹង ចង់មានន័យថាយ៉ាងម៉េច?

**ឆ៖** សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយតប! មានការជំទាស់តវ៉ាពីតំណាងសហព្រះរាជអាជ្ញា។ សូម

អញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន ខ្ញុំមិនចង់ជំទាស់ទេ ហើយខ្ញុំសូមជំទាស់។ នេះជាសំណួរវែង ហើយមិនសមស្របដើម្បីឲ្យមេធាវី ដើម្បីសួរសំណួរបែបនេះដោយមានសេចក្ដីថ្លែងការណ៍ ហើយនិងមានការអះអាងផ្ទាល់របស់គាត់។ ប្រសិនបើមេធាវីចង់បង្ហាញអង្គហេតុ គឺថាសូមធ្វើដូច្នេះជម្រាបទៅគាត់ដោយមានឯកសារ។ ហើយបើសិនជាមេធាវី លោកផ្ដល់អង្គហេតុតាមការចងចាំរបស់គាត់ មិនមានឯកសារយោងអ៊ីចេះ មិនស្របទេ លោកប្រធាន។

[០៩:១៥:៤០]

**លោក សុន អរុណ៖**

ខ្ញុំសូមឆ្លើយទៅព្រះរាជអាជ្ញា។ ខ្ញុំសួរទាំងអស់នេះ ក្នុងចំណុចដែលខ្ញុំចង់បញ្ជាក់អំពីពាក្យរបស់លោក ផេនដ៍ល័រ ជម្រាបឆ្លើយតបទៅនឹងលោកស្រីចៅក្រម កាលពីថ្ងៃទី១៨ ខែ៧។

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាមានប្រសិទ្ធភាព។ សំណួររបស់មេធាវីការពារក្ដីមិនច្បាស់ទេ ដោយផ្អែកទៅលើចម្លើយតបរបស់អ្នកជំនាញ តបទៅនឹងសំណួររបស់លោកស្រីខាតវ៉ាយថ៍ ដែលតាំងសំណួរយ៉ាងច្រើននៅព្រឹកថ្ងៃទី១៨នោះ។ មិនដឹងថាតើផ្អែកលើត្រង់ចំណុចណាមួយ ឬសំណួរណាមួយទេ។

មេធាវី ប្រសិនបើសួររបៀបនេះ គប្បីផ្អែកទៅលើប្រតិចារឹកដែលកំណត់នូវបន្ទាត់ ឬក៏ទំព័រយ៉ាងជាក់ច្បាស់ ឬក៏អាចដកស្រង់នូវខ្លឹមសារនៅក្នុងប្រតិចារឹកនៃចម្លើយរបស់អ្នកជំនាញ ដើម្បីយកមកសួរបញ្ជាក់ ទើបជាការត្រឹមត្រូវ។

អ្នកជំនាញមិនបាច់ឆ្លើយតបទៅនឹងសំណួររបស់មេធាវីការពារក្ដី ដែលសួរលោកអម្បាញ់មិញនេះទេ។

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងបន្តទៅនឹងសំណួរបន្តទៅទៀត។

**សួរដោយលោក សុន អរុណ៖**

**ស៖** សូមសួរលោកសាស្ត្រាចារ្យ ផេនដ៍ល័រ។ លោក ផេនដ៍ល័រ ដែលឃើញរចនាសម្ព័ន្ធ និង

មុខងារ និងតួនាទីរបស់កម្ពុជាប្រជាធិតេយ្យជាផ្លូវការទេ? រចនាសម្ព័ន្ធជាផ្លូវការ លោកដែលបានឃើញ បានទទួលច្បាស់លាស់ទេ រចនាសម្ព័ន្ធតាំងពីថ្នាក់លើរហូតដល់ថ្នាក់ក្រោម?

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** តើលោកយោងទៅរករចនាសម្ព័ន្ធរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យឬ? តើលោកចង់សួរថា តើមានឯកសារអីដែលបង្ហាញពីរចនាសម្ព័ន្ធហ្នឹង លោកចង់សួរខ្ញុំអីចឹងឬ? ខ្ញុំ ក្រែងលោខ្ញុំសំណួរលោកមិនយល់? ឬក៏លោកយោងទៅរករចនាសម្ព័ន្ធស្ថានទូត ឬក៏រដ្ឋាភិបាលទាក់ទងនឹងស្ថានទូតនោះ។ សូមលោកបញ្ជាក់។

[០៩:១៨:៥៤]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី គប្បីបញ្ជាក់ឲ្យបានច្បាស់លាស់ គឺឯកសារ ឬក៏រចនាសម្ព័ន្ធជាក់ស្តែងកម្ពុជាប្រជាធិបតេ្យ។ ពិបាកយល់ណាស់សំណួររបស់លោកក្នុងការសួរបែបនេះ។ បើសិនជាយោងទៅឯកសារ គឺច្បាស់លាស់ជាឯកសារ។ បើលោកយោងទៅលើរចនាសម្ព័ន្ធចាត់តាំងនៃរដ្ឋបាល ឬរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យជាក់ស្តែងនោះ គឺជារឿងមួយទៀត។

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក សុន អរុណ៖**

**ស៖** ខ្ញុំសូមបញ្ជាក់ នៅក្នុងរចនាសម្ព័ន្ធរបស់កម្ពុជាប្រជាធិបតេយ្យដែលយើងមានឯកសារមកគ្រប់ ច្រើនមកហើយ ហើយយើងបានជជែកគ្នាច្រើនខែមកហើយដែរ។ រចនាសម្ព័ន្ធ មានរចនាសម្ព័ន្ធរបស់បក្ស, រចនាសម្ព័ន្ធរបស់រដ្ឋាភិបាល និងរចនាសម្ព័ន្ធរបស់រដ្ឋសភា បក្សប្រជាជនកម្ពុជា។ អំមិញនេះខ្ញុំសួរថារចនាសម្ព័ន្ធរបស់បក្ស តើលោកបានដែលឃើញរចនាសម្ព័ន្ធជាផ្លូវការរបស់បក្សដែរឬទេ?

[០៩:២០:១៨]

**ឆ៖** ខ្ញុំបានឃើញឯកសារ ដែលជួយឲ្យខ្ញុំអាចបញ្ជាក់ថា តើរចនាសម្ព័ន្ធនោះដូចម្តេច? គឺៗមាននៅក្នុងលក្ខន្តិកៈបក្ស ដែលយើងបានមើលពីសប្តាហ៍មុន។ រចនាសម្ព័ន្ធរបស់បក្សហ្នឹង ចាប់ពីលេខាគណៈមជ្ឈិមរហូតទៅដល់ភូមិភាគ ហើយមន្ទីរ ដូចជាក្រសួង ប៉ុន្តែគេមិនហៅថាមន្ទីរ ហើយឯកសារផ្សេងៗគេហៅថាមន្ទីរនោះ។ ហើយមានឯកសារមួយចំនួនដែលយើងបានឃើញ ហើយបញ្ជាក់ពី

ព័ត៌មាននេះ។

**ស៖** ចុះចំពោះរចនាសម្ព័ន្ធរបស់រដ្ឋាភិបាល នៃបក្សកុម្មុយនីស្តកម្ពុជាវិញ តើលោកដែលបាន ទទួល បានស្រាវជ្រាវឃើញទេ ឯកសារជាផ្លូវការ?

[០៩:២១:២១]

**ឆ៖** ខ្ញុំគិតថា -- សូមអរគុណ -- សក្ខីកម្មពីរបីថ្ងៃអាទិត្យមុនហ្នឹងគឺថាបានបង្ហាញអំពីរចនាសម្ព័ន្ធបែបនេះ គឺៗថាផ្អែកទៅលើឯកសារមួយចំនួនច្រើន។ អ្វីដែលខ្ញុំបានឃើញក្រោយនេះ គឺបក្សកុម្មុយនីស្តកម្ពុជានេះ គឺលក្ខន្តិកៈរបស់គេ ហើយនៅក្នុងរដ្ឋធម្មនុញ្ញ ហើយនិងមានតារាងអង្គការលេខមួយចំនួនដែលយើងអាចអាចឃើញពេលក្រោយ គឺអាចនឹងសមស្រប ដែលយើងអាចបញ្ជាក់។ នេះជាឯកសារដែលមានសារប្រយោជន៍ជាបង្អែក ដែលមុននឹងខ្ញុំសរសេរសៀវភៅនោះ។

**ស៖** អរគុណលោក ឆេនដ័ល័រ។ ចំណងសៀវភៅរបស់លោក ដែលតុលាការទទួលស្គាល់ ហើយមានចុះលេខឯកសារ E3/17 មានឈ្មោះហៅថា “ប៉ុល ពត បងទី១” ខ្ញុំសួរថា ហេតុអ្វីបានជាលោកហៅបងប៉ុល ពត -- ហៅប៉ុល ពត បងទី១ ក្នុងរចនាសម្ព័ន្ធរបស់គេអ៊ីចឹងមានទី១ ទី២ ទី៣ រហូតអ៊ីចឹង ឬក៏លោកគ្រាន់តែដាក់តាមគំនិតរបស់លោកទេ? ឬក៏នៅក្នុងរដ្ឋាភិបាលនៅក្នុងបក្ស ជួរបក្សរបស់គេហ្នឹងមានដាក់លេខអ៊ីចឹងដែរឬអត់?

**ឆ៖** សូមអរគុណ។ នេះគឺជាឈ្មោះជាច្រើន ដែលគេហៅប៉ុល ពត។ មិនបានប្រើនៅក្នុងឯកសារផ្លូវការទេ ពាក្យថា “បងទី១” នេះ។ នេះជាការហៅដើម្បីសម្តែងការគោរព ជួនកាលគេថា អ៊ំលេខា។ បងទីមួយនេះគេមិនហៅអ្វីក្រៅពីបងទី១ នេះទេ គេហៅថាលេខា ឬក៏លេខាគណៈមជ្ឈិមបក្ស។ នេះជាពាក្យដែលគេប្រើនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ ហើយខ្ញុំគិតហើយ នេះហើយជាពាក្យដែលជាចំណងជើងសមស្រប សម្រាប់សៀវភៅខ្ញុំ ក៏ខ្ញុំប្រើ។

[០៩:២៣:៥៤]

**ស៖** លោកបានបញ្ជាក់រួចមកហើយ អំពីរចនាសម្ព័ន្ធរបស់បក្ស គឺហាក់ដូចជាពីរ៉ាមីត ពីលើចុះមកក្រោម។ ចុះអង្គភាពតូចៗខាងក្រោម ឧទាហរណ៍ដូចជា ស-២១ -- មន្ទីរ ស-២១ លោកដឹងច្បាស់ថា មានរចនាសម្ព័ន្ធអ៊ីចឹងដែរ ឬក៏ខុសគ្នាយ៉ាងម៉េច?

**ឆ៖** ជួនកាលមាន ជួនកាលមិនមាន។ នៅក្នុង ស-២១ គឺជាថ្នាក់ដឹកនាំបែបសមូហភាព ហើយគេដឹកនាំស្ថាប័នរបស់គេ សេចក្តីសម្រេចមួយចំនួនគឺ ឌុច ធ្វើសេចក្តីសម្រេចក្នុងឋានៈជាមេ

ស-២១ គាត់គឺជាអ្នកដែលមានសិទ្ធិ ក្នុងការបញ្ជូនឯកសារទៅថ្នាក់លើ ជាពិសេសទៅសុន សេន នៅក្នុងកម្រិតមួយ គឺមានលក្ខណៈ ជាពីរ៉ាមីត។ ប៉ុន្តែនៅក្នុងភូមិភាគគឺគេមានផ្នែកខាងសេដ្ឋកិច្ច ហើយមានគណៈដែលមានសមាជិកបីនាក់ ដើម្បីជាគណៈនៅក្នុងតំបន់នៅក្នុងផ្នែកផ្សេងៗ។ ប៉ុន្តែនៅស-២១ ហ្នឹងក៏មានលក្ខណៈជាទម្រង់ពីរ៉ាមីតដែរ នៅតាមទ្រឹស្តីរបស់បក្សកុម្មុយនីស្តកម្ពុជានោះ ដែលថានៅផ្នែកខាងក្រោមគឺមានមនុស្សគាំទ្រជាអ្នកក្រោមបង្គាប់ច្រើន។ បាទ រីឯមេនៅខាងកំពូលនៃពីរ៉ាមីតនោះ។

**ស៖** អរគុណ។ លោក ឆេនដ័ល័រ លោកបានស្រាវជ្រាវយូរហើយច្រើនៗឆ្នាំមក។ សៀវភៅរបស់លោកមួយចំនួន ដែលលោកបានសរសេរតាមការស្រាវជ្រាវរបស់លោក។ ការស្រាវជ្រាវនូវឯកសារដែលលោកយកមកសរសេរក្នុងសៀវភៅនុ៎ង លោកមានដែលភប់ប្រទះនូវហត្ថលេខា ឬត្រាពីថ្នាក់កំពូលមករហូតដល់ថ្នាក់កណ្តាល រហូតមកថ្នាក់ក្រោមទៀតទៅទៀតអីចឹងទេ? ដែលមានបានឃើញ ឬបានស្រាវជ្រាវឃើញនូវឯកសារណា ដែលមានហត្ថលេខា និងត្រាទេ?

[០៩:២៦:៣៧]

**ឆ៖** ខ្ញុំមិនគិតថា ខ្ញុំបានឃើញឯកសារដែលបានពិភាក្សាពីមុនទៅ គឺថាមានហត្ថលេខា ឬក៏មានអក្សរផ្ទាល់ដៃរបស់ សុន សេន។ ប៉ុន្តែពេលដែលគេបញ្ជូនឯកសារទៅ បងវ៉ាន់ ទៅ អៀង សារី ឬក៏ទៅបងនួន ដែលជា នួន ជា នោះ ហត្ថលេខានោះ គឺជាហត្ថលេខាអ្នកដែលបញ្ជូនទៅ ដែល -- ហើយយើងធ្វើការច្រើនឆ្នាំដើម្បីស្វែងរកហត្ថលេខា ប៉ុល ពត ហ្នឹង គឺថា -- ប៉ុន្តែវាអាចមានការហត្ថលេខា -- មានការសរសេរផ្ទាល់ដៃ ប៉ុន្តែយើងដឹងតែហត្ថលេខារបស់ សុន សេន និងអក្សរផ្ទាល់ដៃរបស់ សុន សេន រីឯបងទីបីនៅក្នុងបក្សនោះតែប៉ុណ្ណោះបាទ។

**ស៖** បើលោកមិនបានដែលឃើញហត្ថលេខាថ្នាក់កំពូលចុះមកដល់ថ្នាក់កណ្តាល ឬថ្នាក់ក្រោម លោកអាចសន្និដ្ឋានថា បញ្ហាទាំងអស់ដែលខ្មែរជាទូទៅបានចោទប្រកាន់ថា បក្សកុម្មុយនីស្តកម្ពុជាសម្លាប់ប្រជាជនឯង ថាតើលោកជឿទេក្នុងសម្តីចោទប្រកាន់ទាំងអស់នោះ?

**ឆ៖** ខ្ញុំមិនគិតថាសំណួរលោកច្បាស់ទេ ប៉ុន្តែបើសិនជា សុន សេន គាត់សរសេរមកប្រាប់ ឌុច ឲ្យធ្វើការឲ្យកម្ទេច ឬក៏ឲ្យចាត់ការមនុស្សទាំងអស់នៅស-២១ នោះ នេះគឺជាភស្តុតាងពីចម្លើយរបស់សាក្សីមួយចំនួនដែលបង្ហាញថា នេះជាបញ្ហាមកពីថ្នាក់លើ។ អ្វីដែលគេធ្វើគឺធ្វើតាមបញ្ហារបស់ថ្នាក់លើ គឺថាដើម្បីគេប្រមូលមនុស្ស ឬក៏កម្ទេចកម្មាភិបាលជាដើមហ្នឹង។ តាមធម្មតាគឺបញ្ហាមកពីថ្នាក់លើគេមិនចុះហត្ថលេខាទេ ប៉ុន្តែគេគោរពណាស់បញ្ហានោះ។ កាលណាគេគោរពបញ្ហានោះហើយ គេដឹងថា

បញ្ហានោះមកពីថ្នាក់លើ អាហ្នឹងគឺ -- នេះជាភស្តុតាងមួយដែលយើងទទួលបាន ត្រឹមប៉ុណ្ណឹង។

[០៩:២៩:៣៦]

**ស៖** លោក ផេនដ៍ល័រ លោកបានសរសេរសៀវភៅ “សំឡេងស-២១” ត្រង់ទំព័រ១០៤ បាននិយាយថា កម្មាភិបាលជាន់ខ្ពស់បានជ្រើសរើសយកប្រវត្តិរូបមួយចំនួន របស់កូនចៅនៅក្រោមបញ្ជាមកមើល។ នួន ជា បានសម្តែងនូវការសោកស្តាយរបស់ខ្លួន ដែលមិនសូវយកចិត្តទុកដាក់ក្នុងរឿងនេះថា ចំណុចខ្វះខាតរបស់ខ្ញុំ – ខ្ញុំមានន័យថា នួន ជា – គឺថា ខ្ញុំមិនបានតាមដានឯកសារប្រវត្តិរូបរបស់បក្ស និងសមាជិកស្នូលឲ្យបានលម្អិត ហើយចាត់វិធានការបោសសម្អាតនៅក្នុងជួរបក្សទេ។ ខ្ញុំមើលតែសកម្មភាពទូទៅរបស់គេប៉ុណ្ណោះ។ ខ្ញុំមិនមានធាតុដើម ដែលមានសារៈសំខាន់របស់គេទេ។ ខ្ញុំមិនបានជីកឫសជីកគល់ រឿងគ្រួសារគេទេ។ នេះធ្វើឲ្យខ្មាំងមានឱកាសយ៉ាងងាយក្នុងការជ្រៀតចូល ស៊ីរូងផ្ទៃក្នុងបក្ស”។ អត្ថបទដូច ខ្ញុំបាទ បានអានរួចមកខាងលើហើយនេះ តើលោកយល់ថាយ៉ាងម៉េច មានន័យថាយ៉ាងម៉េច? សូមលោកជម្រាបតុលាការឲ្យបានច្បាស់លាស់ពីរឿង ន័យរបស់លោក សម្តីលោក នួន ជា និយាយខាងលើនេះ។

[០៩:៣១:១៣]

**ឆ៖** ខ្ញុំមិនបានទទួលសេចក្តីដកស្រង់ទាំងស្រុងទេ។ នេះជាចម្លើយដែលលោក នួន ជា បានធ្វើឡើងដើម្បីដោះបន្ទុកគាត់។ ខ្ញុំមិនច្បាស់ទាំងស្រុងថា តើយើងត្រូវពឹងផ្អែកទាំងស្រុងឬអត់ទេ។ ហើយខ្ញុំចង់ឃើញ សេចក្តីដកស្រង់ហ្នឹងចំពោះមុខខ្ញុំ ដើម្បី -- ប្រហែលជាសូមអនុញ្ញាតលោកប្រធាន ដើម្បីបង្ហាញនៅលើអេក្រង់ ដើម្បីខ្ញុំបានឃើញសេចក្តីដកស្រង់ ដើម្បីឲ្យខ្ញុំអាចឆ្លើយបាន។

**ប្រធានអង្គជំនុំ៖**

បាទឥឡូវលោកមេធាវី លោកដកស្រង់នូវអត្ថបទនិពន្ធរបស់អ្នកជំនាញ ដើម្បីសួរដេញដោលគប្បីផ្តល់នូវឯកសារលេខ ERN ទាំងបីភាសា ហើយនិងដាក់បង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រ និងទូរទស្សន៍ផង ហើយនិងផ្តល់ឯកសារជាក្រដាសផងក្នុងករណីចាំបាច់ ដើម្បីជូនអ្នកជំនាញពិនិត្យជាមុនមុននឹងផ្តល់ចម្លើយ។

[០៩:៣២:១២]

*(សម្រាករយៈពេលខ្លី)*

[០៩:៣៣:០៧]

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំស្ដាយណាស់ ដោយខ្ញុំមិនបានរៀបចំឯកសារគ្រប់គ្រាន់មកជម្រាប មកសួរចម្លើយអ្នកជំនាញ។ ខ្ញុំស្មានតែលើក -- ខ្ញុំមិននិយាយស្មានទេ ប៉ុន្តែខ្ញុំយល់ថា ប្រហែលលោកជំនាញលោកនៅចាំអត្ថបទរបស់លោកខ្លះ។ បើអ៊ីចឹងទេ ខ្ញុំនឹងបន្តសំណួរទៅមុខទៀត ខ្ញុំចោលសំណួរហ្នឹងចុះ។

**សួរដោយលោក សុន អរុណ៖**

**ស៖** ខ្ញុំមានសំណួរមួយទៀត។ នៅឯកសារជាច្រើនណាស់ ភាគច្រើនតែឡេក្រាម ទូរលេខមកពីយោធា មកពីភូមិភាគតែងតែសរសេរមកថ្នាក់លើជូនបងអ៊ីចឹងទៅ រួចពីហ្នឹងចម្លងជូនបងនួន អ៊ំនួន បងវ៉ាន់ បងហែម អីអ៊ីចឹង។ល។ ក្នុងអត្ថបទមួយៗ ដែលសរសេរជូនទៅអ្នកណាហើយ ចម្លងជូនអ្នកខាងក្រោមទាំងប៉ុន្មាន លោកយល់ថា អាចម្លងជូនហ្នឹងអ្នកប៉ុន្មានហ្នឹង មានឥទ្ធិពលដូចផ្ញើជូនទៅនៅខាងលើ ដូចដែល -- ឧទាហរណ៍ថា បើផ្ញើជូនទៅ បង មានន័យថា បងពត ហើយចម្លងជូនទៅបងនួនបងហែម បងវ៉ាន់ បងអីអ៊ីចឹង។ តើន័យនៃពាក្យ “បង” ខាងលើ ហើយនិង “ចម្លងជូន” ខាងក្រោមបើតាមលោកយល់ថាអ្នកខាងក្រោមហ្នឹងអាចអនុវត្តបានដូចអ្នកផ្ញើជូនខាងលើទេ? លោកយល់សំណួររបស់ខ្ញុំ? នេះជាបែបបទរដ្ឋបាលទេបាទ។

[០៩:៣៥:៣០]

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** នេះជាសំណួរដ៏គួរឲ្យចាប់អារម្មណ៍មួយ ជាការពិតទៅវាគ្រាន់តែជានីតិវិធីការិយាធិបតេយ្យ គឺយើងគ្រាន់តែចម្លងជូន ប៉ុន្តែអ្នកដែលគេចម្លងជូនហ្នឹង គឺអត់សិទ្ធិបំពេញ ឬក៏មានអំណាចនៅក្នុងការដោះស្រាយ ដូចតែអ្នកដែលគេផ្ញើជូននោះទេ។ ដូចដែលខ្ញុំបញ្ជាក់នៅក្នុងសក្ខីកម្មពីដើមរបស់ខ្ញុំអ៊ីចឹង គឺថាបក្សកុម្មុយនីស្តកម្ពុជា ឬក៏កម្ពុជាប្រជាធិបតេយ្យហ្នឹង គឺជាការដឹកនាំបែបសមូហភាព។ ដូច្នេះហើយ គឺថាអ្នកនៅក្នុងថ្នាក់ដឹកនាំហ្នឹង ត្រូវធ្វើការសម្រេចជារួមដើម្បីដោះស្រាយទៅលើអ្វីដែលបានកើតឡើង។ ដូច្នេះការដែលគាត់ ឬក៏ការដែលអ្នកផ្ញើហ្នឹងមានឈ្មោះច្រើន មានចម្លងជូនច្រើនហ្នឹងបើតាមការស្រាវជ្រាវរបស់ខ្ញុំ គឺថាមិនមែនច្រើនណាស់ណាទេ គឺមានតែប៉ុន្មាន មានតែមួយចំនួនប៉ុណ្ណោះ។ ដូច្នេះហើយការនេះបង្ហាញថា ព័ត៌មានហ្នឹងគឺគេបែងចែកត្រូវត្រឹមតែក្រុមមនុស្សមួយចំនួនតូចតែប៉ុណ្ណោះ។ ធ្វើបែបនេះដើម្បីឲ្យមានការការពារសុវត្ថិភាពឲ្យបានច្បាស់លាស់ ហើយឲ្យមានការ

រក្សាសម្ងាត់ទៅលើសកម្មភាពរបស់មេដឹកនាំនោះ។

[០៩:៣៦:៤៩]

**ស៖** សូមអរគុណលោក ឆេនដ៍ល័រ។ នេះជាសំណួរបញ្ចប់របស់ខ្ញុំ។ សេចក្ដីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន។ អាហ្នឹងនៅឯកសារលេខ E3/12 ចុះថ្ងៃទី -- សេចក្ដីសម្រេចនេះចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦។ ត្រង់សិទ្ធិ -- ទីមួយ "សិទ្ធិសម្រេចកម្ទេចក្នុងជួរ និងក្រៅជួរ" ចំណងជើងថាអ៊ីចឹង។ "សំណួមពរ៖ ១) ឲ្យមានការក្របខ័ណ្ឌក្នុងការកិច្ចអនុវត្តផ្ដាច់ការបដិវត្តន៍របស់យើង។ ពង្រឹងប្រជា -- ២) ពង្រឹងប្រជាធិបតេយ្យសង្គមនិយមរបស់យើង។ ទាំងអស់នេះដើម្បីពង្រឹងរដ្ឋអំណាចរបស់យើង៖ (ចុចមួយ) បើនៅក្នុងក្របខ័ណ្ឌមូលដ្ឋានត្រូវអចិន្ត្រៃយ៍សម្រេច។

បើជុំវិញមន្ទីរមជ្ឈិមត្រូវគណៈមន្ទីរសម្រេច -- អ៎សូមទោស! ជុំវិញមន្ទីរមជ្ឈិមត្រូវគណៈមន្ទីរមជ្ឈិមសម្រេច។

[០៩:៣៨:២៦]

ចំណុចទីបី តំបន់ឯករាជ្យត្រូវអចិន្ត្រៃយ៍សម្រេច។

ចំណុចទីបួន កងទ័ពមជ្ឈិមត្រូវលេខាធិការសម្រេច"។

ត្រង់ចំណុចសំណួមពរ ចំណុចទីមួយនៃសេចក្ដីសម្រេចរបស់គណៈមជ្ឈិមនេះ ខ្ញុំសូមសួរលោក ឆេនដ៍ល័រ ថាអំណាចទាំងអស់នេះដែលគណៈមជ្ឈិមបានសម្រេចចែកឲ្យទៅខាងថ្នាក់អង្គភាពមួយៗអ៊ីចឹងហើយ។ តើថ្នាក់ដឹកនាំខាងលើនោះ កំពូលនោះ នៅមានអំណាចនឹងបញ្ញាតទៅទៀតទេ ឬនេះសម្រេចរបស់មជ្ឈិមហើយ ឲ្យទៅមូលដ្ឋានអស់ហើយ? ការអត់បាយ ការធ្វើការនឿយហត់ខ្លាំង រហូតដល់អត់ថ្នាំអត់សង្កូវអីហ្នឹង បើតាមឯកសារនិយាយមក។ តើលោកយល់ថា ទាំងអស់នេះជាអំណាចរបស់មូលដ្ឋានផ្ទាល់ ឬក៏បញ្ហារបស់គណៈមជ្ឈិមផ្ទាល់?

[០៩:៣៩:៥១]

**ឆ៖** នេះជាសំណួរដ៏ស្មុគស្មាញមួយ ហើយឯកសារខ្លួនឯងផ្ទាល់ហ្នឹង ឯកសារនេះផ្ទាល់ហ្នឹងក៏មិនបាននិយាយ ថាតើវាមានការ -- ថាការសម្រេចនោះ វាបានអនុវត្តដែរឬអត់នោះទេ? វាគ្រាន់តែឯកសារដែលគេរក្សាទុកជាលក្ខណៈប្រវត្តិសាស្ត្រប៉ុណ្ណោះ។ ដូច្នេះហើយ ខ្ញុំមិនដឹងថាតើឯកសារហ្នឹងវាបានអនុវត្តនៅថ្នាក់ក្រោមយ៉ាងណានោះទេ។ ប៉ុន្តែឯកសារទាំងអស់នេះ ប្រហែលជាមិនត្រូវបានគេបញ្ជូនទៅថ្នាក់ក្រោមនោះទេ។ ការពិតគ្រាន់តែផ្ដល់ឲ្យគណៈអចិន្ត្រៃយ៍មានគោលការណ៍ដើម្បីធ្វើការ

សម្រេច ឧទាហរណ៍ថាតាមរយៈទូរលេខ ឬក៏ទូរសារនោះជាដើម។ ដូច្នេះហើយ អានេះវាបញ្ជាក់អំពីទំនាក់ទំនងរវាងមជ្ឈិម អចិន្ត្រៃយ៍ ជាមួយនឹងតំបន់ ឬក៏ភូមិភាគ។

[០៩:៤០:៤៨]

ហើយបន្ទាប់មក អានេះគឺក្នុងករណីគឺកើតឡើងនៅពេលដែលខាងមជ្ឈិម -- នៅខាងភូមិភាគ និងតំបន់ហ្នឹងមានការសង្ស័យ នៅពេលដែលគណៈមជ្ឈិមគាត់សង្ស័យទៅខាងភូមិភាគ តំបន់។ ហើយឯកសារនេះចេញមកបន្ទាប់ពីមានការបញ្ជាមួយចំនួនមួយ។ សូមអរគុណ។

**លោក សុន អរុណ៖**

លោកប្រធាន ខ្ញុំអស់សំណួរ ប៉ុន្តែបន្ទាប់មកខ្ញុំមានសហការីខ្ញុំ នឹងមានសំណួរតទៅទៀត។ ប៉ុន្តែមុននឹងសហការីខ្ញុំនឹងមានសំណួរ លោក នួន ជា ផ្ទាល់ គាត់មានសំណួរមួយ ចង់សួរទៅអ្នកជំនាញតាមរយៈលោកប្រធាន តើអនុញ្ញាតឲ្យគាត់សួរឬទេ?

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញលោក នួន ជា!

[០៩:៤១:៤៣]

**លោក នួន ជា៖**

សូមគោរពបង ពុកម៉ែ បងប្អូនរួមជាតិ។ សូមគោរពតុលាការ សូមគោរពលោកប្រធាន។ សូមគោរពអ្នកជំនាញ។

ខ្ញុំមានពីរសំណួរ។ សំណួរទីមួយ តើតាំងពីដើមមក រហូតដល់ឥឡូវ ទំនាស់រវាងបក្ស -- រវាងប្រជាជនកម្ពុជា និងវៀតណាម មានមូលហេតុសំខាន់មកពីបញ្ហាព្រំដែន ឬមកពីបញ្ហាអ្វីជាសំខាន់? នេះខ ទីមួយ។ ខទីពីរ--

**ប្រធានអង្គជំនុំ៖**

បានហើយ នួន ជា ចាំស្តាប់ការឆ្លើយតបសិន ចំពោះសំណួរទីពីរ នឹងសួរបន្តទៀត។ លោកអ្នកជំនាញ លោកស្តាប់សំណួរលោក នួន ជា សួរអំមិញបានទេ? ហើយបើសួរបាន -- បើស្តាប់បានហើយលោកអាចឆ្លើយតបនឹងសំណួរដែលសួរដោយលោក នួន ជា នេះបានដែរឬទេ?

សូមអញ្ជើញបាទ!

[០៩:៤២:៥៩]

**លោក ដេវីដ ឆេនដ៍ល័រ៖**

សូមអរគុណ។ ពាក់ព័ន្ធទៅនឹងសំណួររបស់លោក នួន ជា ជាមនុស្សដែលខ្ញុំគោរពជាទីបំផុតនុ៎ង គឺថាចំពោះសំណួរនេះ គឺខ្ញុំគិតថាប្រហែលជាត្រូវការចំណាយវារាប់រយទំព័រ អាចដល់១០០, ២០០ទំព័រ ដើម្បីនិយាយអំពីជម្លោះរវាងវៀតណាម ជាមួយនឹងកម្ពុជា រវាងបក្សកុម្មុយនីស្តកម្ពុជា និងបក្សកុម្មុយនីស្តវៀតណាមនៅក្នុង -- នឹងនៅពេលបន្តបន្ទាប់មកទៀត និងនៅពេលមុនៗទៀត។ ដូច្នេះហើយ ខ្ញុំគិតថាវាត្រូវការពេលវេលា និងការពន្យល់យ៉ាងច្រើន ពន្យល់ទៅលើប៉ារ៉ាម៉ែត្រទាំងអស់នេះ។ ដូច្នេះហើយ ប្រសិនបើយើងនិយាយត្រឹមតែ ៧៥, ៧៩ វាដូចជាពិបាកបន្តិច។ ប៉ុន្តែជាការពិតណាស់ គឺហេតុផល ឬក៏មូលហេតុដែលខ្ញុំព្យាយាមធ្វើការសន្និដ្ឋាន ដូចដែលទាំងអស់គ្នាបានដឹង គឺថាមូលហេតុសំខាន់ គឺថា ដូចដែលខ្ញុំបានពិភាក្សាកាលពីមុនរួចមកហើយ គឺការនិយាយអំពីការបន្ទោសគ្នាជាច្រើន ការទទួលខុសត្រូវដែលៗចែករំលែក ឬក៏ដែលទទួលខុសត្រូវដោយភាគីទាំងពីរ។

[០៩:៤៤:១២]

ដូច្នេះ តាមដែលខ្ញុំយល់ គឺជាការបរាជ័យនៅក្នុងការគោរពទស្សនៈរបស់ភាគីទៅវិញទៅមក។ ហើយម្យ៉ាងទៀត គឺមិនមានការចរចា ឬក៏មិនមានការជជែកពិភាក្សាគ្នា ដែលធ្វើឲ្យមានបញ្ហានេះកើតឡើង។ ដូច្នេះ យើងមិនមែនជាបញ្ហា ថាតើអ្នកណាចាប់ផ្តើមមុន? អ្នកណាចាប់ផ្តើមអ្វីនោះទេ? ប៉ុន្តែវាគ្រាន់តែជាការបង្ហាញ ឬក៏ការសល់នូវរបប លន់ នល់ ហើយបន្តមករបបកម្ពុជាប្រជាធិបតេយ្យ ហើយនិងការបោស -- ការៗប៉ះពាល់ជាមួយនឹងវៀតណាមរបស់របប លន់ នល់ ឬក៏របបកម្ពុជាប្រជាធិបតេយ្យ ឬក៏ការវាយប្រហារជាទូលំទូលាយនៅក្នុងចុងឆ្នាំ៧៧ ឬក៏៧៨នោះឯង។ ដូច្នេះមូលហេតុ ប្រសិនបើលោកចង់ដឹងគឺ ប្រសិនបើយើងពិនិត្យមើលទៅលើប្រយោគមួយ ដើម្បីពណ៌នាអំពីមូលហេតុហ្នឹង ខ្ញុំសូមនិយាយថា វាជាមូលហេតុប្រវត្តិសាស្ត្រ គឺការមិនទុកចិត្តគ្នាតាមប្រវត្តិសាស្ត្រ និងការមិនទុកចិត្តគ្នាជាលក្ខណៈទៅវិញទៅមក។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក នួន ជា តាំងសំណួរទី២របស់លោក!

**លោក នួន ជា៖**

តើកំណើតរបស់បក្សកុម្មុយនីស្តកម្ពុជាមានមកដោយសារចលនារបស់ប្រជាជនកម្ពុជា ឬមានកំណើតដោយជនបរទេសនាំពីក្រៅចូលមក?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកសាស្ត្រាចារ្យឆ្លើយតបនឹងសំណួរ ដែលសួរឡើងដោយជនជាប់ចោទនួន ជា!

[០៩:៤៦:១៦]

**លោក ដេវីដ ឆេនឌ័ល័រ៖**

តាមតែការបកប្រែគឺថា សំណួរចង់សួរថា តើកំណើតបក្សកុម្មុយនីស្តកម្ពុជាហ្នឹងកើតមកពីអ្វី? ដូច្នេះ ខ្ញុំគិតថា ប្រហែលជាយើងមានការបកស្រាយ មានការបោះពុម្ពផ្សាយរយារណាស់មកហើយ គឺថា បក្សកុម្មុយនីស្តកម្ពុជាគឺជាចលនាកុម្មុយនីស្តមួយកើតឡើងនៅឆ្នាំ៧៥ -- ឆ្នាំ៦៧ ហើយប៉ុន្តែយ៉ាងណាក៏ដោយ នៅពេលដែលយើងនិយាយអំពីកំណើត គឺយើងទៅមើលពីប្រវត្តិសាស្ត្រនៅក្នុងចុងឆ្នាំ៤០ និង៥០ គឺនៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាហ្នឹង គឺនៅពេលនោះ គឺថាគំនិតនៃកុម្មុយនីស្តកម្ពុជាហ្នឹងគឺ ៗ គំនិតដូចគ្នានឹងកុម្មុយនីស្តវៀតណាម។ ដូច្នេះហើយគំនិតរបស់កុម្មុយនីស្តគឺដើម្បីផ្តួលរំលំអំណាចរបស់អាណានិគមបារាំង ចេញពីប្រទេសវៀតណាម ឡាវ និងកម្ពុជា។ ដូច្នេះហើយគឺថា ទាំងបីប្រទេសហ្នឹងគឺមានគោលដៅដូចៗគ្នា ហើយអាចថាវៀតណាមក៏ជាអ្នកបណ្តុះបណ្តាលកម្ពុជា។ ហើយប្រសិនបើយើងនិយាយឲ្យច្បាស់ គឺថាប្រភពដើមនៃបក្សកុម្មុយនីស្តកម្ពុជាហ្នឹង ប្រសិនបើយើងមើលទៅចុងទសវត្សរ៍៤០, ៥០ គឺមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយវៀតណាម។ ប៉ុន្តែនៅពេលដែលយើងមើលមកដល់ឆ្នាំ៦៧ គឺនៅក្នុងសមាជឆ្នាំ៦០ហ្នឹង គឺមានសេចក្តីសម្រេច ឬក៏មានកំណត់ហេតុ គឺបានពន្យល់យ៉ាងច្បាស់លាស់។ នៅពេលនុំងគឺបញ្ជាក់ច្បាស់ថា គឺគេបានបំបាត់ ឬក៏បោះបង់ចោលនូវឥទ្ធិពលរបស់វៀតណាម នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា នៅពេលដែលបក្សកុម្មុយនីស្តកម្ពុជារៀបចំលក្ខន្តិកៈ ឬក៏នៅពេលដែលមានសង្គ្រាមស៊ីវិល គឺនៅពេលនុំងឥទ្ធិពលរបស់វៀតណាមបានថយចុះយ៉ាងខ្លាំង។

[០៩:៤៨:១២]

ហើយនៅពេលនុំង គឺចលនាកម្ពុជាគឺហាក់ដូចជាចលនាស្វយ័ត ឬក៏ឯករាជ្យ ដែលគ្រាន់តែមានការសហការជាមួយវៀតណាមបន្តិច។ ហើយបន្ទាប់មកទៀត គឺព្យាយាមផ្តាច់ខ្លួនចេញពីចលនាវៀតណាម។ សូមអរគុណ។

**លោក នួន ជា៖**

លោកប្រធាន សូមអស់សំណួរ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីទាំងអស់គ្នា ជាពិសេសសូមជម្រាបសួរលោកសាស្ត្រាចារ្យ សូមអរគុណដែលលោកសាស្ត្រាចារ្យអញ្ជើញមកទីនេះ។ ហើយបន្ទាប់ចំណាយពេលវេលាមួយសប្តាហ៍យ៉ាងលំបាក យ៉ាងហត់នឿយ នៅថ្ងៃនេះខ្ញុំសូមចាប់ផ្តើមសួរលោកសាស្ត្រាចារ្យនូវសំណួរមួយចំនួន អំពីប្រភពនៃចំណេះដឹងរបស់លោក។ យើងបាននិយាយអំពីបញ្ហានេះ គឺលោកសាស្ត្រាចារ្យបានពន្យល់រួចទៅហើយកាលពីសប្តាហ៍មុន ដូច្នេះហើយខ្ញុំនឹងសួរដោយខ្លីនោះទេ។

[០៩:៤៩:៣៦]

**សួរដោយលោក ហ្សាស្តើ ប៉ោ៖**

**ស៖** ហើយខ្ញុំចង់និយាយអំពីប្រយោគដែលលោកថ្លែងកាលពីថ្ងៃពុធ គឺទំព័រ៥២, ៥៣ នៃប្រតិចារឹក ហើយខ្ញុំសូមដកស្រង់ លោកបាននិយាយថា "គឺថា នៅក្នុងកំណត់ហេតុ នៅពេលដែលខ្ញុំសរសេរនៅក្នុងចុងឆ្នាំ៨០ ខ្ញុំមានអារម្មណ៍រីករាយយ៉ាងខ្លាំង ដែលខ្ញុំអាចមានលទ្ធភាពទទួលបានឯកសារនៅក្នុងដីកាដំណោះស្រាយ ព្រោះខ្ញុំបានអានឯកសារប៉ុន្មានខែ ប៉ុន្មានថ្ងៃកាលពីមុនមក ហើយឯកសារនេះបង្ហាញច្បាស់ដូចអ្វីដែលខ្ញុំបានសរសេរនៅក្នុងសៀវភៅ ព្រោះកាលពីមុន គឺឯកសារនោះ អត់មាននោះទេ។ លោកសាស្ត្រាចារ្យ ឆេនដ៍ល័រ តើលោកអាចជម្រាបបានដែរឬទេ ថាតើឯកសារអ្វីខ្លះដែលលោកបាននិយាយ នៅពេលដែលនិយាយថា លោកបានអានឯកសារដែលលោកបានមិនបានអានពីពេលមុន? តើឯកសារនោះ ឯកសារអ្វីខ្លះ?

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** ឧទាហរណ៍ ខ្ញុំនិយាយយោងទៅលើលិខិតចំហរបស់សម្តេចសីហនុ ដែលធ្វើ -- ដែលហៅថា ដែលឯកសារនោះពណ៌នាអំពីឯកសារបើកចំហ ប៉ុន្តែវាជាជើងទំព័រនៅក្នុងដីកាដំណោះស្រាយដែលបកស្រាយអំពីការពិភាក្សានៅក្នុងខែកក្កដា ឆ្នាំ៧៩ ដែលខ្ញុំអត់មានកាលពីមុនមកនោះ។ ដូច្នេះឯកសារនេះ គឺជាសេចក្តីថ្លែងការណ៍មួយ ដែលថ្លែងឡើងដោយ -- វាការពិតវាគ្រាន់តែជាសេចក្តីថ្លែងការណ៍រួម វាជាការយល់ឃើញទូទៅរបស់ខ្ញុំ ហើយវាបានឆ្លុះបញ្ចាំងនូវជើងទំព័រនៅក្នុងសៀវភៅរបស់ខ្ញុំប៉ុណ្ណោះ។ ខ្ញុំមិនរកឃើញនូវឯកសារណាមួយដែលមានលក្ខណៈជាបដិវត្តន៍ ផ្លាស់ប្តូរ ឬក៏ធ្វើឲ្យ

មានការប្រែប្រួលខ្លាំងក្លានោះទេ។ ដូច្នេះហើយ គឺឯកសារជាច្រើនទៀតដែលខ្ញុំបានមើលនៅក្នុងដីកាដំណោះស្រាយ ឬក៏ចម្លើយសារភាពណាមួយ។

[០៩:៥១:៥៣]

ការពិតឯកសារទាំងអស់នេះ វាគ្រាន់តែបញ្ជាក់បន្ថែម ឬក៏វាសង្កត់បន្ថែមទៅលើអ្វីដែលខ្ញុំដឹងពីមុនមក។ ព្រោះថា ផ្នែកខ្លះ ឬក៏ឯកសារខ្លះ គឺខ្ញុំមិនបានសិក្សាឲ្យបានជ្រាលជ្រៅពេកនោះទេ។ ដូច្នេះអ្វីដែលខ្ញុំបាននិយាយ គឺថាខ្ញុំចង់និយាយថា អ្វីៗដែលខ្ញុំបានអាននៅក្នុងដីកាដំណោះស្រាយនោះ ធ្វើឲ្យខ្ញុំនឹកឃើញថា អ្វីដែលខ្ញុំនិយាយកាលពីមុនមកហ្នឹង គឺវាត្រឹមត្រូវ។ គឺថាឯកសារដែលខ្ញុំបានអានមុន -- ក្រោយឆ្នាំ៩៨។ ហើយធ្វើឲ្យខ្ញុំអាច ធ្វើឲ្យការសរសេររបស់ខ្ញុំ វាល្អ ឬក៏វាអាចប្រសើរជាងមុនបាន។

**ស៖** សូមអរគុណ លោកសាស្ត្រាចារ្យ។ សំណួរបន្តទៀត គឺថានៅពេលដែលលោកអានឯកសារ គឺដីកាដំណោះស្រាយនោះ តើលោកអានទូរជើងទំព័រទាំងអស់ ដែលមាននៅក្នុងដីកាដំណោះស្រាយ ឬមួយក៏យ៉ាងណា?

**ឆ៖** គឺមានប្រហែលជា ជើងទំព័រប្រហែលជា៦ពាន់ ដូច្នេះខ្ញុំមើលតែទៅលើផ្នែកខាងក្រោយ ហើយខ្ញុំរកឃើញទៅលើអ្វីដែលខ្ញុំបានចាប់អារម្មណ៍ គឺលិខិតទាំងអស់នោះ។ អ្វីៗទាំងអស់ វាគួរឲ្យចាប់អារម្មណ៍។ ប៉ុន្តែពេលខ្លះ គេលុបចោល ឬក៏គេបិទបាំងនូវឈ្មោះ ដូច្នេះខ្ញុំមិនអាចពិនិត្យមើលទាំងអស់បានទេ ព្រោះថា ដោយសារតែមានការកោសលុប។

ដូច្នេះនិយាយឲ្យច្បាស់ ដូច្នេះខ្ញុំចាប់អារម្មណ៍ទៅលើលិខិតចំហហ្នឹង ដែលធ្វើឡើងដោយ ខៀវ សំផន ផ្ញើទៅតុលាការ ហើយនិងការបញ្ជាក់របស់គាត់និយាយអំពីប្រវត្តិរូបរបស់គាត់ហ្នឹង។ ដូច្នេះនៅពេលដែលខ្ញុំរកឃើញឯកសារ ដែលជាលក្ខណៈសាធារណៈទាំងអស់ហ្នឹង គឺដូច្នេះខ្ញុំមិនអាចនិយាយបានថា ឯកសារណា ឬក៏ឯកសារណាបែបណានោះទេ។ ដូច្នេះ គ្រាន់តែមានឯកសារមួយចំនួនប៉ុណ្ណោះ។

ហើយនៅពេលដែលអានលោកអានឯកសារ លោកមិនអាចប្រើប្រាស់ឲ្យវា ប្រើប្រាស់ពាក្យណាមួយឲ្យពណ៌នាឲ្យបានច្បាស់លាស់លម្អិតលម្អន់នោះទេ។

[០៩:៥៤:០៦]

**ស៖** ខ្ញុំនិយាយហាក់ដូចជាច្បាស់ចំពេក ប៉ុន្តែថាតើលោកមានលទ្ធភាពចូលទៅក្នុងឯកសារដែលជាឯកសារស្រាវជ្រាវរបស់ អូ.ស៊ី.អាយ.ជេ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដែល

គេចាត់ចំណាត់ថ្នាក់ជាឯកសារសម្ងាត់ដែរឬទេ?

**ឆ៖** ខ្ញុំគិតថា ខ្ញុំមិនដែលបានអាននោះទេ។

**ស៖** ក្នុងសក្ខីកម្មកាលពីសប្តាហ៍លោកបាននិយាយអំពីសៀវភៅធំៗចំនួនបី ដែលលោកនិយាយយោងថាជាឯកសារសំខាន់សម្រាប់លោក ថាតើលោកនិយាយយោងទៅលើឯកសារ ទៅនិយាយយោងទៅលើសៀវភៅបីសំខាន់ៗហ្នឹង តើសៀវភៅអីខ្លះ?

[០៩:៥៤:៥៣]

**ឆ៖** នេះ គឺជាឯកសារដែលខ្ញុំមានជាឯកសារក្រដាសដែលគេនិយាយអំពីខ្ញុំ នៅពេលដែលគេរាយការណ៍។ សៀវភៅដែលធំជាងគេនុំងគឺ ចម្លើយសារភាព និងចំណារ ហើយឯកសារបន្ទាប់ទៀតគឺដីកាដំណោះស្រាយ និងឯកសារទី៤ ដែលខ្ញុំមិនប្រាកដនោះទេ គឺប្រហែលជាការបកប្រែនៃចម្លើយសារភាព គឺការបញ្ជូន ឬក៏ឯកសារនិយាយពីការបញ្ជូន ឬក៏ -- ប៉ុន្តែមានចម្លើយសារភាពជាច្រើនដែលខ្ញុំមិនបានពិនិត្យមើលនោះទេ គឺថាខ្ញុំរំលងទៅលើឯកសារមួយចំនួននៅក្នុងទំព័រទាំងអស់នោះ។

**ស៖** ជាសំណួរបន្ទាប់ ខ្ញុំសូមសួរថា តើលោកធ្លាប់អានឯកសារណាដែរឬទេ មុនពេលដែលលោកមុនមកផ្តល់សក្ខីកម្មនេះ -- មួយនេះ។ តើលោកធ្លាប់អានឯកសារណាមួយ ដើម្បីត្រៀមខ្លួនមកផ្តល់សក្ខីកម្មនេះដែរឬទេ?

[០៩:៥៥:៥៥]

**ឆ៖** ខ្ញុំបានអានឯកសារ ឬក៏សៀវភៅមួយចំនួនដែលខ្ញុំបានបោះពុម្ព ឬក៏ឯកសារមួយចំនួនមួយទៀតរបស់លោក ចន ខេរី ហើយខ្ញុំអានសៀវភៅខ្លះទៀត។ គឺថាវាគ្រាន់តែជាឯកសារសាធារណៈមិនមែនឯកសារសម្ងាត់នោះឡើយ។ ឯកសារមួយចំនួនអាចនឹងមិនមែនជាឯកសាររបស់តុលាការផង វាគ្រាន់តែជាអត្ថបទ ឬក៏សៀវភៅនិយាយអំពីតុលាការ ឬក៏អ្វីនោះ ព្រោះថាខ្ញុំខានយកចិត្តទុកដាក់ទៅលើបញ្ហាតុលាការនេះ អស់រយៈពេលរាប់ខែមកហើយ។

**ស៖** ដូច្នេះ ខ្ញុំសូមសួរទៅសំណួរបន្តទៀត ទាក់ទងទៅនឹងអ្វីដែលលោកបាននិយាយថា តើលោកធ្លាប់បានតាមដានដំណើរការសំណុំរឿង០០២ នេះពីមុនដែរឬទេ? ហើយប្រសិនបើតាមដាននោះ តើតាមដានដល់កម្រិតណាដែរ?

**ឆ៖** ជាទូទៅ ខ្ញុំមើលតាមសារព័ត៌មាន តាមអ៊ីម៉ែល ឬក៏តាមបុគ្គលដែលបានចូលរួម ឬក៏បុគ្គលដែលបានសួរនាំ។ ប៉ុន្តែជាទូទៅ ភាគច្រើនគឺរបាយការណ៍ ឬក៏ការរាយការណ៍របស់អ្នកសារ

ព័ត៌មាននោះឯង។ អាចមានឯកសារ ឬក៏សៀវភៅមួយចំនួន ដែលទទួលបានពីតុលាការ ឬក៏អាចដោយសារការជួបជុំគ្នាជាក្រៅផ្លូវការជាដើម។

[០៩:៥៧:១៨]

**ស៖** ពាក់ព័ន្ធទៅនឹងចំណាប់អារម្មណ៍របស់លោកជាមួយនឹង ឌុច ដែលគ្រប់ភាគីទាំងអស់នៅក្នុងតុលាការនេះស្គាល់ ឌុច ច្បាស់ ថាតើលោកចាប់អារម្មណ៍ជាមួយនឹងសក្ខីកម្មរបស់ ឌុច នៅក្នុងសំណុំរឿង០០២ នេះដែរឬទេ?

**ឆ៖** ខ្ញុំមិនប្រាកដទេ គឺខ្ញុំចាប់អារម្មណ៍គាត់ក្នុងសំណុំរឿង០០១ នោះទេ។ ព្រោះថាខ្ញុំគិតថាប្រហែលជាខ្ញុំមិនបានអានទូវសក្ខីកម្មរបស់គាត់នោះទេ។

**ស៖** តើលោកចាំថា តើលោកធ្លាប់អានអត្ថបទសារព័ត៌មាន និយាយអំពីសក្ខីកម្មរបស់ ឌុច ដែរឬទេ -- គឺសក្ខីកម្មរបស់គាត់នៅក្នុងសំណុំរឿង០០២?

**ឆ៖** ខ្ញុំអត់ដែលបានអានទេ។

[០៩:៥៨:១១]

**ស៖** តើលោកធ្លាប់ទំនាក់ទំនងជាមួយនឹងអ្នកប្រាជ្ញ ឬក៏អ្នកនិពន្ធណាមួយនៅក្នុងរបបសម័យកម្ពុជាប្រជាធិបតេយ្យដែរឬទេ? បានន័យថា តើអាចឲ្យតុលាការទាក់ទងជាមួយនឹងអ្នកនិពន្ធទាំងអស់នោះតាមរយៈអ៊ីម៉ែល ឬក៏តាមរយៈទូរស័ព្ទអី តើអាចមានដែរឬទេ?

**ឆ៖** ខ្ញុំមិនបានទទួលបានការស្នើ ឬក៏ការផ្ដល់យោបល់ថាខ្ញុំត្រូវរឹតបន្តឹង ឬក៏ត្រូវរារាំងណាមួយនោះទេមុនពេលខ្ញុំមកតុលាការនេះ។ គឺការពិតខ្ញុំគ្រាន់តែជាការរំឭកទៅលើអ្វីដែលខ្ញុំបានដឹង ដែលបានសរសេរ ហើយខ្ញុំបានជួប ឌុច -- ហើយខ្ញុំមិនបានជួប ឌុច នោះទេ។

**ស៖** ថាតើខ្ញុំមិនមែនជាការបន្ទោសថាលោកមានទំនាក់ទំនងអីនោះទេ ការពិតខ្ញុំគ្រាន់តែចង់ស្វែងរកថា តើប្រភពនៃចំណេះដឹងរបស់លោក ឬក៏ប្រភពនៃព័ត៌មានរបស់លោកហ្នឹងគឺបានមកពីណា? ហើយថាតើសក្ខីកម្មរបស់លោកហ្នឹងពឹងផ្អែកទៅលើអ្វី? ដូច្នេះអ្វីនេះគឺខ្ញុំព្យាយាមស្វែងរក មិនមែនបានន័យថាខ្ញុំចង់បន្ទោស ឬក៏ឲ្យលោកទទួលខុសត្រូវចំពោះការទំនាក់ទំនង ឬក៏ប្រាស្រ័យទាក់ទងអ្វីនោះទេ។ ដូចដែលខ្ញុំបាននិយាយរួចទៅហើយ ប្រភពសំខាន់នៃការទទួលបានចំណេះដឹងសម័យកុម្មុយនីស្ត -- សម័យកម្ពុជាប្រជាធិបតេយ្យ គឺតាមរយៈការសិក្សាទៅលើចម្លើយសារភាពនៅស-២១។ ហើយលោកបានបញ្ជាក់ពីសប្ដាហ៍មុនថា លោកជឿជាក់ថាចម្លើយសារភាពស-២១ គឺត្រូវបានគេកម្ទេចបន្ទាប់ពី

របបកម្ពុជាប្រជាធិបតេយ្យ។ តើលោកអាចពន្យល់បានដែរឬទេ ថាតើពាក្យថា "*ខល*" ដែលខ្មែរយើង ថា ការកម្ទេចសម្អាត បោសសម្អាតហ្នឹង តើវាមានន័យយ៉ាងដូចម្តេច?

[១០:០០:១៧]

**ឆ៖** ខ្ញុំពឹងផ្អែកទៅលើសក្ខីកម្ម ប្រហែលជាតាមអ្នកដែលមានចំណេះដឹងនៅក្នុងឆ្នាំ៧៩ គឺខ្ញុំអាចសួរបាន ហើយអាចធ្វើការសិក្សាទៅលើបណ្ណសារនៅទួលស្លែង លោក អ៊ឹង តុងហ៊ឹង (ស៊ីក) ដែលនៅប្រទេសបែលហ្សិក ឬក៏ដែលៗគាត់ពិភាក្សានៅក្នុងសៀវភៅរបស់គាត់នោះ ថាតើនៅពេលនុ៎ង នៅសម័យនុ៎ង គឺគេអាចអានឯកសារចម្លើយសារភាពជាច្រើន ព្រោះឯកសារសារភាពនោះគឺមានសរសេរ ដូចដែលខ្ញុំបានអានអ៊ីចឹងដែរ។ ហើយចំពោះខ្ញុំ ខ្ញុំប្រាកដថា ឯកសារទាំងអស់នោះ ដែលយើងបានស្គាល់នៅមន្ទីរស-២១ ដែលឥឡូវនេះមិននៅទីនោះទេ។ ដូច្នេះ ខ្ញុំគិតថា ពាក្យដែលប្រើប្រាស់ល្អ គឺពាក្យថា "កម្ទេច" ឬក៏ "បោសសម្អាត"។ ឧទាហរណ៍ ដូចជា នៅ យ៉ា នៅតំបន់ពាយ័ព្យ ឬក៏ដែលមានចម្លើយសារភាពជាង៤០ទំព័រ នៅក្នុងបណ្ណសារ ហើយចម្លើយសារភាពហ្នឹង គឺមានបញ្ជាក់អំពីការបញ្ចោរបស់ ឌុច ហើយនិងកិច្ចសម្ភាសន៍មួយទៀត ដែល ស្ទីវ ហេដឌ័រ ធ្វើនៅក្នុងចុងឆ្នាំ១៩៨០ ដែលនិយាយអំពីរបបកម្ពុជាប្រជាធិបតេយ្យ ហើយបានបោះពុម្ពតាំងពីយូរមកហើយនោះ គឺគោលដៅដើម្បីផ្លាស់ប្តូរនូវការយល់ឃើញរបស់មនុស្ស។ ប៉ុន្តែ ឧទាហរណ៍ ដូចជានៅក្នុងប្រទេសថៃជាដើមគឺ មានការថ្លែងរបស់មេដឹកនាំបក្សខ្ពស់ ដែលនិយាយអំពីចម្លើយសារភាពទាំងអស់នេះ។ ដូច្នេះហើយ គឺវាបញ្ជាក់នៅក្នុងការផ្តល់ចម្លើយសារភាពយ៉ាងវែងអន្លាយទាំងអស់នោះ។

[១០:០២:១១]

ខ្ញុំអាចនិយាយថា ចម្លើយសារភាពដែល ប៉ុល ពត និយាយនោះគឺចម្លើយសារភាពរបស់ យ៉ា គឺចម្លើយសារភាពរបស់ យ៉ា។ នេះគឺជាអ្វីដែល ប៉ុល ពត បាននិយាយ។ គាត់និយាយអំពីតួដ៏សំខាន់ អំពីតំបន់ពាយ័ព្យ អំពីការពាក់ព័ន្ធជាមួយវៀតណាម។ ដូច្នេះ ជាថ្មីម្តងទៀត ខ្ញុំបញ្ជាក់ថា ខ្ញុំមិនមានភស្តុតាងអ្វីទេ វាគ្រាន់តែជាការផ្អែកទៅលើចម្លើយសារភាព ដែលបង្ហាញអំពីទំនាក់ទំនងជាមួយវៀតណាម គឺថាអ្វីៗគឺវាកើតឡើងនៅពេលដែលមានការខុស ឬក៏បានន័យថា ដំណើរការវាខុសពីអ្វីដែលបានកើតឡើងទើបធ្វើឲ្យវាមានបញ្ហានៅជាមួយនឹងវៀតណាម។ ទាំងអស់នេះ ហើយគឺជាចម្លើយសារភាពមួយក្នុងចំណោមសារភាពជាច្រើននៅមន្ទីរទួលស្លែង ដែលបង្ហាញថា -- ដែលនៅសល់ពីរបបកម្ពុជាប្រជាធិប-តេយ្យ។

[១០:០៣:២២]

តាមដែលខ្ញុំដឹង គឺមានឯកសារជាច្រើនដែលមិននិយាយអំពីវៀតណាម ហើយឯកសារហ្នឹងអាចឱ្យទាំងអស់គ្នាបង្ហាញមើល អាចជាចម្លើយសារភាព អំពីការសង្ស័យ ឬក៏អំពីឯកសាររបស់បក្សកុម្មុយនីស្ត។ ខ្ញុំគិតថា នេះគឺជាចម្លើយដ៏វែង ប៉ុន្តែខ្ញុំផ្អែកទៅលើឯកសារទាំងអស់នេះ ទើបខ្ញុំនិយាយអំពីពាក្យថា ការបោសសម្អាត ការបំបាត់ចោលទាំងអស់នោះ។

**ស៖** ខ្ញុំគិតថា នេះជាចម្លើយដ៏វែងមួយ ប៉ុន្តែវាជាចម្លើយដែលលម្អិតលម្អន់ល្អណាស់។ សំណួរដំបូងរបស់ខ្ញុំ គឺមានលក្ខណៈសាមញ្ញបន្តិច ខ្ញុំគ្រាន់តែចង់ឱ្យលោកសាស្ត្រាចារ្យពន្យល់ពាក្យថា បំបាត់ចោល គឺពាក្យថា "ខល" ជាភាសាអង់គ្លេសនោះ។ ខ្ញុំសង្ឃឹមថា ប្រហែលជាមានការបកប្រែទៅជាភាសាខ្មែរ និងភាសាបារាំងឱ្យបានត្រឹមត្រូវ ទៅលើពាក្យថា "ខល" ឬក៏យើងហៅថា "បំបាត់ចោល" នោះ។

**ឆ៖** ប្រសិនបើយើងនិយាយពីខាងក្រៅបក្ស គឺមានឯកសារជាច្រើនដែលគេបង្កើត ហើយនិងជ្រើសរើសឡើង ហើយនិងធ្វើការប្រមូលផ្តុំតិចតួច ឬក៏ដកចេញនូវឯកសារណាមួយដែលគេយល់ថាមិនគួរឱ្យចាប់អារម្មណ៍។ ខ្ញុំគិតថា ដំណាក់កាល -- ការពន្យល់នេះគឺវាពន្យល់បានទាំងអស់ ទាំងទៅលើឯកសាររបស់បក្ស និងទៅលើមនុស្ស។ ដូច្នេះ នេះហើយគឺនិយាយអំពីការស្វែងរករបស់ -- ការស្វែងរកជនវៀតណាមដែល ខ្ញុំគិតថា វាជាការចាប់អារម្មណ៍មួយ។

[១០:០៥:០២]

**ស៖** នៅពេលដែលលោកនិយាយអំពីប្រធានបទមួយ លោកក៏និយាយដែរ គឺថា ភី.អ័រ.ខេ គឺបក្សកុម្មុយនីស្តកម្ពុជាទាក់ទងទៅនឹងការបំបាត់ចោល។ តើលោកអាចពន្យល់បន្ថែមបានទេ លោកនិយាយចំណុចនោះគឺទាក់ទងទៅនឹងវៀតណាម?

**ឆ៖** សារមន្ទីរទួលស្លែង ប្រល័យពូជសាសន៍ហ្នឹងត្រូវបានបង្កើតឡើងដោយវៀតណាម ហើយមានកម្ពុជាក៏បានធ្វើការនៅក្នុងបណ្ណសារនោះដែរ។ ខ្ញុំមិនច្បាស់ថា ខ្ញុំនិយាយថា ការលុបបំបាត់ចោលចម្លើយសារភាពដោយមន្ត្រីសាធារណរដ្ឋខ្មែរនោះត្រឹមត្រូវនោះទេ។ គឺថាៗវាមានការបោសសម្អាតក្នុងសម័យខ្មែរក្រហម ប៉ុន្តែមន្ត្រីសាធារណរដ្ឋកម្ពុជានោះ ប្រជាមានិតកម្ពុជានោះ គឺថាគាត់មិនបានបំបាត់ចោល ឬក៏មិនបានដកចេញនូវចម្លើយសារភាពទាំងនោះទេ។

[១០:០៦:០៨]

ក្រោយមក គឺជាដំណើរការ គឺចម្លើយសារគឺថាសំណុំទីពីរ គឺថាដែលប្រមូលបានមកពីក្រសួងការពារប្រទេស ហើយពីកន្លែងពីមន្ទីររបស់ សុន សេន នោះគឺថាជាឯកសារដ៏សំខាន់ ប្រហែលគេអាចត្រូវដកចេញ ប្រហែលជាសាធារណរដ្ឋប្រជាមានិតកម្ពុជានោះ គឺគេមិនបានបំបាត់ចោល ឬក៏ដកឯកសារហ្នឹងចេញទេ។

**ស៖** ហើយទាក់ទងទៅនឹងចំណុចនេះដែរ លោកបាននិយាយថា កងទ័ពវៀតណាមគឺថាមានការយកចិត្តទុកដាក់តាមប្រវត្តិសាស្ត្រ ហើយលោកបានឆ្លើយចំណុចមួយទៀតព្រឹកមិញនេះ តើលោកអាចពន្យល់តុលាការ ថាតើពួកវៀតណាមគេប្រុងប្រយ័ត្នក្នុងតាមប្រវត្តិសាស្ត្រដូចម្ដេច ដែលថាក្នុងការបំបាត់ ឬក៏ការដកយកឯកសារនេះចេញពីកន្លែងដើម ឬក៏បំបាត់វានោះ?

**ឆ៖** តាមប្រវត្តិសាស្ត្រ គឺថាអ្វីដែលយើងចង់ដឹងទៅលើនោះ គឺថាវៀតណាមមានទំនាក់ទំនងយូរជាមួយកម្ពុជា គឺថាអាចនឹងទាក់ទងនឹងកម្ពុជា គឺគេលក់សៀវភៅដែលសរសេរ។ ដូច្នេះចំណារផ្ទាល់ដៃនៅលើចម្លើយសារភាពនោះ គឺស -- នៅស-២១ នោះគឺថាបង្ហាញ គឺថាមានអ្នកដែលគេចាត់តាំងឱ្យពិនិត្យមើល ថាតើមានហេតុការណ៍អ្វីកើតឡើងតាមឯកសារទាំងអស់នោះ ដោយសារគេមិនយល់ច្បាស់ គេមិនយល់ច្បាស់ពីបដិវត្តន៍កម្ពុជា។ ហើយគេមិនគិតថា វាដំណើរការដូចដែលបក្សកុម្មុយនីស្តកម្ពុជាផ្សេងៗដំណើរការនោះទេ។ គេចង់ដឹងថាតើវាមានរឿងអីកើតឡើងនៅកម្ពុជា?

[១០:០៨:០៧]

គេបានរក្សាទុកឯកសារនេះ ដោយសារថាគេរក្សាទុកបណ្ណសារទូលំទូលាយ គឺគេមិនបើកឱ្យសាធារណជនមើលច្រើនទេ ក៏ប៉ុន្តែប្រសិនបើលោកមិនមានចំណេះដឹងខាងប្រវត្តិសាស្ត្រទេ ខ្ញុំគិតថាលោកអាចកំណត់ថា ប្រជាជនកម្ពុជាហ្នឹងគឺថាមិនបានដឹង។ ហើយលោកអាចនឹងយល់ថា គេបំផ្លាញឯកសារនេះ ប៉ុន្តែជាការប្រៀបធៀប ប៉ុន្តែចាប់ពីសម័យ ប៉ុល ពត -- អ៎ សម័យអ៊ុកតាក់មកគឺថាគេមើលស្ថានភាពមួយចំនួន គេពិភាក្សានៅក្នុងរដ្ឋសភា ហើយកត់ត្រាហើយក៏បានចងជាឯកសារទុក គឺសម្រាប់អ្នកណាដែលចាប់អារម្មណ៍ទាក់ទងទៅនឹងប្រវត្តិសាស្ត្រ។ នេះគឺជាចំណុចដែលថាការវិវឌ្ឍន៍នៃឯកសារទៅតាមប្រវត្តិសាស្ត្រ។ បាទនេះជាផ្នែកមួយដែលគេទុកសម្រាប់កំណត់ត្រារបស់គេ។

**ស៖** សូមអរគុណដែលលោកបានឆ្លើយ។ ទាក់ទងទៅប្រធានបទនេះដែរ ខ្ញុំចង់បង្ហាញលោកសេចក្ដីដកស្រង់ចេញពីសៀវភៅរបស់លោក ដែលមានចំណងជើងថា “សំឡេងពីស-២១” ឯកសារ D108/39/2 ហើយអង់គ្លេស ERN 00192667 រហូត 23 -- អ៎ 32, ខ្មែរ ERN 00191816 រហូត

ដល់ 88, បារាំង ERN 00357247 រហូតដល់ 451។

**លោក ហ្សាស្តេ ប៉ោ៖**

ទំព័រដែលខ្ញុំចង់និយាយនោះ គឺទំព័រទី៩ សូមអនុញ្ញាតលោកប្រធានដើម្បីបង្ហាញនៅលើអេក្រង់ផងដែរ។

[១០:១០:០០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមន្ត្រីជំនួយការបង្ហាញឯកសារនៅលើអេក្រង់ទូរទស្សន៍ និងអាចបង្ហាញនៅលើអេក្រង់កុំព្យូទ័រ និងទូរទស្សន៍ទាំងពីរផង។

**លោក ហ្សាស្តេ ប៉ោ៖**

ខ្ញុំមានឯកសារលើក្រដាសហើយភាសាអង់គ្លេស ហើយនិងជូនទៅលោកសាស្ត្រាចារ្យ ឆេនដ័ល័រ ហើយនិងខ្ញុំនឹងអាចជូន ថាតើលោកចង់បានឯកសារលើក្រដាសទេ? ឬក៏ខ្ញុំចង់ឲ្យលោក -- ឲ្យខ្ញុំអានជូនលោកស្តាប់?

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារក្រដាសពីមេធាវី ដើម្បីជូនទៅលោកអ្នកជំនាញដើម្បីពិនិត្យ។

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**ស៖** ខ្ញុំនឹងអានសេចក្តីដកស្រង់ដែលពាក់ព័ន្ធជូនលោកស្តាប់ ដើម្បីឲ្យសាធារណជនបានស្តាប់ឮផងដែរ។ សូមដកស្រង់ចេញពីសៀវភៅស្នាដៃរបស់លោក។ "ការបកស្រាយរបស់កម្ពុជាទៅលើ -- កម្ពុជាទាក់ទងទៅនឹងក្របខ័ណ្ឌមួយចំនួន ដែលថាជាប្រវត្តិសាស្ត្រដ៏ខ្សោយ ប៉ុន្តែប្រជាជនដែលរស់នៅពិតជាចងចាំយ៉ាងច្រើនឥតខ្ចោះ។ ហើយអ្នកជំនាញបារាំងដែលបានធ្វើការនៅ ធីហ្គែល នៅក្នុងប្រទេសថៃ នៅឆ្នាំ១ ១៩៨០ ដែលអនុញ្ញាតមិនឲ្យយើងសួរ -- ឆ្លើយនូវសំណួរជាច្រើន។ នៅក្នុងករណីនេះគឺតំណាង ដែលហៅថា ខ្មែរក្រហម ថាជាក្រុមដែលអនុវត្តនូវនយោបាយគឺជាបិសាច គឺដូចបំផ្លាញជនជាតិខ្មែរ ហើយបង្កនូវបាតុភាពមួយដែលធ្វើឲ្យប្រជាជនមិនមានការពេញចិត្តនោះ តែពេញចិត្តខ្លួនឯង"។

[១០:១២:០៩]

ដូច្នេះខ្ញុំ នៅក្នុងសំណួរនេះ គឺនៅក្នុងក្របខ័ណ្ឌដែលថាសាធារណរដ្ឋប្រជាមានិតកម្ពុជានោះបាន ធ្វើការច្រើន ដើម្បីវែកមុខ ឬក៏រកឲ្យឃើញអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលកើតឡើងឆ្នាំ១៩៧៥ ដល់១៩៧៩។ នៅពេលដែលរដ្ឋាភិបាលពឹងផ្អែកទៅលើអង្គហេតុដែលថា គេផ្តួលរបបខ្មែរក្រហមនោះ គឺគេបានផ្តន្ទាទោសចលនានោះ ហើយនៅតែមេដឹកនាំខ្មែរក្រហមធំៗរស់នៅធ្វើការជារហូតៗទាល់តែ គេបានភៀសខ្លួនទៅប្រទេសវៀតណាម ឆ្នាំ១៩៧៧, ៧៨ នោះ។ អានោះ ដកស្រង់នៅក្នុងនេះ នៅក្នុង ក្របខ័ណ្ឌមួយ គឺថាសាធារណរដ្ឋប្រជាមានិតកម្ពុជា គឺបានធ្វើការយ៉ាងខ្លាំងដើម្បីបំបាត់នូវរបបប្រល័យ ពូជសាសន៍ គឺថាដែលគេបានមកកាន់អំណាចចាប់ពីឆ្នាំ១៩៧៩ មក។ តើលោកអាចពន្យល់ប្រាប់យើង ដែរទេ ថារបបកម្ពុជាប្រជា -- របបសាធារណរដ្ឋប្រជាមានិតកម្ពុជាធ្វើការខ្លាំងដើម្បីពិនិត្យមើលឧក្រិដ្ឋ កម្មដែលកន្លងមកនោះ តើលោកអាចពន្យល់បានដូចម្តេច?

[១០:១៣:៣៩]

**លោក ដេវីដ ឆេនឌ័ល័រ៖**

**ឆ៖** សូមអរគុណ។ តាមពិតនៅក្នុងការជំនុំជម្រះ ប៉ុល ពត និង អៀង សារី ពីរឿងឧក្រិដ្ឋកម្ម ប្រល័យពូជសាសន៍ហ្នឹង ធ្វើឡើងនៅឆ្នាំ១៩៧៩ នៅក្នុងសៀវភៅនិយាយអំពីសៀវភៅសិក្សាដើម ទសវត្សរ៍ឆ្នាំ១៩៨០ ហើយនិងក៏មានការបង្កើតជាទិវាចងកំហឹង នៅថ្ងៃឧសភា ទី៨ ហ្នឹងហើយ ក្រោយ មកគេបង្កើតនូវសារមន្ទីរប្រល័យពូជសាសន៍។ នេះហើយ ជាការងារមួយដែលអាចនឹងបង្ហាញថាមេដឹក នាំសាធារណរដ្ឋប្រជាមានិតកម្ពុជាក៏បានធ្វើការងារនេះ ហើយដើម្បីពិនិត្យមើលនូវក្រុមមនុស្សមួយចំនួន ដែលប្រព្រឹត្តនូវអំពើអាក្រក់។ ខ្ញុំប្រើនៅក្នុងសេចក្តីដកស្រង់ គឺមាន ប៉ុល ពត និង អៀង សារី ដែល គេកាត់ទោសនោះ។ ជាពិសេសទាក់ទងទៅនឹងមេដឹកនាំនោះ ហើយនេះជាគំនិតដែលយើងគិត ខ្ញុំមិន ចង់បន្ទោសទៅអ្នកទាំងហ្នឹងនោះទេ។ ហើយយើងមិនចង់ចោទថា អ្នកណាជាអ្នកទទួលខុសត្រូវលើអ្វី ទាំងអស់ ចំពោះអ្វីៗកើតឡើងនោះទេ។

[១០:១៤:៥១]

យើងនិយាយថា សម័យ ប៉ុល ពត គឺថាអ្វីៗដែលកើតឡើងនៅក្នុងសម័យនោះ គឺរបបហ្នឹងជា អ្នកទទួលខុសត្រូវ ហើយយើងនិយាយអំពីស្ថាប័ន គេបានប្រឹងប្រែង ដើម្បីឲ្យមានការចងក្រងនូវប្រវត្តិ- សាស្ត្រទាក់ទងទៅនឹងមនុស្សមេដឹកនាំមួយចំនួន ដែលថា គេចាត់ទុកថាជាបិសាច នៃរបបនោះ។ ហើយវាស្ថិតនៅ -- ថាមិនមានអត្ថន័យចំពោះប្រជាជនសាមញ្ញធម្មតាទេ ចំពោះអ្វីដែលគេធ្វើនោះ”។

សំណួរទាក់ទងទៅនឹងចំណុចនេះដែរ លោកបានសរសេរនូវចំណុចផ្សេងទៀត អំពីការរៀបរាប់ ឬក៏ដ៏មានឥទ្ធិពលរបស់សម័យខ្មែរក្រហម គឺថា ជាចារឹដ៏អាក្រក់ ដែលសម្លាប់ប្រជាជនច្រើនលាន ជាអ្នករងគ្រោះនោះច្រើនលាន។ អ៊ីចឹងការរៀបរាប់នេះគឺបង្កើតឡើងនៅក្នុង -- ដែលគេប្រកាន់យក នៅក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ហើយគេនៅតែប្រកាន់ថា គំនិតហ្នឹងវាត្រឹមត្រូវរហូតដល់ពេលនេះដែរឬទេ?

**ឆ៖** មិនដូច្នោះទេ។ ហើយយើងបានព្យាយាម ដើម្បីយល់ថាតើមានអ្វីកើតមានឡើង។ ហើយការយល់ឃើញនេះ គឺជាបេសកកម្មរបស់តុលាការនេះ ដែលសហព្រះរាជអាជ្ញា ហើយសាក្សីចង់ដឹងតើចង់រកឃើញថា វាយ៉ាងដូចម្ដេច។ យើងអាចនិយាយដោយមិនសង្ស័យហ្នឹង គឺថាមិនមែន ៗជាការសម្លាប់មនុស្សម្នាក់ ឬពីរនាក់ ដែលចាត់ទុកថាជាប្រល័យពូជសាសន៍នោះទេ។ នេះគឺជាប្រវត្តិសាស្ត្រ ខ្ញុំមិនទាក់ទងទៅអ្វីដែលយើងធ្វើនោះទេ។

[១០:១៦:៥៤]

នៅទីនោះ ប្រហែលថាវាផ្ទុយពីការងារដ៏ល្អរបស់តុលាការនោះហើយ។

**ស៖** ប្រសិនយើងត្រឡប់ទៅរកការសិក្សាស្រាវជ្រាវរបស់លោកពីមុន អំពីឯកសារកម្ពុជាប្រជាធិបតេយ្យនោះ គឺថា តើលោកទុកចិត្តទេថា សាធារណរដ្ឋប្រជាមានិតកម្ពុជា ហើយវៀតណាមមិនបំផ្លាញ ឬក៏មិនបំបាត់ចោលនូវឯកសារទាំងនេះ ដើម្បីៗទុកបញ្ជាក់អំពីបទឧក្រិដ្ឋកម្មរបស់ជនដែលគេហៅថា បិសាចឧក្រិដ្ឋជនដ៏សំខាន់ តាមន័យរបស់គេនោះ?

**ឆ៖** ដើម្បីឆ្លើយ ប្រសិនគេធ្វើដូច្នេះមិន គឺថា មិន -- ពួកគេមិនបានធ្វើការងារល្អទេ បើផ្អែកតាមឯកសារ គឺថា ឯកសាររាប់ពាន់ គឺនោះហើយដែលសាលាក្ដីនេះប្រមូលបាន គេមិនអាចបន្ថែមអ្វីនោះទេ គឺថា គេមិនអាចប្រឌិតទេ។

**ស៖** ប្រហែលលោក -- សំណួរខ្ញុំមិនច្បាស់ចំពោះលោក។ ប៉ុន្តែអ្វីដែលខ្ញុំចង់សួរ សួរលោកថាតើលោកគិតថា វៀតណាមបានបំប្លែងភស្តុតាង តាមវិធីមួយ ដោយគេយកឯកសារមួយចំនួនចេញ ជាឯកសាររបស់កម្ពុជាប្រជាធិបតេយ្យនោះ ដែលអាចឆ្លុះបញ្ចាំងថា បង្ហាញពីតួនាទីមិនសូមសំខាន់របស់មេដឹកនាំនៅថ្នាក់កំពូលហ្នឹងដែរឬទេ?

[១០:១៨:៣១]

**ឆ៖** គឺថា យើងមិនមានភស្តុតាងអីបញ្ជាក់ថាអ៊ីចឹងទេ។ ប៉ុន្តែអ្វីដែលបានផ្ដល់សក្ខីកម្មដើម

សប្តាហ៍នេះគឺថា គឺកិច្ចប្រជុំរបស់គណៈមជ្ឈិម គឺថាគេប្រជុំរៀងរាល់សប្តាហ៍ ហើយយើងមានៗ ឯកសារហ្នឹងគឺថា ប្រាំបួន ឬ១៥ គឺថាមានឯកសារក្នុង១៥នេះ យើងនៅសល់តែប្រាំបួនទេ ដែលបញ្ជាក់ពីការប្រជុំនោះ។ ដូច្នេះហើយគឺមានឯកសារមួយចំនួននោះបង់បាត់។ អ្នកខ្លះនឹកឃើញថា ចម្លើយរបស់ ឌុច នោះគឺថា នៅក្នុងបទសម្ភាសន៍នោះគឺថា នួន ជា នៅក្នុងទសវត្សរ៍ឆ្នាំ៨០ ហ្នឹង គឺថាបានមកជួបឌុចថាហេតុអីក៏ឌុចឯងមិនដុតបំផ្លាញឯកសារចោល? នេះហើយគឺជាវិធីដែលគេចង់បំផ្លាញឯកសារ។ ខ្ញុំមិនមានភស្តុតាងអី ដែលថាសាធារណរដ្ឋប្រជាមានិតកម្ពុជា ឬក៏កងទ័ពវៀតណាមបានបំផ្លាញឯកសារនោះចោលទេ។ ព្រោះបើយើងមើលឯកសារ គឺថាពេលខ្លះ គឺថាពេលខ្លះ គឺយើងឃើញថាឃើញថា អង្គហេតុថាមានកិច្ចប្រជុំ ឬមិនពិធីអី ប៉ុន្តែមិនមានឯកសារបញ្ជាក់។ អាហ្នឹងគឺថា យើងអាចថាបាត់ឯកសារហ្នឹង។

**ស៖** ទាក់ទងទៅនឹងបញ្ហានេះ យើងបាននិយាយអំពីការជំនុំជម្រះនៅឆ្នាំ១៩៧៩ កាត់ទោសលោក អៀង សារី និងលោក ប៉ុល ពត។ តើផ្អែកលើការសិក្សាស្រាវជ្រាវរបស់លោក ថាតើការប្រមូលភស្តុតាងសម្រាប់ការជំនុំជម្រះហ្នឹងដូចម្តេចដែរ?

[១០:២០:០៥]

**ឆ៖** នេះជាសំណួរល្អ ចម្លើយរបស់សាក្សីមួយចំនួននៅក្នុងការជំនុំជម្រះនោះគឺថា នៅតែមានរហូតដល់ថ្ងៃនេះ។ ចម្លើយរបស់ ដេនីឌី ហ្វ្រង់សូ នោះគឺថា ខ្ញុំបានជួបគាត់ពីរដងនៅទីក្រុងប៉ារីស។ ការចងចាំរបស់គាត់ គឺផ្ទុះបញ្ចាំងអ្វីដែលលោកបាននិយាយនៅក្នុងតុលាការ គឺថាជាដីកាចោទប្រកាន់ដ៏ធ្ងន់មួយទៅលើជនជាប់នោះ គឺថានោះហើយនៅក្នុងរបៀបដែលគេប្រមូលភស្តុតាង និងសក្ខីកម្ម ហើយក៏បានបង្ហាញអំពីអំពើរន្ធត់នៅក្នុងសម័យនោះ គឺថាសាក្សីក៏បានកោះហៅ ហើយកោះហៅគេបាននិយាយចេញពីដួងចិត្តរបស់គេនូវការពិត នូវអង្គហេតុពិតដែរ សាក្សីនៅកាលនោះ។ នៅពេលដែលការជំនុំជម្រះនោះមិនទាក់ទាញមតិអន្តរជាតិឲ្យចាប់អារម្មណ៍នៅកាលនោះ គឺហៅថា គឺជា គេហៅជា "*ខេនហ្គូ ខត*" គឺជាតុលាការបង្កើតដោយក្រុមអ្នកនយោបាយ។

[១០:២១:០៩]

ការហៅបែបនេះ គឺថាធ្វើឲ្យការងាររបស់យើងមានការលំបាក គឺថាធ្វើឲ្យ ប៉ុល ពត និង អៀង សារី គឺថាអ្នកដែលកាត់ទោសគេហ្នឹង គឺថាសុទ្ធតែជាអ្នកនយោបាយ។ ហើយមេធាវីរបស់គាត់នោះមិនបានការពារពួកគាត់ទេ។ ប៉ុន្តែគឺថា សូមឲ្យតុលាការកាត់ទោសគាត់ទៅ។ នេះហើយ ជាអ្វីបានដែល

កើតឡើង។ ហើយសាក្សីដ៏ល្អដែលបានបង្ហាញហ្នឹង គឺថាអ្នកខ្លះអាចនឹងមកបង្ហាញខ្លួននៅទីនេះទៀត ហើយនឹងអាចលើកឡើងអំពីថាអ្វីដែលបានកើតឡើងចំពោះគេ។ នេះហើយគឺថាតម្លៃរបស់ គឺថាក្នុងឆ្នាំ ១៩៧៩ ដែលថាមួយឆ្នាំក្រោយពីរបបហ្នឹងដួល។ អ៊ីចឹងហើយនៅពេលសាក្សីនៅចាំអ្វីៗបានច្រើន មិនស្រពេចស្រពិលទេ។ ដូច្នេះហើយ សក្ខីកម្ម និងភស្តុតាងដ៏មានតម្លៃហ្នឹង គឺថាវាមានតម្លៃ ប៉ុន្តែទម្រង់នៃការជំនុំជម្រះហ្នឹង គឺថាអាចធ្វើឲ្យគេយល់ថាចម្លែក។

[១០:២២:១៥]

**ស៖** សូមអរគុណដែលលោកបានឆ្លើយពិស្តារ។ ខ្ញុំសូមអនុញ្ញាតចូលទៅខាងមុខបន្តិចទៀតនិយាយអំពី -- ឥឡូវនេះគឺឃ្លាតឆ្ងាយពីប្រភពនៃការប្រមូលចំណេះដឹងរបស់លោក ការយល់ដឹងរបស់លោក ប៉ុន្តែខ្ញុំនិយាយអំពីការទម្លាក់គ្រាប់បែករបស់អាមេរិកាំងនៅក្នុងប្រទេសកម្ពុជា។ ខ្ញុំមិនផ្តល់ព័ត៌មានច្រើនពីនេះពេកទេ។ ឥឡូវនេះ ខ្ញុំចង់សួរលោក តើលោកអាចប្រាប់ខ្ញុំដោយសង្ខេប ប្រហែលជាពីរនាទី អំពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកនៅកម្ពុជា ដែលកើតឡើងនៅក្នុងឆ្នាំ១៩៧០ ឬក៏បន្ទាប់មកទៀតនោះ ឬក៏មុនឆ្នាំ៧០នោះ?

**ឆ៖** ខ្ញុំរីករាយ បើសិនជាតុលាការអនុញ្ញាត។ បើសិនជាក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ពេលខ្លះមានទម្លាក់ ពេលខ្លះអត់។ បើសិនតុលាការអនុញ្ញាត ខ្ញុំនឹងឆ្លើយ។ ខ្ញុំមិនចង់និយាយដកថយទៅឆ្លើយនៅឆ្នាំ ១៩៦០, ៧០ ដែលថាវាឆ្ងាយពេក។ ខ្ញុំមិនព្យាយាមចៀសវាងទេ ប៉ុន្តែខ្ញុំសូមជម្រាបតុលាការថា តើអនុញ្ញាតឲ្យខ្ញុំឆ្លើយឬអត់?

**ស៖** សំណួរនេះ គឺចង់ឲ្យលោកយល់ ឲ្យតុលាការយល់ពីបរិបទអ្វីៗនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

[១០:២៤:០០]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:២៥:១៤]

**ប្រធានអង្គជំនុំ៖**

បាទ សូមអ្នកជំនាញឆ្លើយតបទៅនឹងសំណួរដែលសួរអម្បាញ់មិញនេះ ដោយមេធាវីអន្តរជាតិការពារក្តីលោក នួន ជា។ ហើយសូមឆ្លើយដោយសង្ខេបបានហើយ។ ហើយក្នុងនាមលោកជាអ្នកជំនាញខាងប្រវត្តិវិទូ។ សូមអញ្ជើញ!

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** សូមអរគុណលោកប្រធាន។ ហើយខ្ញុំរីករាយនឹងឆ្លើយ។ ក្នុងឋានៈជាពលរដ្ឋអាមេរិក ហើយខ្ញុំមានសញ្ជាតិពីរ ហើយខ្ញុំជាបញ្ញវន្តអ្នកសរសេរនៅកម្ពុជាទសវត្សរ៍ឆ្នាំ១៩៧០នោះ ខ្ញុំដឹងថាមានការទម្លាក់គ្រាប់បែកដោយសហរដ្ឋអាមេរិក គឺមានគ្រាប់បែកជាច្រើនត្រូវបានទម្លាក់។ ពេលនោះអាមេរិកាំងមិនបានធ្វើសង្គ្រាមទេ។ ហើយខ្ញុំបានអានជាច្រើនដែលខ្ញុំគិតឃើញថា ជាសម័យកាលដ៏ខ្មៅងងឹត ដែលប្រព្រឹត្តនៅបរទេស។ ហើយខ្ញុំសូមជម្រាបថា ក្នុងបរិបទនេះខ្ញុំជាពលរដ្ឋអាមេរិកាំងស្មោះត្រង់នឹងប្រទេស ខ្ញុំមិនបោះបង់ទេ។ ខ្ញុំយល់ថា នេះជាអំពើមួយមិនល្អទេ ដែលអាចអាមេរិកប្រព្រឹត្តនៅក្រៅប្រទេសបែបនេះ។

[១០:២៦:៣៧]

ផលប៉ះពាល់នៃការទម្លាក់គ្រាប់បែកទៅលើចលនាខ្មែរក្រហមនោះ គេបានពិភាក្សាយ៉ាងលម្អិតនេះគឺថាជាមានទស្សនៈផ្ទុយគ្នាយ៉ាងច្រើនដែលថា គ្រាប់បែកហ្នឹងគឺធ្វើឲ្យប្រជាជនខ្មែរចូលខ្មែរក្រហមឬក៏ឲ្យគេរត់ជៀសមកភ្នំពេញ? ក្នុងករណីពីរនេះ គឺថាគេពិភាក្សានៅក្នុងបទសម្ភាសន៍នៅក្នុងឆ្នាំ១៩៨០ គឺថាមិនមានព័ត៌មានផ្ទៀងផ្ទាត់ទេ ប៉ុន្តែ ខៀវ សំផន មិនធ្វើអ្វីឲ្យគេបានប្រសើរឡើងទេ គឺកងទ័ពរបស់គេនៅរឹងមាំ។ គឺថាកងទ័ពមិនទទួលការរងគ្រោះហ្នឹងទេ នេះជាសម្តីរបស់ ខៀវ សំផន គឺខ្មែរក្រហមកងទ័ពរបស់គេនៅខ្លាំងដដែល។ ហើយយើងមិនដឹងអំពីចំនួនមនុស្សស្លាប់ និងរបួសទេនៅក្នុងខាងកងទ័ពខ្មែរក្រហម។

យើងដឹងថាសមត្ថភាពរបស់គេក្នុងការដណ្តើមយកភ្នំពេញ គឺថាពន្យារពេលបានពីរឆ្នាំ។ ហើយរីឯក្រសួងការបរទេសរបស់អាមេរិកមួយចំនួនគឺថាគេប្រឆាំង គឺថាគេអាចយល់ថាបើនៅតែទម្លាក់ គឺថាអាចនឹងធ្វើឲ្យកុម្មុយនីស្តអាចដណ្តើមប្រទេសវៀតណាម ឬក៏ស្រុកខ្មែរបាន។ ដូច្នេះមានការពន្យល់ជាយុទ្ធសាស្ត្រនៅទីក្រុងវ៉ាស៊ីនតោន ហើយខ្ញុំ -- អ្វីដែលជាយោបល់របស់ខ្ញុំហ្នឹងគឺថា ជាសម័យកាលដ៏គួរឲ្យខ្មាសអៀនរបស់ប្រវត្តិសាស្ត្រ របស់សហរដ្ឋអាមេរិក។ មិនមែនប្រវត្តិសាស្ត្រសម្រាប់អាមេរិកាំងនោះទេ គឺថាសម្រាប់កម្ពុជាក៏ដូច្នេះដែរ ដែលត្រូវរងគ្រោះនោះបាទ។

[១០:២៨:២៤]

**ស៖** សូមអរគុណ។ ដែលលោកនិយាយថាឆ្នាំ១៩៧៣ លោកបានចាប់ផ្តើមសរសេរ ហើយលោកបានពិនិត្យមើល។ ហើយខ្ញុំមិនចំណាយពេលច្រើនទេ តើនៅក្នុងឆ្នាំ១៩៧៣ មានតែឆ្នាំហ្នឹងទេ

ដែលទម្លាក់គ្រាប់បែក ឬក៏មានឆ្នាំផ្សេងមុនហ្នឹងទៀត ឬក្រោយហ្នឹងទៀត?

**ឆ៖** អត់ទេ ខ្ញុំមិនចង់បញ្ជាក់ថាឆ្នាំ១៩៧៣ហ្នឹង គឺជាឆ្នាំដែលទម្លាក់ច្រើនជាងគេ ដែលថាតំបន់មួយចំនួនដែលថាមិនមានវត្តមានយោធានោះ គឺថាត្រូវបានបញ្ឈប់នេះគឺជាការដាក់វិន័យចំពោះការទម្លាក់គ្រាប់បែកមួយចំនួននៅតំបន់គ្មានយោធា ដូចជានៅឆ្នាំ១៩៦០ នៅតំបន់វៀតណាមជាដើម។ ៦៧, ៦៨ នោះគឺថាអាចទម្លាក់គ្រាប់បែកនោះឆ្លងព្រំដែនបន្តិច។ ប៉ុន្តែមានយុទ្ធនាការយ៉ាងខ្លាំងអំពីការទម្លាក់គ្រាប់បែកហ្នឹងក្នុងឆ្នាំ១៩៧៣។ នៅមានការចុះហត្ថលេខាលើបទឈប់បាញ់គ្នារវាងវៀតណាម និងសហរដ្ឋអាមេរិក ប៉ុន្តែខ្មែរក្រហមមិនព្រមចុះហត្ថលេខា។ កម្ពុជាគឺជា -- គឺមានសង្គ្រាមតែក្នុងស្រុកទេ។ ដូច្នេះហើយគឺបទឈប់បាញ់គ្នានោះគឺមិនទាក់ទងនឹងកម្ពុជាទេ។ ហើយនេះជាចំណុចដែលគួរឲ្យចាប់អារម្មណ៍ ហើយទាក់ទងទៅនឹងវៀតណាម និងសហរដ្ឋអាមេរិក ហើយឆ្នាំ១៩៧៣ ហ្នឹងគឺជាឆ្នាំដែលគេទម្លាក់គ្រាប់បែកច្រើនជាងគេ នៅពេលដែលៗវាមានការទាក់ទងទៅនឹងសង្គ្រាមនៅវៀតណាម។ ហើយជាការទម្លាក់គ្រាប់បែក ឬជម្លោះដោយមូលហេតុអ្វីសមហេតុសមផលរវាងកម្ពុជា និងសហរដ្ឋអាមេរិកនោះ។

**ស៖** សូមអរគុណលោកអ្នកជំនាញ។ នៅពេលដែលលោកឈប់សរសេរសៀវភៅហ្នឹងឆ្នាំ ១៩៨០ ហើយលោកបានសិក្សា ហើយលោកបានជួបឯកសារអ្វីថ្មី ទាក់ទងទៅនឹងការទម្លាក់គ្រាប់បែកហ្នឹងដែរឬទេ ដែលប្រាប់ព័ត៌មានបន្ថែមដល់លោកនោះ?

[១០:៣០:៥៥]

**ឆ៖** តាមពិត ឯកសារដែលបានបោះពុម្ពផ្សាយនេះ គឺជាការបោះពុម្ពផ្សាយដ៏ចម្លែករបស់អ្នកកាសែតកាណាដា គឺដូចឯកសារដែល ប៊ែន ឃៀរនិន បានទទួលបាន។ នៅពេលដែលឯកសារចេញនោះគឺថា អាចបង្កើនចំនួន អំ បង្ហាញចំនួនគ្រាប់បែកដែលទម្លាក់នោះគឺថា ហេតុអ្វីបានជាមិន -- ខ្ញុំចម្លែកដែលថាមិនបានបញ្ជូនទៅអ្នកដែលមានជំនាញខាងវិភាគនោះ គឺថាវាអាចតួលេខហ្នឹងគឺដាក់បញ្ចូលនោះ។ ខ្ញុំមិនអាចថា ពិត ឬមិនពិតទេ ខ្ញុំឋានៈជាបញ្ញវន្តនោះ ខ្ញុំមិនគិតថា តួលេខហ្នឹងមិនគួរឲ្យសាធារណជនបានឃើញ មិនទាន់បានពិនិត្យផ្ទៀងផ្ទាត់ត្រឹមត្រូវនោះទេ។ វាត្រូវតែឆ្លងការពិនិត្យរបស់សារព័ត៌មានដ៏ត្រឹមត្រូវ។ ប៉ុន្តែបើតាមធម្មតា គេមិនគួរផ្សាយព័ត៌មានពីចំនួននេះមិនមុនទេ ក្រោយពី -- លុះត្រាតែមានការពិនិត្យផ្ទៀងផ្ទាត់ ទោះបីជាពិត ប៉ុន្តែវាអាចពិត ប៉ុន្តែគឺថា គ្រាប់បែករាប់ពាន់តោនច្រើនជាងចំនួនដែលអាមេរិកគេប្រកាសនោះ នៅក្នុងកាសែតដែលគេចុះនេះបាទ។

[១០:៣២:១១]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី អរគុណលោកអ្នកជំនាញ។ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលនូវកន្លែងសម្រាក នៅបន្ទប់សម្រាកសម្រាប់សាក្សីនិងអ្នកជំនាញដល់ជំនាញ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មវិញ នៅវេលាម៉ោងដប់មួយខ្វះដប់នាទី។

សម្រាកចុះ!

[១០:៣២:៤៨]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣២ នាទី ដល់ម៉ោង ១០:៥២នាទី)*

[១០:៥២:៤០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយនិងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។ សូមអញ្ជើញ!

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

**ស៖** លោកសាស្ត្រាចារ្យ មុនពេលដែលយើងឈប់សម្រាក គឺយើងបាននិយាយអំពីការទម្លាក់គ្រាប់បែករបស់អាមេរិក ហើយលោកបានផ្តល់ព័ត៌មានមួយចំនួនពាក់ព័ន្ធទៅនឹងការទម្លាក់គ្រាប់នេះ។ ប៉ុន្តែនៅក្នុងសៀវភៅ “បងទី១” របស់លោក លោកបានបញ្ជាក់ថា ហើយខ្ញុំនឹងបង្ហាញនៅលើអេក្រង់

ប្រសិនបើអនុញ្ញាត។ ប៉ុន្តែខ្ញុំសូមគ្រាន់តែធ្វើការបកស្រាយ ហើយលោកអាចធ្វើការបកស្រាយ។

“ការធ្វើយុទ្ធនាការទម្លាក់គ្រប់បែកហ្នឹងគឺមានជោគជ័យតែនៅខាងជនបទប៉ុណ្ណោះ។ គឺថានៅពេលដែលកម្ពុជាមិនមានការរៀបចំឲ្យគ្រប់គ្រាន់ដើម្បីទប់ទល់ ធ្វើឲ្យវាមានគ្រោះថ្នាក់យ៉ាងធំធេង”។ ហើយលោកបន្ទាប់មកទៀត -- ដូច្នេះជាដំបូង ខ្ញុំសូមឲ្យលោកធ្វើការឆ្លើយតបសិន ថាតើលោកមានបានស្រាវជ្រាវ ឬក៏សួរនាំអំពីឥទ្ធិពល ឬក៏ផលប៉ះពាល់នៃការទម្លាក់គ្រាប់បែកមកលើសង្គមកម្ពុជាទាំងមូលដែរឬទេ?

[១០:៥៤:១៦]

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** ការពិតទៅប្រើសិនបើ ខ្ញុំចង់និយាយ គឺខ្ញុំគាំទ្រ ឬក៏ខ្ញុំប្រកាន់ជំហរទៅលើអ្វីដែលខ្ញុំបានសរសេរ។ គឺថានៅពេលនោះ គឺខ្ញុំត្រឡប់មកប្រទេសកម្ពុជាជាច្រើនដង ហើយខ្ញុំប្រាកដថាផលប៉ះពាល់ទៅលើតំបន់ជនបទគឺមានលក្ខណៈថាជាគ្រោះមហន្តរាយដ៏ធំធេង។ ប៉ុន្តែ វាហាក់ដូចជាមិនមានអ្វីដែលនោះទេ ដោយវាផ្អែកទៅលើការផ្តល់ចម្លើយ វាគ្រាន់តែជាការភ្ញាក់ផ្អើល។ ការពិតវាមានការទម្លាក់នៅលើតំបន់ដែលគ្មានមនុស្ស និងតំបន់ដែលមានមនុស្សផងដែរ។ ហើយមានរបាយការណ៍ជាច្រើនដែលនិយាយអំពីការដាក់ទណ្ឌកម្មដែលៗគេទម្លាក់ទៅលើ ប-៥២ គឺទម្លាក់នៅគ្រាប់បែក បេ-៥២ ជាដើម។ ទោះបីយ៉ាងណាក៏ដោយ ខ្ញុំនៅគាំទ្រអ្វីដែលខ្ញុំបានសរសេរ ប៉ុន្តែអាចថារយៈពេលក្រោយ ២០-៣០ឆ្នាំមក គេអាចនិយាយដោយងាយថា វាមានគ្រោះថ្នាក់ដ៏ធំធេង វាមានគ្រោះថ្នាក់ដ៏ខ្លាំងក្លា គឺថាភូមិត្រូវបានបំផ្លាញ ប្រជាជនត្រូវបានសម្លាប់។ ដូច្នេះ ផលប៉ះពាល់សំខាន់នៃការទម្លាប់គ្រាប់បែកហ្នឹងគឺៗបង្ខំឲ្យប្រជាជនពីជនបទរត់ចូលមកទីក្រុងភ្នំពេញ ឬក៏តំបន់ជុំវិញទីក្រុងភ្នំពេញ។

ប្រសិនបើយើងមើលផែនទីនៃការទម្លាក់គ្រាប់បែកហ្នឹងគឺវាមាននៅក្នុងសៀវភៅ *ហ្សូកា* ដែលបង្ហាញអំពីរង្វង់ ឬអំពីក្រុមនៃមនុស្សដែលភៀសខ្លួនមកជុំវិញ មកនៅតំបន់ទីក្រុងភ្នំពេញ។ ដូច្នេះវាមិនមែនមានតែអ្នកធ្វើបដិវត្តន៍នោះទេ សូម្បីតែយុវជន យុវនារីក្មេងៗដែលទទួលផលប៉ះពាល់ពីគ្រាប់បែកហ្នឹងក៏មានហេតុផលដើម្បីឲ្យពួកគាត់ចូលជាមួយនឹងក្រុមខ្មែរក្រហមផងដែរ។ ប៉ុន្តែខ្ញុំមិនអាចបញ្ជាក់ថាតើការជ្រើសរើស ឬការចូលរួមនោះវាមានចំនួនប៉ុន្មាននាក់ច្បាស់លាស់នោះទេ។

[១០:៥៦:២៦]

**ស៖** សូមទោសលោកសាស្ត្រាចារ្យ ខ្ញុំសូមរំខានបន្តិច ខ្ញុំសូមកាត់បន្តិចទៅចុះ។ ការពិតនេះ

គឺជាអ្វីដែលលោកបាននិយាយគឺមានលក្ខណៈអស្ចារ្យណាស់។ ប៉ុន្តែខ្ញុំបានអានសៀវភៅលោកហើយ ដូច្នេះ ខ្ញុំចង់បានចម្លើយដែលខ្លី។ ដូច្នេះ ខ្ញុំត្រូវតែនិយាយកាត់លោកនៅក្នុងករណីខ្លះ។ ហើយនេះគឺជាប្រធានបទដែលខ្ញុំត្រូវសួរសំណួរបន្តទៅទៀត ដែលៗលោកហៅថា ជាការបង្ខំ ឬជាការជំរុញឲ្យជម្លៀសប្រជាជននៅជនបទ។ ប៉ុន្តែតើលោកយល់ស្របដែរឬទេលោកសាស្ត្រាចារ្យ ដែលថាការទម្លាក់គ្រាប់ បែកនោះគឺបង្កើតឲ្យមាននូវការជម្លៀស ឬក៏ឲ្យមានជនភៀសខ្លួនមកតំបន់ទីក្រុងភ្នំពេញ និងជុំវិញទីក្រុងភ្នំពេញនោះ តើវាអាចដែរឬទេ?

[១០:៥៧:២២]

**ឆ៖** ពិតហើយ នេះជាចម្លើយដ៏ខ្លីរបស់ខ្ញុំ។

**ស៖** ប៉ុន្តែលោកមិនអាចប៉ាន់ស្មានពីចំនួនជនភៀសខ្លួនដែលបានរត់គេចមកទីក្រុងភ្នំពេញទេ គឺត្រឹមឆ្នាំ៧៣ ឬក៏ចុងឆ្នាំ៧៣ គឺលោកមិនអាចប៉ាន់ស្មានទេ ថាតើវាមានផលប៉ះពាល់អ្វីខ្លះ ហើយផលប៉ះពាល់ហ្នឹងអាច ប៉ះពាល់ដល់ឆ្នាំ៧៤ ដែរ តើលោកមានចម្លើយយ៉ាងម៉េចដែរចំពោះបញ្ហានេះ?

**ឆ៖** ខ្ញុំមិនប្រាកដដែរចំពោះតំបន់នេះ គឺថា -- ប៉ុន្តែនៅក្នុងខែមេសា ឆ្នាំ៧៥ គឺមានប្រជាជនប្រហែល ពីរទៅ ២លាននាក់ ប៉ុន្តែក្នុង៧០-៧១ -- ឆ្នាំ៧០-៧១ មានប្រហែល១លាននាក់។ ដូច្នេះហើយ យើងគិតថាចំនួនមនុស្សដែលលើសហ្នឹង ដែលកើន ឬក៏ជម្លៀសមកទីក្រុងភ្នំពេញហ្នឹងគឺថា យើង អាចសន្និតបានថា ភាគ មួយភាគនៃប្រជាជនដែលជម្លៀសមកហ្នឹង មកពីផ្នែក ឬក៏ទីរួមខេត្ត ឬក៏ខេត្តនៅជុំវិញទីក្រុងភ្នំពេញ ប៉ុន្តែខ្ញុំមិនប្រាកដថា ខ្ញុំបាននិយាយបែបនេះបានទេ។

[១០:៥៨:៣៩]

**ស៖** តើលោកអាចជម្រាបបានទេអំពីស្ថានភាពរស់ក្នុងទីក្រុងភ្នំពេញ នៅក្នុងខែមេសា ឆ្នាំ៧៥ គឺមុនពេលដែលខ្មែរក្រហមចូលកាន់អំណាច?

**ឆ៖** គឺខ្ញុំផ្អែកទៅលើព័ត៌មានបន្ទាប់បន្សំតែប៉ុណ្ណោះ។ គឺផ្អែកទៅលើព័ត៌មានអំពីជនជាតិចាមដែលថាគាត់អត់មានការរស់នៅគ្រប់គ្រាន់ ដែលគាត់រាយការណ៍ទៅប្រភពព័ត៌មានផ្សេងទៀត អំពីស្ថានភាពរបស់គាត់នោះ គឺតាមរយៈជនជាតិចាម។

**ស៖** ចម្លើយរបស់លោកធ្វើឲ្យខ្ញុំនឹកឃើញទៅដល់ប្រធានបទថ្មីមួយទៀត ហើយប្រធានបទនេះនិយាយអំពីការជម្លៀសចេញពីទីក្រុងភ្នំពេញ។ គឺក្រោយពេលដែលកងកម្លាំងកម្ពុជាប្រជាធិបតេយ្យបានចូលមកកាន់កាប់ទីក្រុង។

លោកបាននិយាយកាលពីសប្តាហ៍មុនថា គឺនៅថ្ងៃ១៩ កក្កដា គឺប្រតិចារឹក ទំព័រ៧២ អ៊ំ! ២៣ ដល់២៥។ “នៅពេលដែលគេចូលមកដល់ គឺគេតែងតែមានហេតុផលដែលមើលទៅដូចជា សមស្រប គឺថាហេតុផលហ្នឹងគឺដោយសារតែខ្វះចំណីអាហារ ដោយសារតែការភ័យខ្លាចការទម្លាប់គ្រាប់បែក របស់អាមេរិកជាដើមនោះ”។ ហើយខ្ញុំសូមបញ្ចប់នូវការដកស្រង់។

[១១:០០:០៤]

ដូច្នេះ ដើម្បីឲ្យច្បាស់លាស់ចំពោះអ្នកដែលចូលរួមនៅក្នុងសាលសវនាការទាំងអស់នេះ ថាតើសប្តាហ៍មុន ពេលដែលលោកនិយាយអំពីហេតុផលដែលមេដឹកនាំកម្ពុជាប្រជាធិបតេយ្យលើកឡើង ទាក់ទងនឹងការជម្លៀសហ្នឹង តើយ៉ាងម៉េចដែរ? លោកមិននិយាយថា ដោយសារកង្វះចំណីអាហារ ឬក៏ដោយសារតែការភ័យខ្លាចទម្លាក់គ្រាប់បែកនោះទេ។ ដូច្នេះ ខ្ញុំចង់ផ្តោតទៅលើចំណុចចុងក្រោយ គឺការភ័យខ្លាចការវាយប្រហារពីអាមេរិក។ លោកបាននិយាយថា លោកមិនបាននិយាយអំពីការភ័យខ្លាចការកម្ទេចរបស់អាមេរិកគឺជាហេតុផលដែលសមស្រប។ តើលោកអាចពន្យល់បានទេ ហេតុអ្វីបានជាលោកថា ការភ័យខ្លាចអាមេរិក មិនមែនជាការហេតុផលដែលសមស្របទៅវិញ?

[១១:០០:៥៦]

**ឆ៖** ខ្ញុំគិតថា ហេតុផលគឺប្រហែលជាមានបកស្រាយរួចមកហើយ ពីព្រោះថាយើងដឹងហើយថា ប្រជាជនៗ នៅក្នុងទីក្រុងដឹងហើយថា វៀតណាមបានចាកចេញរួចទៅហើយ។ សូមទោស គឺអាមេរិកបានចាកចេញកម្ពុជា-វៀតណាមទៅហើយ។ ដូច្នេះ នៅក្នុងខែមេសា ឆ្នាំ៧៥ ហ្នឹង គឺថាហេតុផលសំខាន់ហ្នឹងគឺការដែលថា យើងត្រូវតែជម្លៀសប្រជាជនចេញពីទីក្រុងដោយសារតែវៀតណាម -- អ៊ំ! ដោយសារតែអាមេរិកហ្នឹង គឺមិនត្រឹមត្រូវនោះទេ។ ហេតុដូច្នេះហើយ គួរតែលើកហេតុផលណាមួយដែលសមស្របជាង គឺអាចថាដោយសារតែកង្វះចំណីអាហារ ឬក៏ដោយសារតែកង្វះនូវម្ហូបអាហារជាដើម។ ដូច្នេះហើយ អាចថា ដោយសារតែមានសង្គ្រាមធ្វើឲ្យការស្តុកទុកម្ហូបអាហារ ឬក៏បម្រុងម្ហូបអាហារហ្នឹងមិនគ្រប់គ្រាន់។ ខ្ញុំមិនមានលទ្ធភាពដែលថា -- ហេតុអ្វីបានជាយើងគិតទៅដល់ការភ័យខ្លាចពីអាមេរិកនោះទេ។ ព្រោះថាតាមដែលយើងដឹង អាមេរិកមិនមានគម្រោងដើម្បីទម្លាក់គ្រាប់បែកទៅលើទីក្រុងភ្នំពេញ ក្រោយពេលខ្មែរក្រហមចូលកាន់កាប់នោះទេ។ ដូច្នេះហើយ គឺថាវាគ្មានឯកសារណាមួយដែលបង្ហាញថា អាមេរិកប្រុងទម្លាក់គ្រាប់បែកនោះទេ។

[១១:០២:២២]

**ស៖** ខ្ញុំមិនចង់ឲ្យលោកធ្វើការសន្និដ្ឋានពីអ្វីនៅក្នុងការសួរសំណួរនេះទេ។ ប៉ុន្តែនិយាយអំពីស្ថានភាពស្បៀងអាហារ ដែលលោកបាននិយាយយោងថា មិនមានស្បៀងអាហារសម្រាប់អ្នកភ្នំពេញនោះ។ នៅក្នុងសៀវភៅរបស់លោកនិយាយពី "ប្រវត្តិសាស្ត្រកម្ពុជា" លោកបាននិយាយថា យើងបានមើលផ្នែកមួយ កាលពីសប្តាហ៍មុននោះ។ ឥឡូវនេះ ខ្ញុំគ្រាន់តែដកស្រង់នូវទំព័រមួយ នៅក្នុងសៀវភៅនោះ ខ្ញុំសូម -- ខ្ញុំអាចនឹងផ្តល់ជាឯកសារជូនលោក ប៉ុន្តែលោកនិយាយថា លក្ខខណ្ឌគឺធ្ងន់ធ្ងរណាស់ ជាពិសេសអ្នកដែលមិនមានការ -- មិនចេះធ្វើកម្លាំងពលកម្ម ហើយគិតថា មិនមានអ្នកដែលជម្លៀសពីភ្នំពេញ ហើយត្រឡប់ទៅ -- ហើយជាពិសេស អាចនឹងមានការលំបាក បើប្រៀបធៀបទៅនឹងសម័យកាលដ៏ល្អនោះ។

[១១:០៣:២២]

ចំណុចនេះ និយាយអំពីអ្នកដែលជម្លៀសចេញពីភ្នំពេញទៅជនបទ ហើយលោកបានសរសេរនៅក្នុងភាសាអង់គ្លេសថា "នៅក្នុងស្រុកជាច្រើន គឺមានស្បៀងអាហារគ្រប់គ្រាន់នៅពេលនោះ"។ សូមលោកអាចពន្យល់បន្ថែមបានទេ ទាក់ទងទៅនឹងមតិនេះ?

**ឆ៖** អ្វីដែលខ្ញុំសន្មតនោះ គឺថាដូចខ្ញុំបានសម្ភាសមនុស្សមួយចំនួនគេឆ្លើយបែបនោះ គឺថាវាមិនគ្រប់គ្រាន់ដូចពីដើមនោះទេ ប៉ុន្តែគេមានគ្រប់គ្រាន់ដើម្បីហូប ប៉ុន្តែគេឆ្លើយថា គេមានគ្រប់គ្រាន់។ នេះមិនមែនជាស្ថានភាពដ៏អាក្រក់បំផុតនោះទេ ទូទាំងប្រទេសនៅកាលនោះ។ ប្រហែលជាអ្នកភូមិខ្លះ គឺថាដែលក្រុមគ្រួសារគេរស់នៅ គេអាចមានស្បៀង គេមានស្រូវអង្ករខ្លះ ដោយថាជារដូវច្រូតកាត់ប្រហែលមានស្រូវអង្ករខ្លះ ហើយអ្នករស់រានមានជីវិត គេបានបង្ហាញថាពីរបីខែដំបូងនោះ គឺមិនអាក្រក់ដូចកាលដែលភៀសខ្លួនដំបូងនោះទេ នៅពេលដែលគេបញ្ជូនទៅភូមិភាគពាយ័ព្យ គឺមិនអាក្រក់ដូចដែលគេបញ្ជូនទៅតំបន់ផ្សេងទៀតទេ។

[១១:០៤:៤៦]

**ស៖** សូមអរគុណ។ បើយើងមើលនៅក្នុងសម័យកាលបន្ទាប់ពីការជម្លៀសទៅ ហើយយើងចង់ពិភាក្សាអំពីការប្រជុំដែលកើតឡើងនៅខែឧសភា ថ្ងៃទី២០ ឆ្នាំ១៩៧៥។ លើកឡើងពីសន្និបាតនេះ គឺថាដើមបណ្តឹងរដ្ឋប្បវេណីនោះបានសួរពី -- ថ្ងៃសុក្របានសួរសំណួរទាក់ទងទៅនឹងការធ្វើសន្និបាតមួយនេះ។ ខ្ញុំមិនប្រាកដថា លោកបានស្តាប់ភាសាអង់គ្លេសទេ ប៉ុន្តែការបកប្រែភាសាអង់គ្លេសនោះ គឺថាធ្វើឲ្យយើងយល់ថា នៅក្នុងការជុំនោះ មានសេចក្តីសម្រេចមួយចំនួនដែលគេបានធ្វើ ហើយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំសួរឧលោកបញ្ជាក់ថា "ថាតើសេចក្តីសម្រេចហ្នឹងវាស្របជាមួយនយោបាយ

របស់កម្ពុជាប្រជាធិបតេយ្យដែរឬអត់?"។ ខ្ញុំចង់ឲ្យកត់ត្រាឲ្យច្បាស់នៅក្នុងប្រតិចារឹកថា ឯកសារនេះ គឺថាឯកសារ 4.26 ជា១ផ្នែកមួយដែលដកស្រង់ពីសៀវភៅរបស់លោក ប៉ែន ឃៀវនិន។ សៀវភៅដែលមានចំណងជើងថា "របប ប៉ុល ពត" មិនមែនជាឯកសាររបស់សម័យកម្ពុជាប្រជាធិបតេយ្យដែលបានពិភាក្សាទេ។ ដូច្នេះ ខ្ញុំសូមឲ្យលោកបញ្ជាក់ឲ្យច្បាស់ថា លោកដឹងថាយើងនិយាយអំពីសម័យ -- ឯកសារពីសម័យកម្ពុជាប្រជាប្រធិបតេយ្យ។ លោកសាស្ត្រាចារ្យ ឆេនដ័ល័រ ផ្អែកលើការសិក្សាស្រាវជ្រាវរបស់លោក ថាតើការប្រជុំមួយណាដែលយើងនិយាយថា គឺថានិយាយអំពីសន្និបាតថ្ងៃទី២០ ខែឧសភា ឆ្នាំ៧៥ ហ្នឹង តើសន្និបាតអ្វី?

[១១:០៦:៥១]

**ឆ៖** ខ្ញុំមិនគិតថា ខ្ញុំបាននិយាយយោងទៅរកទេ គឺថាលោក ប៉ែន ឃៀវនិន បានធ្វើការស្រាវជ្រាវ គឺថាអ្នកដែលនៅក្នុងប្រជុំនោះបានប្រាប់លោក ប៉ែន ឃៀវនិន ហើយគាត់មិនបានឃើញឯកសារនោះទេ។ ហើយខ្ញុំមិនបានយោងទៅរកកិច្ចប្រជុំនេះទេ។ ខ្ញុំគិតថា អ្វីដែលគាត់បានព័ត៌មានពីអ្នកដែលសម្ភាសនោះ គឺជាព័ត៌មានត្រឹមត្រូវ។ ខ្ញុំសូមជម្រាបថា មិនមានឯកសារអ្វីដែលសល់បញ្ជាក់ថាមានការប្រជុំហ្នឹងពីសម័យខ្មែរក្រហមទេ។

**ស៖** តាមពិតលោក ប៉ែន ឃៀវនិន នោះបាននិយាយនៅក្នុងសៀវភៅគាត់ថា -- នៅក្នុង ERN 00014425, អង់គ្លេស ERN ដែលខ្ញុំដកស្រង់គឺថា គាត់ថាមិនមានឯកសារអ្វីទេ គឺថាមានតែអ្នកដែលចូលរួមមួយចំនួនតូចទេ ដែលបញ្ជាក់ ក្នុងប្រជុំហ្នឹងទេ ដែលបញ្ជាក់ថា មានការប្រជុំនោះ។ តើតាមការចងចាំ ហើយលោកមិនបានរៀបចំទេ ថាតើលោកអាចបញ្ជាក់ថា អ្នកដែលចូលរួមកិច្ចប្រជុំនុំងមានប៉ុន្មាននាក់ដែលលោក ប៉ែន ឃៀវនិន បានប្រទះ ហើយនិងសួរនោះ? គឺនិយាយពីប្រជុំថ្ងៃ២០ ឧសភា ឆ្នាំ១៩៧៥។

[១១:០៨:១៥]

**ឆ៖** *(គ្មានការបកប្រែ)* --

**ប្រធានអង្គជំនុំ៖**

សាក្សី -- អ្នកជំនាញកុំអាលទាន់ឆ្លើយ មានការតវ៉ាពីក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី រង់ចាំតុលាការសម្រេចអំពីបញ្ហានេះជាមុនសិន។

សូមអញ្ជើញ!

**លោក អូលីវីយ៉េ បាហ្វ៊ូញ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ការរៀបចំសំណួរនេះ គឺនាំឲ្យមានការឆ្លើយតាមរបៀបស្មានៗហើយលោកប្រធាន។

**លោក ហ្សាស្តេ ប៉ោះ៖**

ខ្ញុំរីករាយនឹងរៀបសំណួរឡើងវិញ។

**សួរដោយលោក ហ្សាស្តេ ប៉ោះ៖**

**ស៖** គឺថាផ្អែកលើការសិក្សាស្រាវជ្រាវរបស់លោក លោកសាស្ត្រាចារ្យ ឆេនដ៍ល័រ តើលោកបានរកឃើញទៅលើឯកសារជាប្រភពចម្បងរបស់កម្ពុជាប្រជាធិបតេយ្យ ឬក៏ជាប្រភពទីពីរ ឬក៏ជាអក្សរ ឬក៏សំណេររបស់អ្នកប្រាជ្ញ ឬក៏អ្នកផ្សេង ឬក៏លោកបានឮសម្ដីពីអ្នកដែលបានចូលរួមនៅក្នុងអង្គប្រជុំហ្នឹងបាទ?

[១១:០៩:៣០]

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** គឺថា ខ្ញុំគិតថា តាមដែល ប៉ែន យៀវនិន ប្រាប់ខ្ញុំគឺថា គាត់បានជួបលោក ហេង សំរិន ហើយគឺជាមន្ត្រីថ្នាក់ខ្ពស់នៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលគាត់បានជួបគឺថា ជាអ្នកដែលបានឆ្លើយ។ ជាពិសេស គឺថាអាចនឹងយល់ថា ព័ត៌មានដែលបាននោះគឺជាមានតម្លៃ គឺថាអាចបង្ហាញពីអង្គហេតុ ហើយក៏មិនអាចបន្ទោសថា គាត់និយាយមិនពិតទេ ដូចជា លោក ប៉ែន យៀវនិន ថាគាត់បានជួបជាមួយលោក ហេង សំរិន ហើយមានអ្នកផ្សេងទៀតដែលនិយាយប្រាប់ ប៉ែន យៀវនិន អំពីការប្រជុំថ្ងៃទី២០ ឧសភា ឆ្នាំ៧៥នេះ។

**ស៖** ជាពិសេសចំណុចទាំងប្រាំបីដែលបានពិភាក្សា ដែលលើកឡើងដោយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនោះ គឺមិនបានបង្ហាញពីប្រភពថា ដូចជាប្រភពដែលថា ស៊ិន សុង បានឆ្លើយ ហើយស៊ិន សុង ដែលឆ្លើយហ្នឹងគឺគាត់មិនបានចូលរួមនៅក្នុងកិច្ចប្រជុំមួយនេះទេ។ ហើយដើម្បីកត់ត្រាឲ្យត្រឹមត្រូវ គឺថាចំណុចទាំងប្រាំបីនោះ ដែលបានពិភាក្សាដោយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនោះ គឺដែលទាក់ទងទៅនឹងសៀវភៅ ឬក៏គំនិតរបស់ ប៉ែន យៀវនិន ហ្នឹងគឺជាចម្លើយរបស់ ស៊ិន សុង ប៉ុន្តែ ស៊ិន សុង មិនបានចូលរួមនៅក្នុងកិច្ចប្រជុំថ្ងៃទី២០ ឧសភា ឆ្នាំ១៩៧៥នោះទេ។

[១១:១០:៥៨]

នៅថ្ងៃសុក្រនេះ នៅក្នុងចំណុចទី៥ បញ្ហាដែលបានលើកឡើងថា ពិភាក្សានៅក្នុងកិច្ចប្រជុំហ្នឹង គឺថា ការសម្លាប់មេដឹកនាំទាំងអស់របស់ លន់ នល់ ចាប់ពីថ្នាក់កំពូលទៅ។ តើលោកខ្លួនឯងបានឆ្លើយតបទៅនឹងមតិយោបល់នេះដូចម្ដេច? គឺថាកម្រិតទាក់ទងទៅនឹងមន្ត្រី លន់ នល់ ដែលត្រូវបានសម្លាប់ហ្នឹង គឺថាមិនដែលបានច្បាស់ប្រាកដនោះទេ។ តើលោកអាចពន្យល់អ្វីបន្ថែមពីចំណុចនេះបានឬទេ ទាក់ទងនឹងមតិដែលលោកបានលើកឡើង ទាក់ទងទៅនឹងកម្រិតដែលថាមន្ត្រី លន់ នល់ ត្រូវបានគេសម្លាប់ហ្នឹង គឺមិនដែលកំណត់ឲ្យបានច្បាស់ថា ថ្នាក់ណាដល់ថ្នាក់ណានោះ?

**ឆ៖** ចម្លើយនោះ គឺថាយើងមិនច្បាស់ទេ ពីព្រោះយើងមិនមានភស្តុតាងបង្ហាញដែលថាជាពិសេស គឺថាអ្នកដឹកនាំប្រទេស មុននឹងរបប លន់ នល់ នោះដួលហ្នឹង គឺថាមានប្រាំមួយ ឬប្រាំពីរទេ ដែលគេរាប់ ដែលគេហៅថា ជនក្បត់ ឬជនមហាក្បត់របស់របប លន់ នល់ នោះដែលត្រូវបានសម្លាប់នៅពេលដែលគេរកឃើញ ហើយមានរបាយការណ៍បញ្ជាក់បែបនោះ។ ក្រៅពីហ្នឹង គឺថាមួយចំនួនបានឃើញនៅក្នុងឯកសារហ្នឹង គឺថាមន្ត្រីយោធាដែលជាន់ខ្ពស់ ប្រហែលជាច្បាស់ គឺថាជាថ្នាក់ត្រឹមមន្ត្រីយោធា ឬក៏អធិការនគរបាលត្រូវបានគេសម្លាប់។

[១១:១២:៤៩]

ជាពិសេស គឺយើងមាន -- ជាពិសេសគឺថាវាមានភាពចលាចលនៅក្នុងឆ្នាំ១៩៧៥ ដែលថាវាមានការសម្លាប់ភ្លាមៗនោះដែរ។ គឺថាមានមន្ត្រីខ្លះដែលថ្នាក់ទាបជាងអធិការនគរបាលអីនោះដែរ។ ប៉ុន្តែមានមន្ត្រីជាន់ខ្ពស់មួយចំនួនតូចទេ ដែលនៅរស់ក្នុងចំណោមជនភៀសខ្លួននោះ។ នេះហើយ គឺជាចំណុចមួយដែលថា យើងអាចនឹងចៀសវាងការសម្លាប់របស់របបថ្មី។ កាលណោះ គឺមានការលំបាកណាស់។

**ស៖** សូមអរគុណដែលលោកបានបំភ្លឺចំណុចនេះ។ ឥឡូវនេះ ខ្ញុំសូមអនុញ្ញាតចូលទៅចំណុចមួយ ខ្ញុំសូមអានជូនលោកស្ដាប់សេចក្ដីដកស្រង់ ចេញពីសៀវភៅ ប៉ែន ឃៀរនិន ជាអត្ថបទ។ ហើយខ្ញុំអាច -- ឯកសារនេះបានបង្ហាញដោយមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីពីអាទិត្យមុន គឺថាសុំអនុញ្ញាតឲ្យបង្ហាញ -- មិនអាចបង្ហាញឯកសារបានទេ ប៉ុន្តែខ្ញុំអានឯកសារនេះជូនលោកសាស្ត្រាចារ្យ គឺឯកសារ IS4.26។ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បានប្រើពីថ្ងៃសុក្រហើយ គឺថាឯកសាររបស់សហព្រះរាជអាជ្ញាក៏បានលើកចំណុចនេះដែរ។ គឺថាសុំបង្ហាញដកស្រង់ សេចក្ដីដកស្រង់របស់លោក ប៉ែន ឃៀរនិន ដែលនិយាយពីរបប ប៉ុល ពត នៅទំព័រ៥៧។

**លោក ហ្សាស្តេី ប៉ោ៖**

ខ្ញុំសូមអនុញ្ញាតជូនឯកសារលើក្រដាសទៅលោកសាក្សី ដែលទាក់ទងទៅនឹងអត្ថបទរបស់លោក ប៉ែន ឃៀវនិន ដើម្បីឲ្យបានអាន។ សូមអនុញ្ញាតលោកប្រធាន។

[១១:១៤:៥៥]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារក្រដាសពីមេធាវីយកជូនអ្នកជំនាញពិនិត្យ!

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

**ស៖** ខ្ញុំមិនពិនិត្យមើលទាំងស្រុងនៃទំព័រនេះទេ ប៉ុន្តែខ្ញុំសូមមុននឹងអានសេចក្តីសង្ខេបដកស្រង់លើទំព័រខាងឆ្វេង ទំព័រ៥៦ នៅក្នុងសៀវភៅនេះ ប៉ែន ឃៀវនិន និយាយថា "តាមពិត ជា ស៊ីម បានបង្ហាញថា -- ហើយលោក ជា ស៊ីម បានបន្ថែមនៅក្នុងបទសម្ភាសន៍នោះថា នោះគឺជាដីកា -- ការបញ្ជាដ៏សំខាន់ណាស់ក្នុងការសម្លាប់" គឺថា នួន ជា គឺបាននិយាយពាក្យហ្នឹង។ អ្នកចូលរួមម្នាក់ទៀតនៅក្នុងការប្រជុំនេះ នៅក្នុងការសិក្សារបស់លោកនោះ បើសិនជាគឺតាមពិត លោក ហេង សំរិន អនុលោមតាមសម្តីរបស់ ប៉ែន ឃៀវនិន នោះ ហេង សំរិន គាត់បានលើកឡើងពីអង្គហេតុដ៏សំខាន់មួយទៀត។ ហើយខ្ញុំដកស្រង់ទំព័រ៥៧ នៅក្នុងកថាខណ្ឌ ដែលចាប់ផ្តើម៖ "ហេង សំរិន បន្ទាប់ពីការសិក្សាយោធានៅក្រោម សុន សេន ហើយបានវត្តមាននៅក្នុងកិច្ចប្រជុំ គាត់បាននិយាយនឹកឃើញពាក្យនោះដែរ ហើយគេនិយាយពាក្យថា "សម្លាប់" គឺបំបែកប្រជាជនរបស់របបចាស់ គឺពាក្យថា "កម្ចាត់" គឺមិនឲ្យស្ថិតនៅក្នុងក្របខ័ណ្ឌនោះទេ។ មិនមែនមានន័យថាកម្ទេចទេ។ "កម្ទេច" មានន័យថា "សម្លាប់" ជាពាក្យធម្មតាគឺថា "កម្ចាត់"។ នួន ជា ជាអ្នកប្រើពាក្យនេះ។ នេះគឺជាចំណុចទី៥ របស់ ស៊ិន សុង ដែលគេប្រើពាក្យប្រៀបធៀបទាក់ទងទៅនឹងគុណសម្បត្តិសំខាន់ៗរបស់មនុស្ស"។ ចប់សេចក្តីដកស្រង់។

[១១:១៧:២២]

លោកសាស្ត្រាចារ្យ ឆេនដ័ល័រ ផ្អែកលើការយល់ដឹងរបស់លោកនូវភាសាដែលគេប្រើនៅក្នុងសម័យរបស់កម្ពុជាប្រជាធិបតេយ្យ តើលោកយល់ស្របជាមួយលោក ហេង សំរិន ថាពាក្យថា "កម្ចាត់" គឺគេមិនប្រើពាក្យថា "កម្ទេច"ទេ គឺទាក់ទងដែរឬទេ នៅពេលដែលលោក -- គេនិយាយអំពីការនិយាយនៅក្នុងកិច្ចប្រជុំនោះ គឺទាក់ទងទៅនឹងលោក ជា ស៊ីម ហ្នឹងបញ្ជាក់ថា នេះជាការបញ្ជាដ៏សំខាន់ណាស់

ក្នុងការសម្លាប់។ តើលោកយល់ថា ចំណុចនេះសំខាន់ដូចដែលលោក ប៉ែន យៀវនិន យល់ដែរឬទេ?

**ឆ៖** នេះជាព័ត៌មានផ្ទុយគ្នា។ ខ្ញុំមិនអាចឆ្លើយថាណាមួយខ្ញុំជឿជាក់នោះទេ។ ខ្ញុំមិនបាន១មើលការសម្ភាសទាំងស្រុងនោះទេ។ ពាក្យថា "កម្ចាត់" ហ្នឹង គឺថាមានប្រើនៅក្នុងឯកសារជាច្រើន។ គាត់អាចនឹងប្រើពាក្យនេះ គឺថា ការចងចាំរបស់ឆ្លើយនោះគឺថាអាចនឹងត្រឹមត្រូវ។ មន្ត្រីជាន់ខ្ពស់ពីររូបនេះគប្បីតែនៅក្នុងទំព័រដដែល គប្បីតែមានគំនិតដូចគ្នា គឺថាគាត់មានការចងចាំច្បាស់នៅពេលដែលគាត់សម្ភាសជាមួយ ប៉ែន យៀវនិន នោះប្រហែលជាមិននៅបន្ទប់ជាមួយ ឬនៅបន្ទប់ខុសគ្នា។ ពេលនេះគឺថា លោក ហេង សំរិន មិនបានយល់ស្របទេ។ ប៉ុន្តែតាមសក្ខីកម្មនេះ ខ្ញុំមិនអាចអះអាងថា ណាមួយត្រឹមត្រូវបានទេ ព្រោះខ្ញុំមិនដឹងទាំងស្រុង។

[១១:១៩:០៣]

ប៉ុន្តែចំណុច៦ ដែលលើកឡើងនេះ គឺថាអាចនឹងគេអាចប្រើពាក្យស្រាលជាង ដូចពាក្យ "កម្ចាត់" ដូចជាថា អាចបំបែក និងកម្ចាត់ គឺថាអាចនឹងបញ្ជូនទៅទីជនបទ។ ប៉ុន្តែពាក្យមួយទៀត គេប្រើពាក្យ "ជម្លៀស" មួយទៀត ដែលមិនប្រើពាក្យ "កម្ចាត់" នេះទេ។ ខ្ញុំមិនអាចឆ្លើយលោកឲ្យច្បាស់នូវចំណុចនេះទេ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំមិនឲ្យលោកប្រកាន់យកចម្លើយណាមួយនៅក្នុងករណីនេះទេ។ ឥឡូវនេះខ្ញុំសូមចូលទៅដល់ប្រធានបទមួយផ្សេងទៀត គឺថាអាចនឹងពេលក្រោយមកនៃរបបកម្ពុជាប្រជាធិបតេយ្យ គឺនៅក្នុងឆ្នាំ១៩៧៧ ហើយខ្ញុំសូមដកស្រង់ចេញមកពីសេចក្តីដកស្រង់ ពីសៀវភៅមានចំណងជើងថា "បងទី១" ជាសៀវភៅរបស់លោក ដែលលើកមកពិភាក្សានៅពេលកន្លងមក ហើយខ្ញុំនឹងអានសេចក្តីដកស្រង់ បើសិនជាលោកត្រូវការ។

សូមដកស្រង់នៅក្នុងទំព័រ១១៧, ១១៨ នៃសៀវភៅនោះ "ស្ថានភាពកាន់តែដុនដាបទៅនៅក្នុង ១៩៧៧ គឺថាមនុស្សរាប់ពាន់បានអត់អាហារ ហើយផ្សេង១ទៀតបានធ្លាក់ខ្លួនឈឺដោយខ្វះអាហារ។ របាយការណ៍នេះគឺប្រើពេលយូរមុននឹងទៅដល់ថ្នាក់លើ ដោយសារថាមិនយល់ស្របគ្នានៅក្នុងបក្ស ហើយបក្សនោះមិនដែលពិចារណាទេ ហើយគេយល់ថាជាការល្អ ហើយគេមានសុទិដ្ឋិនិយម ហើយគេយល់ថាមានការបង្កបង្កើនផលល្អ ហើយ -- តែផ្ទុយទៅវិញតំបន់ជនបទខ្វះរបបអាហារ ហើយមនុស្សស្លាប់"។ ចប់សេចក្តីដកស្រង់។ លោកសាស្ត្រាចារ្យ ឆេនដ័ល័រ ផ្អែកលើការសិក្សាស្រាវជ្រាវរបស់លោក ថាតើ១អ្នកក្រោមបង្គាប់នៅក្នុងកម្ពុជាប្រជាធិបតេយ្យ ថាតើគេលាក់ព័ត៌មានទេថា មិនឲ្យថ្នាក់លើដឹង

ថាមានបញ្ហា ឬក៏មានការអត់ឃ្លាន ឬការស្លាប់នោះ?

[១១:២១:២៦]

**ឆ៖** បាទ ខ្ញុំគិតថា គឺគេលាក់កុំឱ្យមានការរិះគន់ កុំឱ្យមានការទិតៀនដើម្បីឱ្យគេរួចផុតពីការបោសសម្អាត ដើម្បីថា បង្ហាញថាការបង្កើតផលបានល្អ ហើយមានសល់ខ្លះថែមទៀតផង ដើម្បីឱ្យគេថាខ្លួនធ្វើបានល្អ។ ប៉ុន្តែគឺយើងឃើញច្បាស់ហើយនៅរបបនោះ គឺថាប្រភពនោះបានថា គឺថាមានការងារជាច្រើនណាស់ដែលគេត្រូវធ្វើ ផែនការច្រើនណាស់នៅជនបទ។ ប្រជាជនថ្មីគឺថាមានកម្រិតទាបណាស់នៅក្នុងអាទិភាពរបស់គេក្នុងការយកចិត្តទុកដាក់ហ្នឹង។ ដូច្នេះហើយការចាត់ការនោះ គឺថាវាយឺតយ៉ាវ។ អៀង ធីរិទ្ធ បានទៅជនបទ ហើយត្រឡប់មកវិញ ដោយមានរបាយការណ៍អាក្រក់មួយចំនួន ប៉ុន្តែប្រាប់ទៅមេដឹកនាំ គឺថាអាហ្នឹងជាការងាររបស់ជនក្បត់ ជាខ្មាំងទេ មិនមែនរបស់បក្ស របស់ខ្លួនទេ។ នេះជាការពន្យល់ផ្ទុយ ដើម្បីលាក់ការងារព័ត៌មានពិតនោះ។ ហើយបើទោះបីជារាយការណ៍ពិត វាជាដំណឹងអាក្រក់សម្រាប់ខ្លួនឯង។ គេអាចនឹងទទួលការបន្ទោស ឬក៏ការដាក់ទោស ដោយសារខ្លួនមិនធ្វើមិនបានជោគជ័យ អាហ្នឹងគឺជាចំណុចបែបហ្នឹង។

[១១:២២:៤៧]

**ស៖** សូមអរគុណ។ លោកបានឆ្លើយសំណួរខ្ញុំហើយទាំងស្រុង។ ដូច្នេះខ្ញុំអាចចូលទៅប្រធានបទមួយថ្មីទៀត។ ខ្ញុំសូមឱ្យលោកពិនិត្យមើលឯកសារមួយជាការងាររបស់លោក គឺស្នាដៃរបស់លោក គឺ "បងទី១" គឺ E3/17 ហើយនិងខ្ញុំសូមលោកមើលទំព័រ១៦០ នៃទំព័រនោះគឺ ERN ជាភាសាអង់គ្លេសនោះ គឺ 00393074។ ខ្ញុំបានឃើញសេចក្តីដកស្រង់នេះ គឺថាខ្ញុំនឹងអានសេចក្តីដកស្រង់នេះជូនលោក។ សូមដកស្រង់៖ "ប្រហែលបុរសស្ត្រីរាប់ពាន់នាក់ ឬលើសពីនេះគឺត្រូវបានគេសម្លាប់ចោលដោយគ្មានការជំនុំជម្រះ។ នៅតំបន់ជនបទ ការសម្លាប់ភាគច្រើនកើតឡើងនៅពេលកម្មាភិបាលក្មេងៗអនុវត្តនូវអ្វីដែលគេយល់ថាជាការផែនការរបស់អង្គការ។ ការសម្លាប់ទាំងអស់នេះប្រហែលជាភាគច្រើនហ្នឹង គឺវាមានលក្ខណៈ ដោយសារការប្រតិកម្មហួសហេតុ ឬក៏ការសងសឹក"។ ចង់សេចក្តីដកស្រង់។

នៅថ្ងៃសុក្រ នៅពេលដែលរៀបចំសំណួរនេះ ខ្ញុំមិនមានប្រតិចារឹកនៅថ្ងៃសុក្រទេ ប៉ុន្តែខ្ញុំចង់និយាយអំពីការសម្លាប់ដោយករណីពិសេស ហើយនិងដោយថាអ្នកសម្លាប់ហ្នឹងគឺមានការពេញចិត្តទៅនឹងការងារបក្ស បដិវត្តន៍របស់គេបានជាគេអនុវត្តការងារហ្នឹង។ តើលោកអាចប្រាប់តុលាការបន្ថែមអ្វីអំពីប្រធានបទនេះ អ្វីដែលលោកហៅថា គឺជាប្រតិកម្មហួសហេតុ គឺជាសេចក្តីសម្រេចអនុវត្តបន្ទាន់

លើសពីអ្វីដែលជានយោបាយគេនោះ?

[១១:២៥:០២]

**ឆ៖** ឥឡូវនេះយើងដឹងថា ប្រហែលជាច្រើនជាងបីបួនពាន់ទៅទៀត នេះជាប្រព័ន្ធការសម្លាប់នៅជនបទហ្នឹង គឺថាយើងមានឯកសារច្រើនដែលយើងបានដឹង ប៉ុន្តែខ្ញុំប្រកាន់យកអ្វីដែលខ្ញុំបានសរសេរ គឺការបោះពុម្ពលើកទី២ នៅឆ្នាំ១៩៩៩។ សៀវភៅរបស់ខ្ញុំនេះ ជាពិសេសគឺព័ត៌មានដែលបានមកពីបទសម្ភាសន៍គឺថា អាកប្បកិរិយារបស់កម្មាភិបាល គឺជាកត្តាជំរុញដោយអំពើចលាចលដែលគេមានកំហឹងខឹងសម្បា។ ហើយប៉ុន្តែគេមានការរៀបចំ គឺថាភាគច្រើនគេមានអំពើឃោរឃៅ គឺថាវាមានកត្តាជំរុញ គឺថាពេលខ្លះមានបញ្ជាមកពីលើ ក៏ប៉ុន្តែព័ត៌មានដែលខ្ញុំបានទទួលជាច្រើនឆ្នាំនោះ គឺថាដែលប្រជាជនខ្មែរជាច្រើនដែលខ្ញុំបានសម្ភាសនោះ គឺគេបាននិយាយបែបនេះ។

ខ្ញុំសូមបន្ថែមបន្តិច មិនដែលឃើញនៅក្នុងចម្លើយសារភាពនៅស-២១ ដែលថាអ្នកណាម្នាក់បានសារភាពថា ៗជាកាយវិការហួសហេតុ សងសឹកនៅទៅតាមខេត្តនោះទេ ដែលជាបទឧក្រិដ្ឋដែលគេបានធ្វើនោះ។

[១១:២៦:៣០]

**ស៖** នេះជាសំណួរបន្ថែមដែលខ្ញុំនឹងសួរបន្តទៅទៀត តើលោកបានដឹងថា តើៗថ្នាក់ក្រោមហ្នឹងអាចរាយការណ៍សេចក្ដីសម្រេចពិសេសមួយៗដែលថាប្រតិកម្មហួសហេតុ ឬក៏ថាគេបញ្ជូនទៅថ្នាក់លើរបស់គេឲ្យដឹងទេ កាលណាគេអនុវត្តលើសផែនការដោយសងសឹក ដោយកំហឹងអីហួសហេតុនោះ?

**ឆ៖** ប៉ុន្តែវាមិនជាចំណុចចាប់អារម្មណ៍ទេ។ ប៉ុន្តែកាលពីសប្ដាហ៍មុននោះនៅក្នុងលក្ខន្តិកៈបក្សកុម្មុយនីស្ដកម្ពុជាដែលយើងបានពិភាក្សានោះ និងការងាកទៅខាងឆ្វេងហ្នឹង គឺថាការអនុវត្តឆ្វេងពេកស្ដាំពេកនោះ គឺបក្សគេបានកត់សម្គាល់អីចឹង ក៏ប៉ុន្តែការពេញចិត្តក្នុងការអនុវត្តគោលដៅរបស់បដិវត្តន៍នោះគឺគេយល់ជាទូទៅ គឺថាគេមិនទទួលការពិន័យពីបក្សនោះទេ។ នៅក្នុងករណីខ្លះកម្មាភិបាល គឺមិនមែនមានន័យថា គេអនុវត្តដោយមិនមានការត្រួតពិនិត្យ ប៉ុន្តែកាលណាគេអនុវត្តផែនការហើយ ពេលក្រោយគឺពេលដែលគេចោទប្រកាន់ថាជាភ្នាក់ងារអ្វីៗនោះ គេមិនបានសារភាពថាគេអនុវត្តផែនការលើសដោយមានកំហឹង ដោយអីនោះទេ។ គេបែរជាសារភាពណា គេធ្លាប់មានទំនាក់ទំនងជាមួយខ្សែពីដើម ខ្មាំងអីជាដើម។ គេមិនដែលសារភាពថាគេធ្វើការងារហួសនោះទេ ប៉ុន្តែការងារ -- ប៉ុន្តែវាមានការងារមួយចំនួនដែលគេធ្វើ ប៉ុន្តែគេមិនដែលរាយការណ៍។ នេះជារបាយការណ៍ដែលថាវាផ្ទុយគ្នានៅ

ក្នុងចំណុចខ្លះៗដែលខ្ញុំឃើញ។

[១១:២៨:២១]

**ស៖** សូមអរគុណ។ នៅក្នុងបរិបទដដែលនេះ ខ្ញុំចង់បង្ហាញលោកនូវឯកសារមួយជាអត្ថបទដែលសរសេរដោយ ស្ទីវ ហេដឌ័រ គឺនិយាយអំពីការវាយតម្លៃឡើងវិញ អំពីតួនាទីមេដឹកនាំក្នុងមូលដ្ឋានដើម្បីផ្តោតទៅលើបទឧក្រិដ្ឋកម្ពុជាប្រជាធិបតេយ្យ។ ឯកសារ E190.1.3.8, អង់គ្លេស ERN 00661455 រហូតដល់ 491, បារាំង ERN 007979 (ស៊ីក) រហូតទៅដល់ 850។ ខ្ញុំចង់បង្ហាញលោកសេចក្តីដកស្រង់ចេញពីទំព័រ១២ នៅចំណុចនេះ អង់គ្លេស ERN 00661466 ហើយនិងយើងមានឯកសារលើក្រដាសជូនលោក។

**លោក ហ្សាស្តេ ប៉ោ៖**

សូមលោកប្រធានអនុញ្ញាត ដើម្បីបង្ហាញឯកសារនេះនៅលើអេក្រង់ និងជូនឯកសារលើក្រដាសទៅសាក្សីបាទ។

[១០:២៩:៤២]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៣១:០៥]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីឯកសារ E190.1.3.8 ហ្នឹង តើមាននៅក្នុងសំណុំរឿងដែរឬទេ?

**លោក ហ្សាស្តេ ប៉ោ៖**

លោកប្រធាន តាមដែលខ្ញុំបានដឹងសហព្រះរាជអាជ្ញាបានបញ្ជាក់ខាងដើមហើយថា ឯកសារនេះគឺមាននៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញាបាទ។ នៅក្នុងសំណុំរឿងហើយ គឺខ្ញុំគិតថា ផ្អែកលើឯកសារលេខនេះ ជាផ្នែកដែលបានដាក់ជូនដោយមេធាវី ខៀវ សំផន ដែលដាក់ដេញដោលចំពោះអង្គជំនុំជម្រះគឺ E190.1.398។ បាទនេះជាឯកសារ តាមអ្វីដែលខ្ញុំយល់អំពីសមត្ថភាពនេះគឺថា គប្បីតែបានអនុញ្ញាតឲ្យដាក់ដេញដោលក្នុងករណីនេះគឺ E 190.1.398 បាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីមេធាវី យកជូនលោកអ្នកជំនាញដើម្បីពិនិត្យ។

**សួរដោយលោក ហ្សាស្តើ ប៉ៅ៖**

**ស៖** នេះគឺថាមានបីទំព័រ ប៉ុន្តែខ្ញុំនឹងយោងតែរកទំព័រ១២ ជាទំព័រដែលលោកបានប្រមូលឯកសារលោកកត់ត្រា ហើយខ្ញុំនឹងដកស្រង់សេចក្តីរបស់លោក ហេដឌ័រ -- ស្ទីវ ហេដឌ័រ ហើយខ្ញុំសូមដកស្រង់៖ “ប៉ុន្តែការសម្លាប់ផ្សេងទៀត ប្រហែលជាភាគច្រើន គឺត្រូវបានប្រព្រឹត្តនៅថ្នាក់តំបន់ ហើយថ្នាក់មូលដ្ឋាន គឺដែលបានធ្វើឡើងមិនគោរពទៅតាមខ្សែបញ្ជា ប្រហែលជាវាមានភាពធូររលុងក្នុងរចនាសម្ព័ន្ធដែលគេបានផ្ទេរអំណាចឲ្យទៅដល់ថ្នាក់ក្រោម គឺមានការណែនាំស្រពេចស្រពិលមិនច្បាស់លាស់ ហើយថ្នាក់ក្រោមដែលបានសម្រេចថា តើត្រូវកំណត់ថា អ្នកណាខ្មាំង អ្នកណាមិនមែនខ្មាំងត្រូវអ្វីដោយខ្លួនឯង។ ថ្នាក់ក្រោមទាំងអស់នេះ គឺមិនគោរពបញ្ជានោះទេ”។ តើលោកឯកភាពយល់ស្របជាមួយការសរសេរបែបនេះដោយ ស្ទីវ ហេដឌ័រ ដែរឬទេ?

[១១:៣៣:៤៧]

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** បាទ ខ្ញុំឯក -- ខ្ញុំយល់ស្រប។

**ស៖** សូមអភ័យទោស។ ខ្ញុំសួរសំណួរផ្សេង។ តើលោកបានឃើញ ឬក៏បានដឹងពីឯកសារនេះពីមុនមកទេ មុននឹងមកទីនេះបាទ?

**ឆ៖** បាទ ខ្ញុំធ្លាប់ស្គាល់។

**ស៖** ហើយចំណុចទី២ ដែលខ្ញុំចង់ដក គឺដកស្រង់ គឺនៅទំព័រ២១ ហើយភាសាអង់គ្លេស គឺមាន 00661475។ ហើយខ្ញុំសូមដកស្រង់៖ “វាហាក់ដូចជាបង្ហាញថា ជាទូទៅមនុស្សត្រូវបានគេចាប់ឡើងនៅក្នុងភូមិស្រុក ហើយត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខស្រុក ដើម្បីធ្វើការស៊ើបអង្កេត។ ទោះបីថា ខាងស្រុកបានឆ្លើយទៅខាងតំបន់ក៏ដោយ ប៉ុន្តែអ្នកទោសទាំងអស់នោះ ជាញឹកញាប់ត្រូវបានគេសម្លាប់។ ការណ៍នេះផ្ទុះបញ្ជាំងថា ខាងតំបន់ និងខាងភូមិភាគគ្រាន់តែផ្តល់នូវព័ត៌មាន ឬក៏ផ្តល់នូវការណែនាំជាទូទៅពីខាងលើទៅថ្នាក់ក្រោមតែប៉ុណ្ណោះ តើវាជាការត្រឹមត្រូវដែរឬទេ ដែលនិយាយបែបនេះ?

លោក សាស្ត្រាចារ្យ ឆេនដ៍ល័រ តើលោកយល់ស្របជាមួយនឹងការរៀបរាប់ ការកំណត់ប្រភេទរបស់លោក ស្ទីវ ហេដឌ័រ បែបនេះដែរឬទេ?

**ឆ៖** បាទ ខ្ញុំគាំទ្រ ខ្ញុំយល់ស្រប។

[១១:៣៥:៣២]

**ស៖** ហើយនៅទំព័រទី២ លោក ស្ទីវ ហេដឌ័រ បានពិភាក្សាអំពីគំរូប្រវត្តិសាស្ត្រ និងគំរូ មួយចំនួនទាក់ទងទៅនឹងការប្រព្រឹត្តនូវរបបណាហ្មឹ ហើយគាត់បានពិភាក្សាអំពីគំរូនេះជាសង្ខេប ដែលថាជាទូទៅគឺមានការប្រព្រឹត្តពីលើចុះមកក្រោម នៅក្នុងការប្រព្រឹត្តអំពីប្រល័យពូជសាសន៍។ ហើយជាដំបូងគឺថាគេចាត់ទុកថាជាខ្លាំងធំ ឬក៏ត្រីធំហ្នឹង ត្រូវបានគេចាប់ គឺនៅពេលដែលគេស្ថិតនៅក្នុងអំណាចនោះ។ ដូច្នេះហើយអ្វីទាំងអស់នេះ គឺជាអ្វីដែលខ្ញុំចង់ដកស្រង់ ហើយខ្ញុំចង់សួរទៅលោកសាស្ត្រាចារ្យថា តើការកំណត់ចំណាត់ថ្នាក់របស់លោក ស្ទីវ ហេដឌ័រ ទាក់ទងទៅនឹងរបបណាហ្មឹ អំពីការគ្រប់គ្រង ឬក៏ការដឹកនាំហ្នឹង តើធ្វើឱ្យលោកនឹកឃើញដែរឬទេ ថាតើអ្វីដែលលោកបានពិភាក្សាកាលពីព្រឹកដែលនិយាយថា ការគ្រប់គ្រងតាមបែបថ្នាក់លើហ្នឹងវាមានន័យបែបម៉េច? បែបណាដែរនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

[១១:៣៦:៥១]

**ឆ៖** ពិតហើយ ប៉ុន្តែនេះវាគ្រាន់តែជាផ្នែកចិត្តសាស្ត្រតែប៉ុណ្ណោះ។ ខ្ញុំគិតថា ខ្ញុំគួរតែលើកឡើងអំពីគំនិតរបស់ខ្ញុំ។ យើងត្រូវតែទទួលយកនូវគំនិតដែលថា អ្នកដឹកនាំជាន់ខ្ពស់ត្រូវតែទទួលខុសត្រូវទៅលើអ្វីដែលខ្លួនបានដឹកនាំ ព្រោះខ្លួនជាអ្នកដឹកនាំប្រទេស។ ដូច្នេះក្នុងករណីនេះ ព្រោះថាខ្ញុំមិនមែនជាអ្នកសរសេរអត្ថបទនេះ ប៉ុន្តែខ្ញុំគិតថាវាជាការត្រឹមត្រូវ ព្រោះថាសំណួររបស់លោកវាជាសំណួរដ៏ច្បាស់លាស់រួចទៅហើយ។

**ស៖** ក្នុងនាមជាប្រវត្តិវិទូ -- ខ្ញុំសូមលើកសំណួរសាជាថ្មី។ តើលោកពេញចិត្តដែរឬទេ ដែលថាមានការស្រាវជ្រាវប្រវត្តិសាស្ត្រជាច្រើនត្រូវបានគេធ្វើឡើង អំពីការទទួលខុសត្រូវរបស់មនុស្សនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលឋានៈទាប ឬក៏ស្ថិតនៅក្នុងកម្រិតទាប ប៉ុន្តែគាត់នៅក្នុងសមាជិកគណៈអចិន្ត្រៃយ៍ ឬគណៈមជ្ឈិម។ ខ្ញុំសូមរៀបចំសំណួរដូចតទៅនេះ។

ខ្ញុំបាននិយាយថា ខ្ញុំចង់និយាយសំណួរសាជាថ្មី ដូច្នេះខ្ញុំសួរថា តើលោកពេញចិត្តជាមួយនឹងការសិក្សាស្រាវជ្រាវ គឺថា ដែលថាអ្នកនៅថ្នាក់ក្រោមហ្នឹង គឺថាអ្នកនៅថ្នាក់ក្រោមទាបជាងមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យនេះជាអ្នកទទួលខុសត្រូវដែរ ឬមួយក៏យ៉ាងណា?

[១១:៣៩:២៥]

**ឆ៖** ខ្ញុំមិនប្រាកដឲ្យច្បាស់លាស់នោះទេ ប៉ុន្តែខ្ញុំមិនចង់ធ្វើការបកស្រាយ ឬក៏ការនេះ ព្រោះថាវាមានាការសិក្សាស្រាវជ្រាវជាច្រើនត្រូវបានធ្វើឡើង ជាពិសេសក្នុងពេលថ្មីៗនេះអំពីបញ្ហាទាក់ទងទៅ

នឹងសំណុំរឿងដែលគេនឹងមិនជំនុំជម្រះ គឺថាសំណុំរឿងដែលនៅក្រោយសំណុំដែលយើងកំពុងតែពិភាក្សានេះ។ ដូច្នេះ អានេះគឺជាការងាររបស់តុលាការ ខ្ញុំគ្រាន់តែធ្វើការសន្មត ប៉ុន្តែយើងត្រូវការឲ្យមានការស្រាវជ្រាវបន្ថែម ហើយបន្ទាប់មកខាងព្រះរាជអាជ្ញា ប្រហែលជាព្រះរាជអាជ្ញាគាត់មានការពិចារណាគ្រប់គ្រាន់ហើយ ទើបគាត់ចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ។ ដូច្នេះ វាអាចជាអាណត្តិការងារ ឬមួយក៏ជាការងារណាមួយដែលយើងត្រូវរកឃើញនៅតាមទីជនបទ។ ពីព្រោះយើងមានឯកសារជាច្រើនរួចមកហើយអំពីសកម្មភាពរបស់ថ្នាក់ក្រោម អំពីអាកប្បកិរិយារបស់ថ្នាក់ដឹកនាំផ្នែកក្រោម។ ដូច្នេះ យើងប្រហែលជាពិបាកក្នុងការពិភាក្សានៅទីនេះ ព្រោះថាវាមិនមែនជាឯកសារជាសាធារណៈដែលយើងត្រូវយកមកជជែកដេញដោល ប៉ុន្តែក្នុងនាមជាអ្នកប្រវត្តិវិទូឯករាជ្យ ខ្ញុំគិតថា វាមិនគ្រប់គ្រាន់នោះទេ។ គឺយើងមានឯកសារបង្ហាញអំពីអាកប្បកិរិយា ឬការដឹកនាំផ្សេងៗទៀតជាច្រើន ដូចដែលខ្ញុំសរសេរនៅក្នុងសៀវភៅរបស់ខ្ញុំអ៊ីចឹង។

[១១:៤០:៤៧]

ដូច្នេះ ខ្ញុំឯកភាពជាមួយនឹងអ្វីដែល ស្ទីវ ហេដឌ័រ បាននិយាយពីខាងមុខ ពីព្រោះថា ស្ទីវ ហេដឌ័រ គាត់ធ្វើការស្រាវជ្រាវច្រើន ច្រើនតាំងពីមុនពេលដែលមានបង្កើតនូវតុលាការមួយនេះមកម្ល៉េះ។ ដូច្នេះ គាត់មានស្រាវជ្រាវដ៏ទូលំទូលាយ និងលម្អិតលម្អន់ខ្លាំង។

**ស៖** សូមអរគុណលោកសាស្ត្រាចារ្យ ដើម្បីឲ្យបញ្ជាក់ឲ្យច្បាស់ ខ្ញុំមិនមែនឲ្យលោកនិយាយអំពីអ្វីដែលទាក់ទងទៅនឹងអង្គជំនុំជម្រះមួយនេះទេ។ ការពិត គ្រាន់តែខ្ញុំចង់ឲ្យលោកបញ្ចេញមតិយោបល់ក្នុងនាមជាប្រវត្តិវិទូ ដែលថាអ្វីដែលលោកបានបង្ហាញរួចមកហើយនោះ គឺវាធ្វើឲ្យខ្ញុំមានការចាប់អារម្មណ៍ ហើយខ្ញុំចង់សួរលោកឲ្យបានលម្អិតបន្ថែមអំពីបញ្ហានេះ។ លោកបានបញ្ជាក់ថា ព័ត៌មានទាំងអស់នេះ ដែលលោកបានពិនិត្យមើល គឺមិនមែនជាឯកសារបើកចំហ ឬក៏ឯកសារសាធារណៈនោះទេ។ ដូច្នេះ តើលោកអាចពន្យល់បន្ថែមបានទេ ទៅលើបញ្ហានេះ ដើម្បីឲ្យយើងបានយល់ច្បាស់អំពីចំណុចទាំងអស់នេះ?

[១១:៤២:០១]

**ឆ៖** ការពិត វាមិនមែនជាឯកសារដែលគេចាត់ចំណាត់ថ្នាក់ ថាជាសម្ងាត់ដោយអាជ្ញាធរ ឬក៏ដោយបណ្ណាល័យ ឬក៏ដោយភ្នាក់ងារណាមួយឡើយ។ ដូច្នេះ ខ្ញុំគិតថា យើងមានឯកសារជាច្រើន នៅក្នុងបណ្ណសារ ឧទាហរណ៍ ដូចជារបស់ ឌី.ស៊ី.ខេម ឬក៏មានការស្រាវជ្រាវ មានការស៊ើបអង្កេតណាមួយ

ផ្សេងទៀត។ លោកអាចនឹងឃើញមាននៅក្នុងជើងទំព័ររបស់ឯកសាររបស់លោក ស្ទីវ ហេដឌ័រ ឬមួយក៏អំពីរចនាសម្ព័ន្ធដែលចេញមកពីចម្លើយសារភាព ហើយប្រហែលជាលោកដឹងហើយ គាត់បានជម្រាបមកខ្ញុំអំពីបញ្ហានេះ។ គាត់មានអារម្មណ៍ថា រចនាសម្ព័ន្ធ ឬក៏ឯកសារនិយាយអំពីរចនាសម្ព័ន្ធនេះ គឺមានដាក់បញ្ចូលនៅក្នុងឯកសារដែលមានលក្ខណៈជាឯកសារអាជីព ហើយធ្វើការស្រាវជ្រាវ ថាតើអ្នកណាជាអ្នកទទួលបញ្ជា? អ្នកណាជាអ្នកបញ្ជា? ដូច្នេះ វាពិបាកក្នុងការនិយាយទៅលើបញ្ហានេះ។

[១១:៤៣:០៧]

**ស៖** ខ្ញុំយល់ថា ប្រហែលជាលោកមិនចង់ធ្វើការប៉ាន់ស្មាន ឬក៏ទស្សន៍ទាយពីអ្វីដែលលោក ស្ទីវ ហេដឌ័រ បាននិយាយ ហើយខ្ញុំក៏មិនស្នើសុំឲ្យលោកធ្វើការទាយស្មាននោះដែរ។ ប៉ុន្តែទោះបីថា លោក ស្ទីវ ហេដឌ័រ ប្រាប់លោក ឬមួយក៏លោកមានហេតុផលដែលជឿជាក់ថា ឯកសារនិយាយអំពីអង្គការដែលលោក ស្ទីវ ហេដឌ័រ បាននិយាយអំពីបញ្ហាទាំងអស់នេះ គឺតើវាយ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំគិតថា ឯកសារនេះ គឺមានច្រើននៅក្នុងទួលស្លែង ប្រសិនបើលោកមើលទៅលើជើងទំព័ររបស់គាត់ គឺគាត់និយាយបញ្ជាក់ច្បាស់អំពីបញ្ហានេះ ហើយគាត់រួមបញ្ចូលទាំងកិច្ចសម្ភាសន៍របស់គាត់ផងដែរ។

**ស៖** ប៉ុន្តែលោកដឹងដែរឬទេ ថាតើមានការសិក្សាស្រាវជ្រាវណាមួយ ដែល ស្ទីវ ហេដឌ័រ គាត់ធ្វើការស្រាវជ្រាវបន្ទាប់ពីបានទទួល បន្ទាប់ពីបានពិនិត្យមើលឯកសារនៅៗ ស-២១ រួចហើយ?

**ឆ៖** មិនមានបញ្ជាក់អ្វីឲ្យបានច្បាស់លាស់ទេ ព្រោះថាប្រហែលជាមិនមានការបោះពុម្ពអី ឲ្យបានច្រើននោះទេ។ ដូច្នេះ ខ្ញុំមិនអាចជម្រាបអ្វីឲ្យបានច្បាស់លាស់នោះទេ។

[១១:៤៤:២៦]

**ស៖** ក្នុងឯកសារដដែលរបស់ ស្ទីវ ហេដឌ័រ នោះ នៅទំព័រ២។ យើង -- ខ្ញុំសូមបង្ហាញនៅលើអេក្រង់ ហើយវាជាឯកសារដដែលរបស់ ស្ទីវ ហេដឌ័រ ដែលយើងបានពិភាក្សាមុននេះរួចមកហើយ ហើយខ្ញុំសូមដកស្រង់នូវឯកសាររបស់ ស្ទីវ ហេដឌ័រ ។ ផ្នែកនេះ គឺពិភាក្សាអំពីវិធីសាស្ត្រដែលគ្រប់គ្រងដោយមិនត្រឹមត្រូវទៅលើវិធីសាស្ត្រផ្នែកច្បាប់ និងប្រវត្តិសាស្ត្រទាក់ទងទៅនឹងការសម្លាប់ជាទ្រង់ទ្រាយធំដែលធ្វើឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក្រោមការគ្រប់គ្រងពីឆ្នាំ៧៥ ខែមេសា រហូតដល់ថ្ងៃ ០៧ មករា ឆ្នាំ៧៩ របស់បក្សកុម្មុយនីស្តកម្ពុជា។ ប្រវត្តិសាស្ត្រដែលមានតែមួយរបស់កម្ពុជាប្រជាធិបតេយ្យ គឺឯកសារដែលបានបោះពុម្ពថ្មីៗនេះ ដោយលោក ប៉ែន យៀវនិន គឺនិយាយអំពីរបបខ្មែរ

ក្រហម ការ -- ពូជសាសន៍ អំណាច ហើយនិងការប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា ក្រោមរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង គឺធ្វើឲ្យសំណុំរឿងរបស់កម្ពុជាប្រជាធិបតេយ្យហ្នឹងវាមានលក្ខណៈដូចគ្នាទៅនឹងការគ្រប់គ្រងផ្ដាច់ការ ហើយនិងជាអន្តរជាតិ។ ហេតុដូច្នេះហើយ គឺវាបង្ហាញអំពីការ--

[១១:៤៦:០២]

**អ្នកបកប្រែ៖**

លោកប្រធានសូមស្នើឲ្យមេធាវីការពារក្ដីអានឲ្យបានយឺតៗបន្តិច។

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

ខ្ញុំគិតថា ប្រហែលជាលោកបានឆ្លើយទៅលើសំណួរនេះមួយចំនួនរួចមកហើយនៅក្នុងមតិរបស់លោកកាលពីមុន ប៉ុន្តែលោក ស្ទីវ ហេដឌ័រ បានលើកឡើងអំពីទ្រឹស្ដីនៃការលុបចោល ឬក៏ទ្រឹស្ដីអកម្មនៃការមិនទទួលខុសត្រូវរបស់អ្នកដឹកនាំថ្នាក់ក្រោមនៅក្នុងរបប ប៉ុល ពត។

**ស៖** តើលោកយល់ឃើញដូចគ្នានឹងលោក ស្ទីវ ហេដឌ័រ ដែរឬទេ ដែលថា ការដកចេញនូវសារៈសំខាន់នៃអ្នកដឹកនាំថ្នាក់ក្រោមហ្នឹង គឺមិនមែន -- គឺមិនទទួលខុសត្រូវនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើលោកយល់ឃើញដូចគ្នានេះដែរឬទេ?

[១១:៤៧:០២]

**លោក ឆេវីដ ឆេនដ៍ល័រ៖**

**ឆ៖** គឺមានពាក្យបីដែលខ្ញុំចង់ឆ្លើយ។ គឺខ្ញុំយល់ស្របទៅលើ -- វាជាសំណួរដ៏ស្មុគស្មាញមួយ ហើយខ្ញុំគិតថា ប្រហែលជាយើងត្រូវចំណាយពេលពិភាក្សាទៅលើផ្នែកដទៃទៀតដ៏ច្រើន។ ដូច្នេះនៅក្នុងសៀវភៅរបស់ ប៊ែន ឃៀរនិន គឺលោក ប៊ែន ឃៀរនិន បាននិយាយពីអ្វីដែលខ្ញុំចង់និយាយនេះ។ គឺថាការនិយាយអំពីពូជសាសន៍ហ្នឹង គឺវាកើតឡើងនៅក្នុងពេញទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ ហើយលោក ឃៀរនិន ក៏បានប្រើប្រាស់ពាក្យថា “បណ្ដាញ ឬក៏ខ្សែមួយ”។ ដូច្នេះហើយវាពិបាក។ ដូច្នេះហើយនេះវាជាការសម្រេចផ្នែកប្រវត្តិសាស្ត្រមួយដែលបង្ហាញថា វាមិនខុសពីអ្វីដែលកើតឡើងនៅក្នុងឆ្នាំ៧៩ គឺសវនាការឆ្នាំ៧៩ នោះឡើយ។ ដូច្នេះ ខ្ញុំសូមធ្វើការវាយតម្លៃឲ្យបានត្រឹមត្រូវដែលថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើលោកនិយាយថា បុគ្គលតែមួយរូបនៅក្នុងថ្នាក់ដឹកនាំនុំងគឺមានការទទួលខុសត្រូវតែឯង ឬក៏ទទួលខុសត្រូវច្រើន។ ប៉ុន្តែយ៉ាងណាក៏ដោយ ប្រសិនបើយើងគិតបែបនេះគឺយើងមិនអាចឈានទៅបានឆ្ងាយពីអ្វីដែលបាននិយាយនេះទេ។ ដូច្នេះ ការពន្យល់របស់លោក ស្ទីវ

ហេងឌ័រ គឺមានលក្ខណៈត្រឹមត្រូវសមស្រប។

[១១:៤៨:៤៧]

**ស៖** លោកជាប្រវត្តិវិទូ ហើយយើងបាននិយាយអំពីបរិបទច្រើននៅក្នុងពេលឥឡូវនេះ ហើយសំណួររបស់ខ្ញុំដែលចង់សួរលោកគឺថា តើលោកគិតថាហេតុការណ៍ ឬក៏ការពិតផ្នែកនយោបាយនានាដែលបានកើតឡើងក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ មានឥទ្ធិពល ឬក៏មានផលប៉ះពាល់ទៅដល់អ្វីដែលយើងមើលទៅលើអង្គហេតុដែលយើងជួបប្រទះនៅថ្ងៃនេះដែរឬទេ?

**ឆ៖** នេះគឺជាអ្វីដែលយើងគិតទាំងអស់គ្នា គឺយើងធ្វើនៅក្នុងការផ្តល់សក្ខីកម្មកាលពីសប្តាហ៍មុន ហើយយើងទទួលបាននូវអ្វីដែលយើងទទួលបាននៅថ្ងៃនេះ គឺអំពីបរិបទនៅថ្ងៃនេះ ប៉ុន្តែខ្ញុំមិនប្រាកដថាតើវាយ៉ាងម៉េចនោះទេ។ នេះគឺជាអ្វីដែលយើងទទួល អ្វីដែលយើងប្រើប្រាស់នៅព័ត៌មានដែលយើងបានទទួលនៅពេលដែលរបបមួយបានដួល គឺយើងមានទទួលព័ត៌មានដែលយើងមាន និងព័ត៌មានដែលមិនមាន។ ដូច្នេះ យើងត្រូវមានការប្រុងប្រយ័ត្នចំពោះព័ត៌មានដែលយើងទទួល ហើយយើងស្វែងរកនូវលទ្ធភាពដែលយើងអាចទទួលបានព័ត៌មាន ដើម្បីទទួលបាន។ ឧទាហរណ៍ដូចជាយើងចូលទៅក្នុងបន ហើយ ឬក៏យើងដឹងអំពីបនប្រល័យពូជសាសន៍ ប៉ុល ពត, អៀង សារី ជាដើមនោះ។

ដូច្នេះហើយ នៅពេលដែលពេលវេលាវាបានប្រែប្រួល ដូច្នេះអាចថានៅ១០ឆ្នាំមុន គឺព័ត៌មានវាថ្មីជាងបច្ចុប្បន្ននេះ ប៉ុន្តែនៅពេលដែលពេលវេលាកន្លងផុតទៅ គឺយើងអាចនឹងធ្វើការវាយតម្លៃថ្មីអ្វីដែលបានកើតឡើង ព្រោះយើង -- ព្រោះលោកដឹងហើយថា ប្រវត្តិសាស្ត្រគឺវាមានការប្រែប្រួល។ ដូចដែលខ្ញុំបាននិយាយនៅក្នុងសៀវភៅចុងក្រោយរបស់ខ្ញុំអ៊ីចឹង មិនមែនជាពាក្យចុងក្រោយទេ ប៉ុន្តែជាសៀវភៅចុងក្រោយរបស់ខ្ញុំ។

[១១:៥១:០២]

**ស៖** ខ្ញុំយល់ស្របជាមួយនឹងអ្វីដែលលោកបាននិយាយ។ បរិបទដែលយើងចង់និយាយថា តើលោកអាចពន្យល់បន្ថែមបន្តិចបានដែរឬទេ អំពីការលាបពណ៌នយោបាយរបស់ភាគី ឬក៏បក្សដែលទទួលបានអំណាចក្រោយឆ្នាំ៧៩ ហើយតើការលាបពណ៌នយោបាយហ្នឹង វាមានផលប៉ះពាល់ ឬក៏វាមានឥទ្ធិពលបែបណាដែលទៅលើការពិភាក្សា ទៅលើការគិតរបស់យើង ក្នុងនាមលោកជាប្រវត្តិវិទូមួយរូបនោះ?

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំទាន់អាលឆ្លើយតប ចាំស្តាប់មតិជំទាស់របស់ភាគីតំណាងសហព្រះរាជអាជ្ញា និង ក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាមុនសិន។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ចារីក៖**

លោកប្រធាន ខ្ញុំសូមជំទាស់ទៅលើសំណួរនេះ។ ពាក្យថា "ការផាត់ពណ៌ ការលាបពណ៌នយោបាយ" គឺវាមិនមានពាក់ព័ន្ធ ឬក៏មិនមានអ្វីពាក់ព័ន្ធទៅនឹងសម័យកម្ពុជាប្រជាធិបតេយ្យ ព្រោះថាយើងមិនមានចាប់អារម្មណ៍អ្វីទៅលើបញ្ហាក្រោយកម្ពុជាប្រជាធិបតេយ្យនោះឡើយ។ យើងគ្រាន់តែចាប់អារម្មណ៍ជាមួយនឹងទស្សនៈរបស់លោកសាស្ត្រាចារ្យទៅលើរចនាសម្ព័ន្ធការដឹកនាំផ្សេងៗតែប៉ុណ្ណោះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីក្រុមតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក អូលីវីយេ បាហ៊្វូញ៖**

សូមអរគុណលោកប្រធាន។ សំណួរនេះមិនត្រឹមតែនាំមុខទេ ហើយសំណួរនេះក៏ថែមទាំងនៅក្រៅបរិបទទៀតផង។ ព្រោះវាស្ថិតនៅក្រោយឆ្នាំ១៩៧៩ ហើយប្រសិនបើយើងគិតទៅលើបទពិសោធន៍របស់ប្រវត្តិវិទូនោះ គឺថាយើងត្រូវតែយោងទៅលើឯកសារជាក់លាក់ ដែលបង្ហាញអំពីអង្គហេតុដែលកើតក្រោយឆ្នាំ៧៩នោះ។

[១១:៥៣:១១]

**លោក ហ្សាស្តេ ប៉ោ៖**

ដើម្បីឆ្លើយទៅនឹងនេះ ខ្ញុំសូមបង្ហាញដូចតទៅនេះលោកប្រធាន។ ខ្ញុំមានហេតុផលដែលខ្ញុំសួរទៅលើសំណួរនេះ ព្រោះថាខ្ញុំចង់ដឹងអំពីទស្សនៈរបស់គាត់ទាក់ទងទៅនឹងហេតុការណ៍ដែលកើតឡើងក្រោយការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ ព្រោះថាផលប៉ះពាល់នេះ វាអាចធ្វើឲ្យប៉ះពាល់ដល់ការយល់ឃើញរបស់យើងនៅពេលក្រោយមក។ ដូច្នេះ ខ្ញុំគ្រាន់តែចង់ដឹងថាតើលោកសាស្ត្រាចារ្យគាត់យល់ឃើញយ៉ាងម៉េចដែរ ថាតើអាច ឬក៏មិនអាច? ហើយវាប៉ះពាល់ទៅដល់សំណុំរឿង ឬក៏ទៅដល់អង្គហេតុនៃសំណុំរឿងនេះ។ យើងបានស្តាប់តាំងពីសប្តាហ៍មុនរហូតមកដល់ថ្ងៃនេះ គឺអំពីការ និយាយ

អំពីភស្តុតាងរបស់វៀតណាម ឬក៏សាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលពួកគាត់ទាំងនោះអាចចូលរួម អាចថាមានការបំផ្លាញទៅលើឯកសារ ឬក៏ភស្តុតាងណាមួយ។

[១១:៥៤:០៤]

ដូច្នេះហើយ អ្វីដែលខ្ញុំនិយាយនេះ គឺវាមានលក្ខណៈច្បាស់លាស់អាចថាមាន ឬក៏មិនមាននូវការផាត់ពណ៌ ការលាបពណ៌នយោបាយ ដោយសាធារណរដ្ឋប្រជាមានិតកម្ពុជាក្នុងនាមគាត់ជាអ្នកប្រវត្តិសាស្ត្រក្នុងនាមជាអ្នកជំនាញខាងប្រវត្តិសាស្ត្រកម្ពុជា។ ដូច្នេះ លោកសាស្ត្រាចារ្យអាចនឹងមានព័ត៌មាន ឬក៏អាចដឹងបានច្រើនអំពីបក្សកុម្មុយនីស្តកម្ពុជា ហើយខ្ញុំចង់ឲ្យលោកសាស្ត្រាចារ្យ ឆេនដ័ល័រ ផ្តល់នូវមតិយោបល់ផ្នែកប្រវត្តិសាស្ត្រ ដោយមិនឲ្យនិយាយអ្វីបន្ថែមពីនេះទៀតទេ ដើម្បីឲ្យគាត់បញ្ជាក់ថា តើក្នុងគំនិតរបស់គាត់ហ្នឹង តើអង្គហេតុហ្នឹងវា -- អង្គហេតុទាំងអស់ដែលយើងមានហ្នឹងត្រូវបានផាត់ពណ៌ ឬក៏ត្រូវបានប្រឡូកប្រឡាក់ដោយសាររបបដែលដឹកនាំក្រោយៗមក គឺរបបដែលបានកាន់អំណាចក្រោយរបបកម្ពុជាប្រជាធិបតេយ្យនោះដែរឬយ៉ាងណា?

ដូច្នេះខ្ញុំគិតថាវាមានការពាក់ព័ន្ធយ៉ាងច្បាស់លាស់ទៅនឹងប្រវត្តិសាស្ត្រ ហើយខ្ញុំមានសិទ្ធិ ឬក៏ខ្ញុំអាចនឹងចោទសួរសំណួរទាំងអស់នេះ ដើម្បីនឹងឲ្យលោកសាស្ត្រាចារ្យគាត់ពន្យល់អំពីប្រវត្តិសាស្ត្រកម្ពុជាដល់យើងបាទ។ ខ្ញុំគិតថា ខ្ញុំអាចសួរបែបនេះបាន។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីការពារក្តី -- ក្រុមតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺអង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកឆ្លើយតបទៅនឹងសេចក្តីតបរបស់ភាគីមួយទៀតទេ។ អង្គជំនុំជម្រះសម្រេចសេចក្តីជំទាស់របស់ភាគីតំណាងសហព្រះរាជអាជ្ញានិងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានប្រសិទ្ធភាព។ សំណួរនេះមិនពាក់ព័ន្ធទេ ហើយក៏គ្មានមូលដ្ឋានសំអាងជាក់ច្បាស់ដែរ គឺជាការសួរដោយការប៉ាន់ស្មាន អត្តនោម័តិផ្ទាល់ខ្លួនប៉ុណ្ណោះ។ លោកអ្នកជំនាញមិនបាច់ឆ្លើយតបទៅនឹងសំណួរចុងក្រោយរបស់មេធាវីការពារក្តីលោក នួន ជា នេះទេ។

សូមអញ្ជើញលោក ម៉ែខល កាណាវាស!

[១១:៥៦:២២]

**លោក ម៉ែខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីទាំងអស់នៅក្នុងនិងក្រៅ -- នៅ

ក្នុងសាលសវនាការ។ ប្រសិនបើយើងនិយាយអំពីការកើតឡើងអំពីការលាបពណ៌នយោបាយ ហើយការលាបព៌ណនេះវាអាចនឹងមានផលប៉ះពាល់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចបញ្ហានេះរួចហើយ ដូច្នេះអង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកនិយាយបញ្ហាដដែលនេះទៀតទេ មានបញ្ហាថ្មីទើបអង្គជំនុំជម្រះអនុញ្ញាត។

អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅមេធាវីការពារក្តីលោក នួន ជា។

**លោក ម៉ែខល កាណាវាស៖**

ប្រសិនជាអនុញ្ញាត ខ្ញុំ--

**ប្រធានអង្គជំនុំ៖**

បញ្ហាដដែលអង្គជំនុំជម្រះសម្រេចរួចហើយ។ អង្គជំនុំជម្រះមិនផ្តល់វេទិកាឲ្យលោកនិយាយបញ្ហាដដែល ដែលអង្គជំនុំជម្រះបានសម្រេចរួចហើយទេ ជាការរំខានដល់ពេលវេលានៃកិច្ចដំណើរការសវនាការ។

[១១:៥៧:២៥]

**លោក ម៉ែខល កាណាវាស៖**

ខ្ញុំមិនមែនចង់និយាយអំពីប្រធានបទទេ ខ្ញុំគ្រាន់តែចង់ឲ្យលោក លោកស្រីចាប់អារម្មណ៍ជាមួយនឹងបញ្ហាមួយដែលថាយើងមានសិទ្ធិក្នុងការបង្ហាញកំណត់ត្រា។ ខ្ញុំ--

**ប្រធានអង្គជំនុំ៖**

ចាំដល់ពេលលោកមាន -- ត្រូវនិយាយទេ សឹមលោកនិយាយ។

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា អាចបន្តមួយ ឬពីរសំណួរ --មួយសំណួរ ឬពីរសំណួរទៀតមុនពេលសម្រាកអាហារថ្ងៃត្រង់។

[១១:៥៧:៥៧]

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគោរពនូវការសម្រេចរបស់លោក ដែលថាមិនអនុញ្ញាតឲ្យខ្ញុំចោទសួរសំណួរដែលខ្ញុំបានដាក់ពីមុននេះ។ ដូច្នេះ ខ្ញុំស្នើសុំឲ្យមានការសម្រេចដែលមានសំអាងហេតុទៅលើការផ្តល់សិទ្ធិដល់ខាងព្រះរាជអាជ្ញា និងខាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីឲ្យបញ្ជាក់ច្បាស់ថាអង្គជំនុំ

ជម្រះមិនអនុញ្ញាតឱ្យមានការចោទសួរសំណួរបែបនេះ។ បន្ទាប់មកខ្ញុំនឹងបន្តនូវសំណួរបន្ទាប់របស់ខ្ញុំ។ ដូច្នេះសូមឱ្យមានការពិចារណាទៅលើបញ្ហាទាំងអស់នេះឡើងវិញ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចរួចហើយ សេចក្ដីជំទាស់របស់ក្រុមតំណាងសហព្រះរាជអាជ្ញា និងមេធាវីតំណាង -- នាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានប្រសិទ្ធភាព។ សំណួរដែលលោកសួរគឺទី១ គឺក្រៅអង្គហេតុ ទី២ មិនមានភស្ដុតាងណាមួយនៅចំពោះអ្នកជំនាញនេះអំពីបញ្ហាដែលលោកសួរដោយប៉ាន់ស្មាននោះទេ។ លោកមិនបានចង្អុលបង្ហាញអំពីភស្ដុតាងអ្វីជាក់លាក់លើបញ្ហានេះទេ។ អង្គជំនុំជម្រះបានសម្រេចរួចហើយ។

[១១:៥៩:៣២]

**សួរដោយលោក ហ្សាស្ដើ ប៉ោ៖**

**ស៖** ដើម្បីឱ្យមានងាយ -- ដើម្បីមានភាពងាយស្រួលដល់ខ្ញុំក្នុងការបង្កើតសំណួរបន្តទៅទៀតគឺថាយោងទៅលើអ្វីដែលបានចង្អុលបង្ហាញទៅលើឯកសារជាក់លាក់នុ៎ង។ លោកសាស្ត្រាចារ្យ ឆេនដ៍ល័រ នៅពេលដែលលោកនិយាយអំពីការបោសសម្អាត ការបោសកម្ទេចហ្នឹង តើលោកនិយាយអំពីមូលហេតុរបស់ប្រទេសវៀតណាមដែលធ្វើបែបនេះដែរ ឬមួយក៏យ៉ាងណាដែរ។ ដូចដែលយើងនិយាយអំពីសាធារណរដ្ឋប្រជាមានិតកម្ពុជា អាចថាពួកគាត់មានការចូលពាក់ព័ន្ធទៅក្នុងបញ្ហានេះ ឬមួយក៏អត់យ៉ាងណា។ សំណួររបស់ខ្ញុំដែលចង់សួរគឺថា តើលោកគិតថា ការបំបាត់ឯកសារ ដែលជាឯកសាររបស់របបកម្ពុជាប្រជាធិបតេយ្យហ្នឹងគឺទទួលឥទ្ធិពលពីការផាត់ពណ៌នយោបាយ -- ការលាបពណ៌នយោបាយរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាដែរ ឬមួយក៏យ៉ាងណា?

[១២:០០:៤២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

ជាបឋមហ្នឹង និយាយពាក្យថា បំបាត់ ឬក៏ បំផ្លាញឯកសារនេះជាសេចក្ដីសន្និដ្ឋាន ដែលលោកសាស្ត្រាចារ្យមិនបាននិយាយ។ និយាយពីការបកស្រាយអំពីការលើកឡើងថា ហេតុការណ៍ហ្នឹងមាន ឬមិនមានហ្នឹងគឺថា មេធាវីលើកសំណួរនេះគឺមិនសមស្របនៅក្នុងបរិបទនេះទេ។ ទាក់ទងទៅនឹងសក្ខីកម្ម

របស់លោកសាស្ត្រាចារ្យ ដេវីដ ឆេនដ៍ល័រ នេះបាទ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក អូលីវីយេ បាហ៊្វួញ៖**

សូមអរគុណលោកប្រធាន។ ខាងមេធាវីការពារក្តី គាត់នៅតែបន្តសួរសំណួរដដែល គឺសំណួរដែលពាក់ព័ន្ធទៅនឹងអំពើដែលបានកើតឡើងក្រោយឆ្នាំ៧៩ ហើយគាត់សន្មតថាមានការបំផ្លាញភស្តុតាងដោយយើងមិនដឹងច្បាស់ ជាពិសេសគឺថាមានការបំផ្លាញឯកសារដែលគាត់គិតថា ជាភស្តុតាង។ ដូច្នេះវាចេញក្រៅបរិបទហើយ ហើយវាជាការស្មានទេលោកប្រធាន។ សូមអរគុណ។

[១២:០២:០១]

**សួរដោយលោក ហ្វាស្តេី ប៉ោ៖**

**ស៖** ដើម្បីឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញា ហើយនិងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនោះ សាស្ត្រាចារ្យ ឆេនដ៍ល័រ ពួកគាត់លើកឡើងថា យើងនិយាយស្មានអំពីការបំផ្លាញឯកសារ ឥឡូវនេះយើងចង់ដឹងពីលោកសាស្ត្រាចារ្យ ដេវីដ ឆេនដ៍ល័រ ថាតើសក្ខីកម្មទាំងអម្បាលម៉ានពីខាងដើមហ្នឹងតើលោកឆ្លើយដោយពិតប្រាកដ ឬក៏ដូចម្តេច? ដោយសារលោកឆ្លើយដោយប្រុងប្រយ័ត្ន ពេលខ្លះយក -- លោកបដិសេធ ហើយជាពិសេសទាក់ទងទៅនឹងចម្លើយសារភាពមួយចំនួនត្រូវបានបំផ្លាញ ហើយគាត់មិនឆ្លើយដោយស្មានទេ។ គាត់បានផ្តល់នូវព័ត៌មានជាទស្សនៈ ក្នុងឋានៈជាអ្នកជំនាញ ជាប្រវត្តិវិទូ។

ហើយចំណុចមួយទៀតដែលសំខាន់នោះ នៅពេលដែលមើលចម្លើយរបស់គាត់ គាត់បានធ្វើការស្រាវជ្រាវមុនដំបូងទៅលើឯកសារកម្ពុជាប្រជាធិបតេយ្យ។ គាត់បានសម្ភាសមនុស្សជាច្រើន ដូចជាជនអៀសខ្លួន ហើយនិងអ្នកដែលប្រមូលឯកសារជាដើម ហើយគាត់អាចនឹងផ្តល់មតិយោបល់។ ហើយដែលសេចក្តីដកស្រង់សម្តីរបស់គាត់នោះ ក៏ដូចឆ្លើយតបទៅនឹងតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺថា ខ្ញុំសួរសំណួរអំពីអង្គហេតុដែលមុន ឬក៏កើតឡើងក្រោយកម្ពុជាប្រជាធិបតេយ្យដើម្បីកត់ត្រាតុលាការ។

[១២:០៣:៣៨]

យើងនិយាយទីនេះ គឺនិយាយអំពីឯកសារដែលចេញមកពីសម័យកម្ពុជាប្រជាធិបតេយ្យ ហើយយ៉ាងហោចណាស់គឺ អនុលោមទៅតាមមតិរបស់លោក ដេវីដ ឆេនដ៍ល័រ ឬក៏សម្តីរបស់មនុស្ស ឬក៏ឌី.ស៊ី.ខេម ហើយដែលប្រមូលមកពីសម័យកម្ពុជាប្រជាធិបតេយ្យ។ ហើយមិនប្តូរប្រធានបទទេ ទោះបី

ជាសម័យកាលហ្នឹងក្រោយ១៩៧៩ ក៏ដោយ បើភស្តុតាងដែលយកមកប្រើនៅក្នុងការជំនុំជម្រះនេះ វាអាចថាឯកសារមួយចំនួនត្រូវបានបំផ្លាញ ឬក៏អាចបំប្លែង ឬក៏ -- យើងចង់ដឹងពីប្រភពប្រវត្តិសាស្ត្រ ថាតើអ្នកប្រវត្តិសាស្ត្រផ្សេងៗ តើគាត់ពឹងផ្អែក -- នេះគឺជាប្រវត្តិ អ៊ំ! សំណួរទាក់ទងនឹងប្រវត្តិសាស្ត្រ ហើយគាត់អាចនឹងទាក់ទងទៅនឹងយោបល់របស់គាត់នៅក្នុងចំណុចនេះបានបាទ។

[១២:០៤:៤០]

*(ចៅក្រមពិភាក្សាគ្នា)*

[១២:០៨:៣៥]

**ប្រធានអង្គជំនុំ៖**

បាទ ក្រោយពីពិភាក្សានៅក្នុងក្រុមប្រឹក្សានៃអង្គជំនុំជម្រះ។ អង្គជំនុំជម្រះយល់ឃើញថា ដើម្បីឲ្យច្បាស់លាស់លើបញ្ហានេះ គប្បីឲ្យលោកអ្នកជំនាញឆ្លើយតបទៅនឹងសំណួរដែលសួរចុងក្រោយដោយមេធាវីអន្តរជាតិការពារក្ដីលោក នួន ជា។ បើសិនជាក្នុងនាមលោកសាស្ត្រាចារ្យជាអ្នកជំនាញប្រវត្តិសាស្ត្រនុ៎ង អាចឆ្លើយជាក់ច្បាស់ទៅនឹង តបទៅនឹងសំណួរនេះបាន។ ហើយអង្គជំនុំជម្រះបដិសេធលើសេចក្ដីជំទាស់របស់ក្រុមតំណាងសហព្រះរាជអាជ្ញា និងមេធាវីនាំតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

សូមអញ្ជើញលោកសាស្ត្រាចារ្យអាចឆ្លើយតបទៅនឹងសំណួរដែលសួរចុងក្រោយ ដោយមេធាវីអន្តរជាតិការពារក្ដីលោក នួន ជា។

[១២:០៩:៣៨]

**លោក ដេវីដ ឆេនដ្លឺរ៖**

**ឆ៖** បាទ ខ្ញុំនឹងឆ្លើយ។ ប្រហែលជាច្រើនពេកដែលលោកលើកឡើងអំពីការបំផ្លាញឯកសារហ្នឹងគឺថាអាចនឹងជាការសន្និដ្ឋាន។ យើងមិនបានឃើញថាមានការបំផ្លាញឯកសារ តែមានឯកសារខ្លះរាត់រាយមែន ប៉ុន្តែខ្ញុំមិនចងចាំសក្ខីកម្មរបស់ខ្ញុំនៅក្នុងសំណុំរឿង០០១ នៅពេលមេធាវី ឌុច សួរខ្ញុំ ថាតើឯកសារអីខ្លះនៅក្នុងបណ្ណសារដែលរកមិនឃើញនោះ។ ខ្ញុំត្រូវតែឆ្លើយថា ខ្ញុំពិបាកប្រាប់ណាស់ ថាតើឯកសារអីខ្លះដែលមិនបានរកឃើញនោះ។ ដូចគ្នា ហើយយើងមិនដឹងថា តើឯកសារនេះទៅណា? មិនដឹងថាឯកសារអីបានបាត់បង់ យើងមិនដឹងថាមានអ្វីខ្លះក្នុងឯកសារ។ យើងមិនដឹងថា ហេតុអ្វីបានគេបំផ្លាញ តើមានការបំផ្លាញ ឬអត់? នៅពេលដែលវៀតណាមបានពិនិត្យមើលឯកសារ ហើយឯកសារមួយចំនួនយើងមិនដឹងច្បាស់ថា ផ្នែកណាដែលបាត់។ គេបានយកឯកសារខ្លះ ហើយដែលគេ -- ដែលគេ

មិនគិតថា បំពេញសេចក្តីត្រូវការរបស់គេ។ ឯកសារភាគច្រើនណាស់ដែលនៅសល់អំពីរបបកម្ពុជាប្រជាធិបតេយ្យ ដែលយើងអាចៗនិយាយបានថា ជាឯកសារប្រភពដ៏សំខាន់។

[១២:១០:៥៤]

ខ្ញុំមិនអាចយកថា ការបំផ្លាញឯកសារនៃបញ្ហាសំខាន់នោះទេ ព្រោះវាថាភស្តុតាងមួយចំនួននោះយើងមិនដឹងថាមានគេយកទៅអ្វី? ឬក៏របបកម្ពុជាប្រជាធិបតេយ្យដុតចោលខ្លួនឯង ឬក៏គេយកចេញទៅចាកសោនៅកន្លែងណាមួយ ខ្ញុំមិនអាចឆ្លើយបានទេ។ ខ្ញុំមិនដឹងថា បញ្ហាហ្នឹងវាត្រូវដោះស្រាយដោយរបៀបម៉េចទេ ប៉ុន្តែខ្ញុំនឹងឆ្លើយ ខ្ញុំមិនបានត្រៀមខ្លួនដើម្បីឆ្លើយពិស្តារអ្វីបានពីបញ្ហានេះទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកសាស្ត្រាចារ្យ។ អរគុណលោកមេធាវី។ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ហើយចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សឹមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

[១២:១១:៤២]

មន្ត្រីរដ្ឋបាលតុលាការសម្រាបសម្រួលកន្លែងសម្រាកនៅបន្ទប់សម្រាក សម្រាប់សាក្សីអ្នកជំនាញដល់លោកសាស្ត្រាចារ្យក្នុងអំឡុងពេលសម្រាកពិសាអាហារថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅរសៀលនេះនៅវេលាម៉ោងមួយសាមសិបនាទី។

សូមអញ្ជើញលោកមេធាវី!

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជម្រាបលោកប្រធានថា លោក នួន ជា សូមអនុញ្ញាតទៅតាមដានសវនាការនៅបន្ទប់ឃុំខ្លួនខាងក្រោម ដោយសារគាត់ឈឺក្បាល ហើយគាត់មានបញ្ហាក្នុងការផ្តង់អារម្មណ៍ ហើយនិងឈឺខ្នងផងដែរ។ ហើយយើងខ្ញុំនឹងដាក់ជូននៅលិខិតលះបង់សិទ្ធិរបស់គាត់ទៅតាមនីតិវិធីរបស់តុលាការ។

[១២:១២:៣២]

**ប្រធានអង្គជំនុំ៖**

បានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តី

របស់គាត់ស្នើសុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់រយៈពេលពេញមួយរសៀលនេះ ដោយមូលហេតុជនជាប់ចោទមានអាការៈឈឺក្បាល ថមថយនូវលទ្ធភាពផ្តង់អារម្មណ៍ក្នុងការតាមដានកិច្ចដំណើរការសវនាការ។ ដោយក្រុមមេធាវីការពារក្តីបានសន្យាថាខ្លួននឹងប្រគល់មកឲ្យអង្គជំនុំជម្រះនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់ជនជាប់ចោទ នួន ជា។

អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលស្នើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយរសៀលនេះ។ ដោយលោក នួន ជា គាត់បានលះបង់សិទ្ធិចូលរួមកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

អង្គជំនុំជម្រះម្រូវឲ្យក្រុមមេធាវីការពារក្តីលោក នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ នួន ជា។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់មកស្ថិតនៅក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការនៅរសៀលនេះ។

ហើយបង្គាប់ឲ្យផ្នែកអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ខាងក្រោមសាលសវនាការនេះ ដោយនៅរសៀលនេះទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចតាមដានកិច្ចដំណើរសវនាការពីចម្ងាយ។

ដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់ឡើងមកកាន់បន្ទប់សវនាការវិញឲ្យបានមុនម៉ោងមួយសាមសិបនាទីរសៀល។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:១៤ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:៣៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ជាបន្តទៅនេះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។ សូមអញ្ជើញ!

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**ស៖** លោកសាស្ត្រាចារ្យ ឆេនដ័ល័រ យើងបាន -- នៅមុនសម្រាកនោះគឺយើងបានទុកចំណុចដែលយើងនិយាយអំពីឆ្នាំមួយពាន់ -- ទសវត្សរ៍ឆ្នាំ១៩៨០ ថាតើសាធារណរដ្ឋប្រជាមានិតកម្ពុជានោះមានជាប់ពាក់ព័ន្ធទៅនឹងការប្រមូលឯកសារ និងការបំផ្លាញឯកសារដែរឬទេ?

[១៣:៣២:៤៧]

ខ្ញុំចង់ត្រឡប់ទៅការពិភាក្សាកាលពីព្រឹកមិញរបស់យើងឡើងវិញ។ កាលពីព្រឹកមិញខ្ញុំបានសួរ -- ចាប់ផ្តើមសួរលោកទៅលើប្រធានបទនេះ។ យើងបានពិភាក្សាទៅលើសេចក្តីប្រកាសរបស់លោក និងចំណុចយោងនៅក្នុងសៀវភៅរបស់លោក ដែលថាសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា គឺធ្វើការងារទៅលើកំហឹង ដែលគេចងទៅលើរបបកម្ពុជាប្រជាធិបតេយ្យ។ តើលោកបានដឹងដែរ ឬទេនៅពេលនោះ? ហើយតើលោកឯកភាពជាមួយនឹងសេចក្តីប្រកាសនេះដែរឬទេ ដែលថារដ្ឋាភិបាលនៅពេលនេះគឺធ្វើការងារយ៉ាងខ្លាំង ដើម្បីឲ្យមានការចងកំហឹងទៅលើបន ប៉ុល ពត, អៀង សារី? ហើយជាពិសេសនោះគឺនៅក្នុងសមាជិករដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជានៅពេលនោះ ក៏មួយចំនួននោះធ្លាប់ជាខ្មែរក្រហមផងដែរ។ តើលោកឯកភាព និងយល់យ៉ាងម៉េចទៅលើសេចក្តីប្រកាសនោះ?

[១៣:៣៣:៥៨]

**លោក ដេវីដ ឆេនដ័ល័រ៖**

**ឆ៖** ខ្ញុំមិនអាចធ្វើការចង្អុលយោងទៅលើចំណុចហ្នឹងទេ គេបានលើកឡើងថា គេមិនបានលើកឡើងអំពីបញ្ហាសន្តិភាពនោះទេ ហើយវាមានចំណុចសង្ស័យមួយចំនួន។ ហើយការដែលគេលើកឡើងអំពីបនប្រល័យពូជសាសន៍ ប៉ុល ពត នោះគឺជាចំណុចមួយដែលគេអាចឲ្យសង្គមនេះដើរទៅមុខ។ ក៏ប៉ុន្តែចំពោះសេចក្តីប្រកាសនេះ គឺខ្ញុំក៏មិនបានដឹងអំពីការរៀបចំសកម្មភាពឲ្យប្រជាជនគិតដូច្នោះនោះដែរ។

**សៈ** ខ្ញុំសូមបង្ហាញនៅលើអេក្រង់ម្តងទៀត ឯកសារដដែលដែលយើងបានពិភាក្សាកាលពីព្រឹកមិញ។ ERN ជាភាសាអង់គ្លេសគឺ 00192688, ខ្មែរ 00191839។ សូមអនុញ្ញាតពីលោកប្រធានដាក់នៅលើអេក្រង់ ដែលយើងបានពិភាក្សាហើយម្តងរួចមកហើយចំពោះឯកសារនេះ។ សូមអនុញ្ញាតពីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**សៈ** លោក ឆេនដ័ល័រ នេះគឺជាការដកស្រង់ចេញពីសៀវភៅ "សំឡេងពីមន្ទីរស-២១"។ ខ្ញុំសូមដកស្រង់សម្តីចេញពីសៀវភៅនេះ ដើម្បីឲ្យមានការបញ្ជាក់បំភ្លឺឲ្យបានច្បាស់លាស់ ខ្ញុំចាប់ផ្តើមត្រង់ជួរដូចតទៅ៖ "របបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានផ្តោតអារម្មណ៍ បានពុះពារយ៉ាងខ្លាំង ដើម្បីផ្តោតអារម្មណ៍របស់ប្រជាជន ទៅលើការចងកំហឹងចំពោះបនប្រល័យពូជសាសន៍ដែលកាន់អំណាចពីខែមេសា ឆ្នាំ៧៥ ដល់ខែមករា ៧៩។ តាមការពិតព្រោះតែរដ្ឋាភិបាលថ្មី ផ្អែកទៅលើភាពស្របច្បាប់ដែលថាខ្លួនជាអ្នកផ្តួលរំលំពួកខ្មែរក្រហមនោះ រដ្ឋាភិបាលមិនប្រកាន់យកនូវគោលជំហរផ្តន្ទាទោសចលនាទាំងមូលឡើយ ព្រោះឥស្សរជនដែលសំខាន់ៗនៃរបបថ្មីភាគច្រើន ក៏ជាខ្មែរក្រហមដែលផ្តាច់ខ្លួនរត់ទៅប្រទេសវៀតណាមនៅឆ្នាំ៧៧ និង៧៨ផងដែរ"។

លោកសាស្ត្រាចារ្យ ឆេនដ័ល័រ នៅពេលដែលខ្ញុំអានចំណុចនេះចំពោះខ្ញុំ ខ្ញុំយល់ឃើញថាជំហររបស់លោកដែលលើកឡើងក្នុងសៀវភៅនេះ គឺថាប្រភពខ្មែរក្រហមគឺសមាជិករបស់សាធារណរដ្ឋប្រជាមានិតកម្ពុជានោះ ក៏ជាសមាជិកមួយនៅក្នុងខ្មែរក្រហម ហើយគេបានធ្វើសកម្មភាពឲ្យប្រជាជនចងកំហឹងទៅលើខ្មែរក្រហម ប្រល័យ -- អំពើបនប្រល័យពូជសាសន៍នោះ។ តើលោកឯកភាពទៅលើអ្វីដែលខ្ញុំលើឡើងនេះដែរឬទេ?

[១៣:៣៧:១៣]

**ឆៈ** ខ្ញុំសូមបញ្ជាក់ថា ចម្លើយរបស់ខ្ញុំលើកឡើងនេះ គឺថាអតីតខ្មែរក្រហម គឺបានរត់ចេញពីចលនានេះ ដោយសារតែពួកគេជាអតីតខ្មែរក្រហម ហើយពួកគេក៏មិនទទួលរងនូវការកាប់សម្លាប់ពីវៀតណាមដែរចំពោះសមាជិកមួយចំនួនរបស់ខ្មែរក្រហម។ អតីតសមាជិករបស់សាធារណរដ្ឋប្រជា-មានិតកម្ពុជាមួយចំនួននោះ គឺគេមិនបានរត់ទៅវៀតណាមនោះទេ ហើយក៏គេជាសមាជិករដ្ឋាភិបាល

នៅក្នុងសម័យនោះ។ ហើយសមាជិកទាំងអស់នោះមួយចំនួន គេបានលើកឡើងថា ពួកគេមិនមានការស្មោះស្ម័គ្រនឹងខ្មែរក្រហមទៀតនោះឡើយ។ ដូច្នេះចំណុចនេះ គឺដើម្បីឲ្យគេអាចទទួលអនុគ្រោះទោសពីប្រជាជន ហើយគឺធ្វើយ៉ាងណាឲ្យគេអាចធ្វើ -- នៅរស់នៅទីក្រុងភ្នំពេញ ហើយកាន់កាប់តំណែងនៅពេលនោះបាន។ ប្រជាជនមួយចំនួន សមាជិកមួយចំនួននោះ គឺគេបានសុំការជ្រកកោន ហើយមួយចំនួនបានរត់ទៅវៀតណាម។

[១៣:៣៨:២២]

**ស៖** លោកបានលើកឡើងថា ហ៊ុន សែន បានរត់គេចមុនគេ មុនអ្នកដទៃទៅប្រទេសដទៃនោះ។ តើលោកអាចបញ្ជាក់ថា រត់ចេញឆ្នាំណាដែរ? នៅពេលណាដែរ ដែល ហ៊ុន សែន និងមេដឹកនាំផ្សេងទៀតរត់ទៅវៀតណាមនោះ? តើក្នុងឆ្នាំណាដែរ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំស្ទាក់ស្ទើរក្នុងការកាត់នៅពេលនេះណាស់ ក៏ប៉ុន្តែខ្ញុំមិនគិតថា សំណួរនេះគឺវាពាក់ព័ន្ធទៅនឹងការតាំងសំណួរ និងវគ្គសវនាការរបស់យើងនោះទេ។ យើងគឺត្រូវផ្តោតទៅលើរចនាសម្ព័ន្ធរដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ និងគោលនយោបាយខ្មែរក្រហមដែលឧក្រិដ្ឋកម្មបានប្រព្រឹត្តឡើង។ ដូច្នេះហើយខ្ញុំគិតថាអ្វីដែលសួរនេះ គឺមិនពាក់ព័ន្ធទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះឡើយ។

**លោក ហ្សាស្តេី ប៉ោ៖**

ដើម្បីជាការឆ្លើយតប ខ្ញុំសូមបញ្ជាក់ថា ជំហររបស់មេធាវីការពារក្តីបញ្ជាក់ថា អ្វីដែលកើតឡើងក្រោយ៧៩ ឆ្នាំ៧៩នោះ រួមទាំងការកើតឡើងក្នុងទសវត្សរ៍ក្នុងឆ្នាំ៨០នោះ ក៏ពាក់ព័ន្ធទៅនឹងអ្វីដែលយើងយកមកពិភាក្សាក្នុងរយៈពេលពីរថ្ងៃនេះផងដែរ។ បុគ្គលមួយចំនួន ដែលយើងបាននិយាយជាមួយហើយជាមន្ត្រីជាន់ខ្ពស់នៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាក្នុងទសវត្សរ៍ទី៨០នោះ ក៏មានអំណាច និងជាឥស្សរជនសំខាន់នៅក្នុងកម្ពុជានាពេលបច្ចុប្បន្ន ហើយគេក៏យល់អំពីចលនា និងហេតុផលពាក់ព័ន្ធទៅនឹងខ្មែរក្រហមនៅពេលនោះផងដែរ។ ដូច្នេះហើយវាពាក់ព័ន្ធទៅនឹងអង្គហេតុ ដែលយើងយកមកពិភាក្សានៅពេលនេះ។ ខ្ញុំមិនសូមលើកឈ្មោះនោះទេ ចំពោះបុគ្គលដែលខ្ញុំសួរនោះ ក៏ប៉ុន្តែខ្ញុំសូមឲ្យលោកសាស្ត្រាចារ្យឆ្លើយទៅនឹងសំណួររបស់ខ្ញុំ។ យើងឃើញយ៉ាងច្បាស់ថា វាមានការបែង

ចែកយ៉ាងច្បាស់នៅក្នុងប្រវត្តិសាស្ត្រ ហើយលោកសាស្ត្រាចារ្យប្រហែលជាឯកភាពជាមួយខ្ញុំ ដែលថាមានការបែងចែកគ្នាយ៉ាងច្បាស់ចំពោះបក្សដែលនៅឆ្នាំ៨០ និងនៅក្នុងពេលបច្ចុប្បន្ន។ ដូច្នេះហើយអង្គហេតុទាំងឡាយដែលពាក់ព័ន្ធនៅក្នុងទសវត្សរ៍ឆ្នាំ៨០ នោះគឺវាមានការពាក់ព័ន្ធដែលទាក់ទងនឹងសំណួរដែលខ្ញុំចង់សួរ។ ដូច្នេះ បន្ទាប់មកខ្ញុំនឹងសួរសំណួរបន្ទាប់ៗទៀត ដើម្បីឱ្យយើងយល់ច្បាស់ទាំងអស់គ្នាថា ហេតុអ្វីបានជាសំណួរជាក់លាក់មួយនេះពាក់ព័ន្ធទៅនឹងអង្គហេតុរបស់យើង។ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៤១:២៨]

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់ និងសំអាងហេតុ នៃសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិមានមូលហេតុត្រឹមត្រូវ។ សេចក្តីជំទាស់នេះមានប្រសិទ្ធភាព។ អ្នកជំនាញមិនចាំបាច់ឆ្លើយតបទៅនឹងសំណួរដែលសួរដោយមេធាវីអន្តរជាតិការពារក្តីលោក នួន ជា សំណួរចុងក្រោយនេះទេ។

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

**ស៖** ដូច្នេះខ្ញុំនឹងបន្តទៅមុខទៀត ទៅសំណួរបន្ទាប់។ ជាថ្មីម្តងទៀត គឺខ្ញុំផ្អែកទៅលើការចំណេះដឹងរបស់លោក ផ្អែកទៅលើប្រវត្តិសាស្ត្រ ស្តីអំពីប្រទេសកម្ពុជា។ លោកបានរៀបរាប់កាលពីអតីតកាលនូវសញ្ញាណនៃការកាត់ទោសមេដឹកនាំខ្មែរក្រហម ហើយវាជាការអាម៉ាស់ចំពោះរបបបច្ចុប្បន្ននៃប្រទេសកម្ពុជា។ ដូច្នេះខ្ញុំសូមសួរបញ្ជាក់ជាមួយលោក ថាតើនេះជាមតិទស្សនៈរបស់លោក ឬក៏មិនមែនទេ?

**លោក ដេវីដ ឆេនដ័ល័រ៖**

**ឆ៖** ខ្ញុំមិនច្បាស់ចំពោះចម្លើយដូច្នេះនោះទេ។ ថា ខ្ញុំបាននិយាយ ឬក៏មិនបាននិយាយជាមួយនឹងអ្នកកាសែត។ ខ្ញុំបាននិយាយអំពីការជំនុំជម្រះ ហើយគឺខ្ញុំក៏បានលើកអំពីយោបល់នេះនៅក្នុងបរិបទមួយចំនួន ក៏ប៉ុន្តែខ្ញុំមិនមែននិយាយសំណួរណាមួយដោយមិនផ្អែកទៅលើបរិបទនោះឡើយ។

[១៣:៤៣:០៧]

**ស៖** ខ្ញុំមិនចង្អុលយោងទៅលើឯកសារណាមួយនោះទេ។ ក៏ប៉ុន្តែខ្ញុំគ្រាន់តែចង់សួរលោកនៅក្នុងបរិបទនៃសំណួរនេះ តើលោកឯកភាពដែរឬទេ ចំពោះសេចក្តីថ្លែងការណ៍ ឬសេចក្តីប្រកាសដែលបានលើកឡើងថា ការដាក់ជំនុំជម្រះខ្មែរក្រហមនោះ វាអាចជាអាម៉ាស់ទៅដល់របបបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា?

**ប្រធានអង្គជំនុំ៖**

ឈប់សិនលោក! សំណួរនេះឥតមានពាក់ព័ន្ធទេ។ ដូច្នេះអ្នកជំនាញមិនចាំបាច់ឆ្លើយតបទៅនឹងសំណួររបស់មេធាវីការពារក្តី នួន ជា ទេ។ ហើយអង្គជំនុំជម្រះសូមសួរទៅមេធាវីការពារក្តីនួន ជា តើលោកត្រូវការពេលវេលាប៉ុន្មានទៀត ក្នុងការតាំងសំណួរដេញដោលចំពោះអ្នកជំនាញរូបនេះ? ហើយតើមានការបែងចែកច្បាស់លាស់ទេ រវាងពេលវេលាដែលបានបែងចែកឲ្យពីរថ្ងៃកន្លះសម្រាប់ក្រុមមេធាវីទាំងបី? ពីព្រោះលោកហាក់ដូចជាការប្រើប្រាស់នូវពេលវេលា ដែលតាំងសំណួរក្រៅអង្គហេតុកាន់តែច្រើនឡើងៗ ដោយមិនបានប្រើពេលវេលាឲ្យមានប្រសិទ្ធភាពនៅក្នុងការតាំងសំណួរដេញដោលនោះទេ។

[១៣:៤៤:២៣]

**លោក ហ្សាស្តើ ប៉ៅ៖**

សូមអរគុណលោកប្រធាន។ យើងមានរយៈពេលដែលយើងទទួលបាន ហើយយើងបានបែងចែកពេលវេលារួចហើយថាមេធាវី នួន ជា នោះ ទទួលបានរយៈពេលរហូតដល់ម៉ោងបីចុចសាមសិបប្រាំនាទី។ យើងខ្ញុំមានសំណួរមួយចំនួនជាមួយនឹងក្រុមរបស់ខ្ញុំ។ ហើយបន្ទាប់ពីខ្ញុំទៅ លោក អ៊ីនូហ្ស៊ីមានសំណួរបន្ថែមទៀត។ ខ្ញុំយល់ឃើញថា សំណួរដែលខ្ញុំសួរ គឺអាចទំនងជាត្រូវបានជំទាស់ ឬក៏មិនជំទាស់។ ក៏ប៉ុន្តែខ្ញុំសូមសរសេរនៅក្នុង -- លើកឡើងក្នុងប្រតិចារឹកថា វាមិនសមរម្យនោះទេ។ សំណួរដែលខ្ញុំសួរនេះ គឺវាពាក់ព័ន្ធទៅនឹងការជំនុំជម្រះនៅពេលនេះ ហើយខ្ញុំសូមបន្តទៅមុខទៀត។ ប្រធានបទនេះ គឺមិនសួរលើសពី៥នាទីទេ គឺអ្វីដែលខ្ញុំសួរនេះគឺពាក់ព័ន្ធ។

**ប្រធានអង្គជំនុំ៖**

លោកតាំងសំណួរឲ្យបានច្បាស់លាស់។ សំណួរដែលសួររួចហើយនេះ អង្គជំនុំជម្រះបដិសេធរួចហើយ ដោយមិនមានការពាក់ព័ន្ធ ហើយអង្គជំនុំជម្រះបានជម្រាបទៅអ្នកជំនាញថា មិនចាំបាច់ឆ្លើយតបទេ។

[១៣:៤៥:៥៤]

**លោក ហ្សាស្តើ ប៉ៅ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ហ្សាស្តើ ប៉ៅ៖**

**ស៖** ផ្អែកតាមចំណេះដឹងរបស់លោក ទាក់ទងទៅនឹងប្រទេសកម្ពុជា ជាពិសេសប្រទេសកម្ពុជា

ក្នុងទសវត្សរ៍ឆ្នាំ៧០ និងឆ្នាំ៨០។ តួនាទីដែលកាន់កាប់ដោយបុគ្គលមួយចំនួននៅក្នុងទសវត្សរ៍ឆ្នាំ៧០ និងឆ្នាំ៨០នោះ តើលោកភ្ញាក់ផ្អើលដែរឬទេ ដែលថាថ្នាក់ដឹកនាំជាន់ខ្ពស់មួយចំនួននៅក្នុងរាជរដ្ឋាភិបាលកម្ពុជាបានមិនរវល់ទៅលើដីកាកោះអញ្ជើញមកផ្ដល់សក្ខីកម្មនៅចំពោះមុខ អ.វ.ត.ក ហើយចៅក្រម ម៉ាកសែល ឡឺម៉ុងដ៍ នោះក៏បានយល់ឃើញដែរថា--

**ប្រធានអង្គជំនុំ៖**

បាទអ្នកជំនាញមិនចាំបាច់ឆ្លើយតបនឹងសំណួរនេះទេ មិនមែនជាមុខងាររបស់អ្នកជំនាញប្រវត្តិសាស្ត្រទេ ពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក។

[១៣:៤៧:១២]

**លោក ហ្សាស្តេី ប៉ោ៖**

ដើម្បីជាប្រតិចារឹក ខ្ញុំគោរពទៅតាមសេចក្ដីណែនាំរបស់លោកប្រធាន--

**ប្រធានអង្គជំនុំ៖**

លោកអាចតាំងសំណួរផ្សេងទៀតបាន យើងបានសម្រេចរួចហើយ មិនមែនឆ្លៀតយកពេលវេលានេះសម្រាប់ធ្វើប្រតិចារឹកនៅពេលដែលអង្គជំនុំជម្រះសម្រេចរួចហើយនោះទេ។ បើលោកគ្មានសំណួរទេ គឺលោកប្រគល់ឲ្យទៅមេធាវីរបស់លោកផ្សេងទៀត ដើម្បីបន្តការតាំងសំណួរក្នុងន័យដើម្បីសន្សំពេលវេលា ប្រើប្រាស់ពេលវេលាដែលបែងចែកឲ្យ ឲ្យមានប្រសិទ្ធភាព។ ប្រសិនបើអាចធ្វើទៅបាន គឺអាចឆាប់រហ័សជាងពេលវេលាដែលបានបែងចែកឲ្យជាការល្អ ប្រសើរជាជាងការតាំងសំណួរដែលមិនពាក់ព័ន្ធ ឬក៏សំណួរឥតប្រយោជន៍ មិនរួមវិភាគទានដល់ការស្វែងរកការពិតនៃរឿងក្ដី។

[១៣:៤៨:០៤]

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងបន្តទៅមុខទៀត។ ខ្ញុំគិតថាអ្វីដែលខ្ញុំសួរនេះ វាចូលទៅនឹងការដែលខ្ញុំចង់ស្វែងរកការពិតយ៉ាងប្រាកដណាស់។

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

**ស៖** លោកសាស្ត្រាចារ្យ ឆេនដ៍ល័រ លោកបាននិយាយកាលពីមុខរួចមកហើយថា ហ៊ុន សែន គឺពេញចិត្តឲ្យការជំនុំជម្រះនេះធ្វើឡើង ដោយសារតែគាត់ជាអ្នកទទួលបន្ទុកទៅលើលទ្ធផលដែលចេញមកពីការជំនុំជម្រះនោះ។ តើលោកយល់យ៉ាងម៉េចដែរទៅលើការលើកឡើងដូច្នេះ?

**លោក អាប់ឌុលឡាក់ ថារីក៖**

*(គ្មានការបកប្រែ)*

[១៣:៤៨:៤៤]

**ប្រធានអង្គជំនុំ៖**

សូមៗអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

ជាបឋមយើងខ្ញុំសូមជំទាស់ទៅនឹងការតាំងសំណួរ ដែលសួរទៅកាន់លោកសាស្ត្រាចារ្យនេះ។ គឺលោកសាស្ត្រាចារ្យមិនបានមើលសេចក្ដីប្រកាសមុនៗ ដែលបានលើកឡើង ហើយសំណួរនេះក៏វាមិនពាក់ព័ន្ធផងដែរ។ ចេតនារបស់រដ្ឋាភិបាល ហើយសាស្ត្រាចារ្យយល់យ៉ាងណាទៅលើចេតនារបស់រដ្ឋាភិ-បាលនោះ គឺវាមិនទាក់ទងទាល់តែសោះ។

**លោក ហ្សាស្ដេី ប៉ោ៖**

ឆ្លើយតប--

**ប្រធានអង្គជំនុំ៖**

មិនទាន់ដល់វេនលោកទេ។ សូមអញ្ជើញលោកមេធាវីតំណាង -- នាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

[១៣:៤៩:២៨]

**លោក អូលីវីយេ បាហ្ស៊ីញ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់សួរ ថាតើអាចជម្រាបទៅខាងមេធាវីការពារក្ដីឲ្យបានដឹងទេ ថាតើយើងមានដែនកំណត់ប៉ុនណា នៅក្នុងដីកាដំណោះស្រាយនោះ ដើម្បីឲ្យគាត់យល់ ហើយឲ្យគាត់គោរពទៅតាមអ្វីដែលមានចែងនៅក្នុងដីកានោះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញមេធាវី នួន ជា មានអ្វីតបទៅនឹងសេចក្ដីជំទាស់របស់មេធាវី -- អ៎ តបទៅនឹងសេចក្ដីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិដែរឬទេ?

**លោក ហ្សាស្ដេី ប៉ោ៖**

ជាការពិត ខ្ញុំមាន។ មានចំណុចចំនួនពីរឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញា។ ខ្ញុំចង់បង្ហាញ

លោកសាស្ត្រាចារ្យសេចក្តីប្រកាសនេះជាក់ស្តែងតែម្តង ដែលខ្ញុំបានដកស្រង់ចេញមក ក៏ប៉ុន្តែគឺយើងខ្ញុំមិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ឯកសារនោះទេ។ យើងខ្ញុំគ្រាន់តែទទួលបានការអនុញ្ញាតឲ្យផ្អែកទៅលើខ្លឹមសារនៃសេចក្តីប្រកាសនោះតែប៉ុណ្ណោះ។ ដូច្នេះហើយខ្ញុំធ្វើដូច្នេះ ដើម្បីគោរពទៅតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង។ ចំណុចទីពីរ គឺថាអ្វីដែលខ្ញុំព្យាយាមបង្ហាញនេះប្រវត្តិសាស្ត្របក្សកុម្មុយនីស្តកម្ពុជាគឺ វាអាចពាក់ព័ន្ធទៅនឹងសមាជិករបស់គណៈបក្សប្រជាជនកម្ពុជា។ ដូច្នេះហើយវាជាប្រវត្តិសាស្ត្របក្ស ហើយខ្ញុំគ្រាន់តែសួរលោកសាស្ត្រាចារ្យ ឲ្យផ្អែកចម្លើយរបស់គាត់ទៅលើចំណេះដឹងប្រវត្តិសាស្ត្រតែប៉ុណ្ណោះ។ ប្រធានបទនេះ គឺយើងដឹងថាមានការលើកឡើង ដូច្នេះហើយ លោកសាស្ត្រាចារ្យគាត់ទទួលបានឱកាសនេះក្នុងការឆ្លើយតប។ ហើយខ្ញុំធ្វើនេះគឺដើម្បី ព្យាយាមស្វែងរកការពិតតែប៉ុណ្ណោះ។

[១៣:៥១:២០]

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់ របស់តំណាងសហព្រះរាជអាជ្ញាត្រឹមត្រូវ។ សេចក្តីជំទាស់មានប្រសិទ្ធភាព លោកសាស្ត្រាចារ្យមិនបាច់ឆ្លើយតបទៅនឹងសំណួរដែលសួរចុងក្រោយដោយមេធាវីអន្តរជាតិការពារក្តីលោក នួន ជា ទៀតទេ។ លោកមេធាវីអំមិញលោកបានស្តាប់ហើយនូវសំណើសុំរបស់មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី សុំឲ្យលោកមានការពិចារណាក្នុងការតាំងសំណួរដេញដោលពាក់ព័ន្ធទៅនឹងបណ្តាកថាខណ្ឌទាំងឡាយនៅក្នុងដីកាដំណោះស្រាយ ដើម្បីផ្តោះបញ្ចាំងនូវ -- ពាក់ព័ន្ធទៅនឹងដីកាដំណោះស្រាយ នេះជាការល្អ ហើយត្រឹមត្រូវទៅតាមនីតិវិធីមានដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ។

[១៣:៥២:១២]

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនទាន់បានឆ្លើយទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីនៅឡើយនោះទេ។ អង្គហេតុដែលយើងបានលើកឡើងនេះដូចដែលលោកសាស្ត្រាចារ្យ ឆេនដ័ល័រ ឯកភាពទៅនឹងសេចក្តីប្រកាស និងសេចក្តីថ្លែងការណ៍ អម្បាញ់មិញនោះគឺថា អង្គហេតុទាំងអស់នោះវាមានឥទ្ធិពលនិងមានអានុភាពពាក់ព័ន្ធទៅនឹងប្រវត្តិសាស្ត្រនាពេលក្រោយៗ។ ដូច្នេះហើយទើបខ្ញុំព្យាយាមភ្ជាប់ប្រវត្តិបក្សកុម្មុយនីស្ត -- បក្សប្រជាជនកម្ពុជា និងប្រវត្តិបុគ្គលមួយចំនួនដែលពាកព័ន្ធតែប៉ុណ្ណោះ។ ខ្ញុំយល់ថា

តុលាការនេះមិនផ្តល់ឱកាស ឲ្យខ្ញុំសួរសំណួរទាំងនេះទាល់តែសោះ។ ដូច្នេះហើយខ្ញុំត្រូវតែបោះចោលសំណួរទាំងអស់នេះមិនអាចយកមកសួរបានទេ។ ខ្ញុំមានចំណុចតូចពីរទៀត មុនពេលដែលខ្ញុំផ្តល់វេទិកានេះទៅឲ្យ អ៊ីនូហ្សិ៍ ដើម្បីជាប្រតិចារឹក ខ្ញុំគ្រាន់តែចង់ដឹងពីលោកសាស្ត្រាចារ្យ ឆេនដ័ល័រ នៅពេលដែលគាត់ឆ្លើយនោះគឺ មីក្រូហ្វូន គាត់ -- នៅពេលដែលគាត់ឆ្លើយទាក់ទងទៅនឹងថា តើតុលាការនេះអាចជាអាម៉ាស់ទៅដល់រដ្ឋាភិបាលកម្ពុជាដែរឬទេ? មីក្រូហ្វូនរបស់លោកសាស្ត្រាចារ្យមិនបានបើកឆ្លើយតបមកយើងនោះទេនៅពេលគាត់និយាយ។ ដូច្នេះហើយខ្ញុំគ្រាន់តែចង់លើកចំណុចនេះ ដើម្បីជាប្រតិចារឹកតែប៉ុណ្ណោះ។

[១៣:៥៣:៥៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៥៥:៤២]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រី ស៊ីលវៀ ខាតវ៉ាយថ៍ ឆ្លើយតបទៅនឹងបញ្ហាដែលលើកឡើងដោយមេធាវីអន្តរជាតិការពារក្តីលោក នួន ជា ដែលបានលើកឡើងចុងក្រោយអម្បាញ់មិញនេះ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

យោបល់ដែលមេធាវីការពារក្តីលើកឡើងអម្បាញ់មិញនេះ មិនមែនជាផ្នែកមួយនៃកំណត់ប្រតិចារឹកផ្លូវការនោះទេ។ វាជាការព្យាយាមដើម្បីអាចលើកយោបល់ នៅក្នុងវិធីមួយក្រៅផ្លូវការតែប៉ុណ្ណោះ។ លោកសាស្ត្រាចារ្យ មីក្រូហ្វូនរបស់គាត់មិនបើកនោះ ចៅក្រម និងភាគីដទៃទៀត គឺមិនបានស្តាប់ឮ ហើយក៏មិនបញ្ជាក់សរសេរចូលទៅក្នុងប្រតិចារឹកនោះផងដែរ។

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកស្រីចៅក្រម ខាតវ៉ាយថ៍ ដែលបានឆ្លើយបញ្ជាក់ទៅលើចំណុចនេះ។

លោកស្រីប្រើពាក្យថា ជាអកុសល ពាក្យថា -- ចំណុចនេះគឺហាក់ដូចជា វាឲ្យយើងសង្ស័យថាតើលោកសាស្ត្រាចារ្យនោះ បាននិយាយចំណុចដែលគាត់បានលើកឡើង ឬក៏អត់? ដូច្នេះហើយ--

[១៣:៥៦:៥៨]

**ប្រធានអង្គជំនុំ៖**

លោកមានអីសួរទៀតទេ ឬក៏យ៉ាងម៉េច? ឬក៏យក -- អាល័យតែយកវេទិកាហ្នឹងធ្វើអត្ថាធិប្បាយ

ផ្សេងៗក្រៅអង្គហេតុ ក្រៅបញ្ហាដែលត្រូវពិភាក្សា។ វេទិកាដែលអង្គជំនុំជម្រះជូនទៅលោកគឺពិភាក្សាដេញដោលជាមួយនឹងអ្នកជំនាញ ប្រសិនបើមិនមានទេ គឺអាចបញ្ឈប់ត្រឹមនេះ។ យើងមិនផ្តល់លទ្ធភាពឲ្យលោកធ្វើអត្ថាធិប្បាយឯណា ដែលបកស្រាយវែងអន្លាយក្រៅពីការដេញដោលទៅលើអ្នកជំនាញទេ។ យើងដូចប្រាប់លោក ច្រើនលើកច្រើនសាហើយអំពីបញ្ហានេះ។ ទំនងជាអស់សំណួរហើយតាមមើលទៅបានជានិយាយបញ្ហាដែលវា មិនមានប្រយោជន៍ក្នុងការស្វែងរកការពិតបែបនេះ។

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនមែនព្យាយាមធ្វើដូច្នោះនោះទេ ខ្ញុំគ្រាន់តែបញ្ជាក់បំភ្លឺនូវអ្វីដែលខ្ញុំធ្វើតែប៉ុណ្ណោះ--

**ប្រធានអង្គជំនុំ៖**

តើលោកមានសំណួរអីសួរទៀតទេ? យើងមិនអនុញ្ញាតឲ្យលោកធ្វើសេចក្តីថ្លែងការណ៍បែបនេះទេ។

[១៣:៥៨:១៣]

**លោក ហ្សាស្តើ ប៉ោ៖**

លោកប្រធាន។ នៅក្នុងបរិបទដែលសហសេវិករបស់ខ្ញុំ ត្រូវបានដាក់ទណ្ឌកម្ម ហើយមានពាក្យប្តឹងទៅគណៈមេធាវីរបស់គាត់នោះ គឺវាចំណុចសំខាន់ដែលយើងត្រូវតែលើកឡើង ឲ្យមានសរសេរចូលក្នុងប្រតិចារឹក។

**ប្រធានអង្គជំនុំ៖**

យើងអត់ឲ្យលោកធ្វើដូច្នេះទេ។ លោកមិនអាចឆ្លៀតឱកាសដើម្បីធ្វើសេចក្តីថ្លែងការណ៍ ឲ្យខាតពេលពិភាក្សាដេញដោល នៅក្នុងការសួរដេញដោលរបស់ -- ទៅអ្នកជំនាញទេ ព្រោះអ្នកជំនាញមានពេលវេលាខ្លីណាស់។

**លោក ហ្សាស្តើ ប៉ោ៖**

ខ្ញុំគោរពទៅតាមសេចក្តីណែនាំ សេចក្តីសម្រេចរបស់លោកប្រធាន។

ចុងក្រោយ ខ្ញុំសូមលើកឡើងថា លោកសាស្ត្រាចារ្យ ឆេនដ័ល័រ បានឆ្លើយមួយចំនួនតូចដែលហាក់ដូចជា ផ្ទុយទៅនឹងសម្ភារៈឯកសារទាំងឡាយមួយចំនួន ដែលគាត់សរសេរកាលពីអតីតកាល។ យើងខ្ញុំមិនអនុញ្ញាតឲ្យ--

**ប្រធានអង្គជំនុំ៖**

លោកអាចធ្វើជា -- ចង់ធ្វើជាសេចក្តីសន្និដ្ឋាន សូមលោកអនុវត្តតាមវិធាន៩២ នៃវិធានផ្ទៃក្នុង។ សេចក្តីសន្និដ្ឋានពាក់កណ្តាលទី គឺមេធាវីអាចធ្វើជាលាយលក្ខណ៍ -- ត្រូវធ្វើជាលាយលក្ខណ៍អក្សរតាមកំណត់នៃវិធាន៩២ នៃវិធានផ្ទៃក្នុង។

[១៤:00:0២]

យើងអានឡើងវិញ៖ "ការដាក់សេចក្តីសន្និដ្ឋានរហូតដល់ពេលបិទកិច្ចពិភាក្សាដេញដោល រហូតទាល់នឹងបិទកិច្ចពិភាក្សាដេញដោល ភាគីអាចធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ដូចមានចែងនៅក្នុងសេចក្តីណែនាំអនុវត្តពីការដាក់ឯកសារ។ ក្រឡាបញ្ជីអង្គជំនុំជម្រះត្រូវចុះហត្ថលេខា និងចុះកាលបរិច្ឆេទ ទទួលសេចក្តីសន្និដ្ឋាននេះ ហើយត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង"។ បើសិនជាមេធាវីមានបំណងធ្វើសេចក្តីសន្និដ្ឋានបែបនេះ គឺមិនអនុញ្ញាតឲ្យលោកធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់ទេ។ លោកត្រូវធ្វើជាលាយលក្ខណ៍អក្សរតាមវិធាន៩២ នៃវិធានផ្ទៃក្នុង ហើយនិងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ។

[១៤:00:៥0]

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ហើយខ្ញុំក៏សូមជម្រាបផងដែរថា ក្នុងឋានៈជាប្រធានលោកមានការងារសំខាន់ណាស់តាមវិធានផ្ទៃក្នុង ដើម្បីធានាឲ្យមានការជំនុំជម្រះយុត្តិធម៌ ឆាប់រហ័ស ហើយគោរពទៅតាមគោលការណ៍ទាំងអម្បាលម៉ាននោះ។

**ប្រធានអង្គជំនុំ៖**

ទំនងជាលោកអស់សំណួរហើយ លោកនៅតែជាឆ្លៀតឱកាស ឆ្លៀតពេលវេលាដើម្បីធ្វើសេចក្តីថ្លែងការណ៍បែបនេះ។ លោកអាចតាំងសំណួរពាក់ព័ន្ធជាមួយនឹងសារធាតុនៃចំណេះដឹងអំពីប្រវត្តិសាស្ត្រកម្ពុជា ពាក់ព័ន្ធទៅនឹងអ្នកជំនាញប្រវត្តិវិទូ ដេវីដ ឆេនដ៍ល័រ នូវបញ្ហាទាំងឡាយដែលនៅសេសសល់ ដើម្បីឲ្យអស់លទ្ធភាពនៅក្នុងការពិភាក្សាដេញដោលចំពោះអ្នកជំនាញរូបនេះ។

[១៤:0២:0៤]

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។ នេះហើយ ជាចំណុចដែលខ្ញុំចង់បញ្ជាក់ គឺថាមតិយោបល់ខ្ញុំ គឺទាក់

ទងទៅនឹងសក្ខីកម្មរបស់លោក ដេវីដ ឆេនដ័ល័រ។ ខ្ញុំប្រើពេលតែមួយនាទីទេ។ គាត់បានសរសេរឯកសារមួយចំនួនដែលផ្ទុយទៅនឹងចម្លើយដែលគាត់បានឆ្លើយថ្ងៃនេះ ម្សិលមិញ ហើយដូច្នេះហើយ បានយើងប្រើឯកសារដើម្បីផ្ទញ់គាត់--

**ប្រធានអង្គជំនុំ៖**

យើងបានប្រាប់អ្នកឯងហើយ ថានេះសេចក្ដីសន្និដ្ឋានរបស់លោក មិនមែនជាសំណួរទេ។ ឱកាសដែលយើងឲ្យនេះ គឺផ្ដល់ថា វេទិកាទៅភាគីដើម្បីតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។ ចំណែកឯការធ្វើសេចក្ដីសន្និដ្ឋាន បើមានបំណងធ្វើដូច្នេះ ឲ្យលោកអនុវត្តមានវិធាន៩២ នៃវិធានផ្ទៃក្នុង និងនីតិវិធីនៃការដាក់ឯកសារនៅចំពោះអង្គជំនុំជម្រះ។ យើងបានណែនាំរួចហើយ ខ្លឹមសារដែលលោកមានប្រសាសន៍ចុងក្រោយនេះ គឺជាសេចក្ដីសន្និដ្ឋានវាយតម្លៃទៅលើការផ្ដល់សក្ខីកម្មរបស់អ្នកជំនាញ ដេវីដ ឆេនដ័ល័រ។

[១៤:០២:៥៧]

យើងមិនអនុញ្ញាតឲ្យធ្វើលោកដូច្នេះទេ គឺអនុញ្ញាតឲ្យលោកធ្វើជាលាយលក្ខណ៍អក្សរ ដូចមានចែងនៅក្នុងវិធាន៩២ នៃវិធានផ្ទៃក្នុង។ លោកអាចអាននូវវិធាន៩២ នៃវិធានផ្ទៃក្នុងទៅ ដើម្បីឲ្យអស់ចម្ងល់នូវអ្វីដែលលោកមានការប៉ុនប៉ងធ្វើបែបនេះ។ យើងមិនអនុញ្ញាតឲ្យលោកធ្វើបែបនេះទេ។

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់បំភ្លឺបញ្ហានេះ គឺបញ្ហាមួយ។ នេះមិនមែនជាការប្រើនូវឯកសារផ្ទុយគ្នាទេ ចំពោះអ្វីដែលលោកសួរសំណួរនោះ គឺថាត្រូវសួរឲ្យនឹងពាក់ព័ន្ធទៅនឹងបញ្ហា រឿងក្ដី ០០២ និងរឿងក្ដី០០១។ ដូច្នេះ គឺថាយើងមានហេតុផលគ្រប់គ្រាន់ដើម្បីមិនឲ្យលោកបន្តការសួរបែបនេះ។ ប្រសិនបើលោកមានសួរសំណួរដែលពាក់ព័ន្ធ លោកអាចបន្តសួរបាន បើមិនមានទេ លោកមិនអាចសួរបាទេ។ សូមអរគុណលោកប្រធាន។

[១៤:០៤:១៥]

**លោក ហ្សាស្ពើ ប៉ោ៖**

សូមអរគុណលោកស្រីចៅក្រម ខាតវ៉ាយថ៍ ចំពោះការបំភ្លឺនេះ។ ខ្ញុំមិនមានសំណួរអ្វីទៀតទេ នៅដំណាក់កាលនេះ ប៉ុន្តែខ្ញុំចង់ជម្រាបតុលាការថា ខ្ញុំនឹងពឹងផ្អែកលើឯកសារ ដើម្បីសួរផ្ទញ់គាត់ទាក់ទង

ទៅនឹង -- យើងខ្ញុំនឹងធ្វើសារណាលាយលក្ខណ៍អក្សរ ហើយផ្អែកលើឯកសារនោះ ដែលយើងនឹង សូមរក្សាសិទ្ធិ និងសួរសំណួរតាមដានក្រោយទៀត បន្ទាប់ពីយើង -- ប្រសិនបើឯកសារនេះ ត្រូវបានទទួលស្គាល់ដើម្បីប្រើ ដើម្បីជាសួរផ្ទៀងផ្ទាត់ទៅនឹងសាក្សីនេះ ទាក់ទងទៅនឹងសំណួរមួយចំនួន ហើយអាចនឹងធ្វើឡើងបញ្ចប់នៅថ្ងៃនេះ។ ហើយយើងមានពេលថ្ងៃពុធ ទៀតនឹងសួរ ហើយខ្ញុំនឹងជូនដំណឹងជាមុនអំពីផែនការរបស់យើងខ្ញុំ ហើយខ្ញុំបានបញ្ចប់ការសួរសំណួររបស់ខ្ញុំហើយ។ ហើយខ្ញុំរក្សាសិទ្ធិនឹងសួរសំណួរដូចខាងក្រោមបន្តទៅទៀត បើសិនជាឯកសារជាក់លាក់នោះ ត្រូវបានតុលាការទទួលស្គាល់ក្នុងដំណើរការនីតិវិធីនេះ។ ខ្ញុំនឹងរក្សាសិទ្ធិសួរផ្ទៀងផ្ទាត់បញ្ហានេះទៅនឹងសាក្សី។ ឥឡូវនេះខ្ញុំសូមប្រគល់វេទិកានេះទៅលោកមេធាវី អេនគ្រូ អ៊ីនូហ្ស៊ី ជាសហសេវិកខ្ញុំបាទ។

[១៤:០៥:៤៦]

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោក ប្រធាន ប៉ោ សូមជម្រាបសួរលោក លោកស្រីចៅក្រម ហើយខ្ញុំនឹងបន្តសំណួរ ហើយខ្ញុំគោរពទៅតាមគោលការណ៍របស់ខ្ញុំ ហើយខ្ញុំនឹងបញ្ចប់មុនពេលសម្រាក។

**សួរដោយលោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

**ស៖** ហើយសូមសួរទៅលោក ដេវីដ ឆេនដ៏ល័រ ថ្ងៃពុធ ថ្ងៃទី១៨ ខែកក្កដា ខ្ញុំនឹងប្រើប្រតិចារឹកសេចក្តីព្រាង ហើយសូមលោកកែតម្រូវ បើខ្ញុំល្អៀង។ នៅថ្ងៃពុធ យោងទៅរកឯកសារ E3/12 មិនបាច់ចាំមើលឯកសារនោះទេ គឺយើងដឹងហើយថា ឯកសារហ្នឹងគឺជាសេចក្តីសម្រេចរបស់មជ្ឈិមបក្សលើបញ្ហាមួយចំនួន។ លោក និងចៅក្រម ខាតវ៉ាយថ៍ បានពិភាក្សា ឆ្លើយឆ្លងទៅមកក្នុងកម្រិតពិស្តារមួយ។ ខ្ញុំបន្ថយល្បឿន គឺថាសំណួរដែលគេសួរលោកហ្នឹង៖ “ថាតើឯកសារនោះនិយាយថា រដ្ឋាភិបាលត្រូវតែជាអង្គការស្អាតស្អំរបស់បក្ស នេះហើយជាដំណើរការអនុវត្តរបស់បក្ស របស់អង្គការក្នុងការគ្រប់គ្រងប្រទេស ហើយនិងបក្សក៏ដូចគ្នា គណៈអចិន្ត្រៃយ៍ក្នុងប្រទេស?” ហើយលោកឆ្លើយថា៖ “បាទ ហើយមិនមានភាពអ្វីខុសគ្នាទេ លេខារបស់គណៈមជ្ឈិម របស់បក្សកុម្មុយនីស្តកម្ពុជាក៏មានមុខតំណែងហើយគ្រប់ពេលទាំងអស់ជារដ្ឋមន្ត្រី -- ជានាយករដ្ឋមន្ត្រីរបស់ប្រទេស មិនមានការបែងចែកទេ។ មិនមានធាតុផ្សំឲ្យមានតុល្យភាពឯករាជ្យដូចស្ថាប័នណាមួយមាននោះទេ។ ហើយខ្ញុំសូមបញ្ជាក់ដោយស្មោះត្រង់គឺរដ្ឋាភិបាលរបស់ និងគាំទ្របក្សដែលកាន់អំណាច”។ តើនេះត្រឹមត្រូវអ្វីដែលលោកឆ្លើយទៅសំណួរចៅក្រម ខាតវ៉ាយថ៍ ទេ? បាទប្រហាក់ប្រហែលហ្នឹងទេ?

[១៤:០៧:៣៧]

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** បាទ អ៊ីចឹងមែន។

**ស៖** សំណួរចំពោះលោក គឺថាប្រសិនបើលោកសាស្ត្រាចារ្យ ឆេនដ៍ល័រ បើចង់កែភាសានៅក្នុងភាសានោះ គឺថាលេខារបស់បក្សកុម្មុយនីស្តកម្ពុជា ទៅជា១ អនុប្រធានបក្សកុម្មុយនីស្តកម្ពុជាហ្នឹង គឺថាដែលនិយាយថា នយោបាយរបស់កម្ពុជាថ្ងៃនេះដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអភ័យទោសដែលខ្ញុំជំទាស់ទៅនឹងសំណួររបស់មេធាវីទីមួយនេះ គឺថាសំណួរនេះមិនពាក់ព័ន្ធទាល់តែសោះទៅនឹងអង្គហេតុ។

[១៤:០៨:៣១]

**លោក អេនឌ្រូ អ៊ីន្ទូហ្វ៊ី៖**

មិនអ្វីខុសទេ គឺថាវាជាសំណួរស្រប គឺថាសកម្មភាពរបស់កម្ពុជាប្រជាធិបតេយ្យ និងសកម្មភាពរបស់រដ្ឋាភិបាលឥឡូវនេះ គឺថាជាការបន្តមក។ ហើយខ្ញុំគិតថា សំណួរនេះគឺមិនគប្បីជំទាស់នោះទេ។ ឥឡូវនេះខ្ញុំចូលទៅសំណួរមួយទៀត។

**សួរដោយលោក អេនឌ្រូ អ៊ីន្ទូហ្វ៊ី៖**

**ស៖** ដោយសង្ខេបនោះ សាស្ត្រាចារ្យ ឆេនដ៍ល័រ គឺសំណួរបញ្ហាទាក់ទងទៅនឹងការដកឯកសារចេញ ឬក៏ការបំបាត់ឯក -- បំផ្លាញឯកសារ នោះគឺថាយើងសួរមុនពេលសម្រាកពិសាអាហារថ្ងៃត្រង់។ លោកបាននិយាយថា អំពីការដកឯកសារ ឬក៏បំផ្លាញឯកសារមុននឹងយកមកប្រើនៅសវនាការថ្ងៃនេះ។ សំណួររបស់ខ្ញុំខុសពីហ្នឹង។ តើអ្វីជាទស្សនៈអ្នកជំនាញរបស់លោក ទាក់ទងថាប្រសិនបើមានការបំបាត់ឯកសារដោយបុគ្គលណាមួយ បើសិនជាការបំបាត់ហ្នឹងអាចជាអត្ថប្រយោជន៍របស់មេដឹកនាំរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលបន្តកាន់អំណាចរហូតមកដល់សព្វថ្ងៃនេះ? ថាតើ១មានមូលហេតុអ្វីសមស្រប ដែលលោកបានថាការបំបាត់ ការបំផ្លាញឯកសារហ្នឹងជាអត្ថប្រយោជន៍របស់មេដឹកនាំរហូតមកដល់ថ្ងៃនេះនោះ? តើលោកអាចមានមតិយោបល់អ្វីទេ?

[១៤:០៩:៥២]

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលឆ្លើយតបទៅនឹងសំណួរ ចាំស្តាប់អង្គជំនុំជម្រះសម្រេចលើសេចក្តីជំទាស់របស់ភាគីពាក់ព័ន្ធ។ ជាពិសេសនាពេលនេះ គឺភាគីសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ហើយនិងអង្គសវនាការទាំងមូល។ សំណួរដែលបានលើកនេះ គឺជាសំណួរដែលមានលក្ខណៈច្រំដែលផង ហើយវានៅខាងក្រៅអង្គហេតុ ហើយប្រហែលជាមានចេតនានៅក្នុងការលើកសំណួរបែបនេះនៅក្នុងការចំណេញ តេស្ត -- គំនិតរបស់ខ្លួន ហើយអ៊ីចឹងហើយបានយើងខ្ញុំសូមជំទាស់ចំពោះសំណួរបែបនេះ។ ហើយម្យ៉ាងទៀត ខាងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន ច្រើនតែលើកថា តើសវនាការពេលណាចប់? អ៊ីចឹងហើយយើងមានគោលការណ៍ដែលថា សវនាការនេះត្រូវឆាប់រហ័ស។ ដូច្នេះជាសំណូមពរសាជាថ្មី សូមឲ្យលោកប្រធានជួយកម្រិតសំណួរណាដែលថា ពាក់ព័ន្ធ ហើយមានប្រយោជន៍ ហើយនាំឲ្យមានការ -- ដំណើរការឆាប់រហ័សដើម្បីមានសាលក្រមឆាប់រហ័ស ដើម្បីជនរងគ្រោះដែលជាដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងជនរងគ្រោះផ្សេងទៀត។ សូមអរគុណលោកប្រធាន។

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

នេះជាសំណួរដែលពាក់ព័ន្ធ គឺតម្រូវឲ្យមានការសន្មតថា មានការងារដែលអ្នកជំនាញត្រូវតែនិយាយទៅតាមសត្យានុម័តរបស់គាត់ដែលដឹង។ ប្រសិនបើគាត់មិនដឹង អាហ្នឹងគឺជាចម្លើយរបស់គាត់តាមដែលគាត់ត្រូវឆ្លើយនោះឯង។

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់របស់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រឹមត្រូវ។ សំណួរនេះមិនពាក់ព័ន្ធទេ។ សេចក្តីជំទាស់មានប្រសិទ្ធភាព។ អ្នកជំនាញមិនបាច់ឆ្លើយតបទៅនឹងសំណួរដែលសួរចុងក្រោយដោយមេធាវីអន្តរជាតិការពារក្តីលោក នួន ជា នេះទេ។

[១៤:១២:០៦]

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន ហើយខ្ញុំនៅមានសំណួរមួយចំនួនទៀត។ ឥឡូវនេះទៅប្រធានបទ

មួយផ្សេងទៀត នៅឱកាសមួយចំនួនដែលខ្ញុំបានកត់សម្គាល់ថា អតីតកម្មាភិបាលខ្មែរក្រហមដែលគេសួរសំណួរបញ្ហាសកម្មភាពដូច ស្រ៊ុន ដែលចង់ឲ្យពួកគាត់បង្ហាញនូវព័ត៌មាន។ នេះជាបរិបទមួយដែលសំណួររបស់ខ្ញុំសួរទៅលោក ឆេនដ័ល័រ ដូចជាថ្ងៃព្រហស្បតិ៍ ដែលលោកចង់និយាយថា ជាក្រុមមួយដែលមិនគោរពបញ្ហា ហើយដូចជាពាក្យថា "*អូមេតា*" ហ្នឹងគឺ លោកសាស្ត្រាចារ្យដឹងទេ មានភស្តុតាងអ្វីទេថា សាក្សីផ្ទៃក្នុងអតីតខ្មែរក្រហមជាកម្មាភិបាលអាចនឹងមកធ្វើសក្ខីកម្ម អាចនឹងៗធ្វើអ្វីដែលគោរពទៅតាមការរក្សាការសម្ងាត់របស់គេទេ ទោះបីជាអ្នកដែលនៅក្នុងរដ្ឋាភិបាលរាល់ថ្ងៃនេះ ឬក៏អ្នកដែលរដ្ឋាភិបាលការពារ។ ដូច្នេះ គឺថាអាចនឹងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីជំទាស់ ប៉ុន្តែខ្ញុំមិនដឹងថា គាត់ជំទាស់ពីរឿងអ្វី?

[១៤:១៣:៣០]

**ប្រធានអង្គជំនុំ៖**

លោកអ្នកជំនាញកុំអាលទាន់ឆ្លើយតប! ចាំស្ដាប់អង្គជំនុំជម្រះសម្រេចទៅលើសេចក្ដីជំទាស់របស់ក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីជាមុនសិន! សូមអញ្ជើញតំណាងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ បញ្ហាបែបនេះ ត្រូវបានលោកប្រធានសម្រេចជាញឹកញយ ហើយគឺជាបញ្ហាដែលឲ្យអ្នកជំនាញ ឬក៏សាក្សីឆ្លើយអំពីបញ្ហានីតិវិធីរបស់តុលាការ។ អ៊ីចឹងករណីនេះ អ្នកជំនាញ ឬក៏សាក្សីមិនមានសមត្ថកិច្ចនៅក្នុងការឆ្លើយពាក់ព័ន្ធនឹងបញ្ហានេះទេ ហើយខ្ញុំជឿថា សហភាតាខ្ញុំក៏យល់ពីបញ្ហានេះច្បាស់លាស់ដែរ។ អ៊ីចឹងសូម -- ខ្ញុំសូមជំទាស់ចំពោះសំណួរបែបនេះ។ សូមអរគុណ។

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

ខ្ញុំចង់បញ្ជាក់ថា ខ្ញុំចង្អុលបង្ហាញថា គាត់នឹងព្យាយាមតាមដាន គាត់អានកាសែតអំពីសវនាការ ហើយគាត់ពិភាក្សា ប្រសិនបើគាត់មិនដឹង គាត់ឆ្លើយថាមិនដឹង។ ហ្នឹងអាចទទួលយកបាន ប៉ុន្តែគាត់មិនបានឆ្លើយ ហើយគាត់អាចនឹងបញ្ជាក់ ឬក៏បំភ្លឺពីបញ្ហានេះបាន។ បាទ បើសិនជាគាត់មិនដឹងមិនជាបញ្ហាអ្វីទេបាទ។

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់ និងសំអាងហេតុរបស់មេធាវី -- សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រឹមត្រូវ។ សេចក្តីជំទាស់មានប្រសិទ្ធភាព។ អ្នកជំនាញមិនចាំបាច់ឆ្លើយតបទៅនឹងសំណួរដែលសួរឡើងដោយមេធាវីអន្តរជាតិការពារក្តីលោក នួន ជា ដែលសួរលោកចុងក្រោយអម្បាញ់មិញនេះទេ។

[១៤:១៥:១០]

**សួរដោយលោក អេនឌ្រូ អ៊ីនូហ្ស៊ី៖**

**ស៖** ខ្ញុំសូមចូលទៅ ពាក្យមួយចំនួនដែលចេញមកពីចម្លើយរបស់លោកសាស្ត្រាចារ្យ។ លោកសាស្ត្រាចារ្យសំណួររបស់ខ្ញុំនោះ គឺថាតើលោកបានធ្វើការវាយតម្លៃទៅកម្មាភិបាលខ្មែរក្រហម ជាអតីតខ្មែរក្រហមនោះទេ ដែលលោករៀបរាប់ថា គាត់ជាអ្នកជំនាញដែលមានប្រសិទ្ធភាព ដែលមានសមត្ថភាពបំផុត គាត់ស្តាប់ ហើយគាត់មានឱកាស ហើយគាត់កែសម្រួលបាន។ ហើយគឺតាមពិតហើយគាត់មានឈាមប្រលាក់ដៃ ហើយគាត់បានឆ្លងកាត់ហើយ។ គាត់មិនសប្បាយនឹងអ្វីដែលកើតមានទេ។ លោកសាស្ត្រាចារ្យ តើលោកធ្លាប់បាននិយាយពាក្យបែបនេះទេកន្លងមកនោះ?

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយតប ចាំស្តាប់អង្គជំនុំជម្រះសម្រេចលើកសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញា លើការតាំងសំណួរចុងក្រោយ។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[១៤:១៦:០៧]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអភ័យទោស ហើយខ្ញុំសូមជំទាស់សំណួរទី១ ហើយសំណួរចុងក្រោយនេះជាសំណួរដែលប្រាស់ចាកអំពីប្រធានបទដែលត្រូវសួរ សំណួរមិនពាក់ព័ន្ធ។ ថាតើគាត់សម្តែងទស្សនអំពីអ្នកនយោបាយដែលមិនបញ្ជាក់ឈ្មោះនោះក៏ដោយ គឺមិនពាក់ព័ន្ធអ្វីទេ ហើយគាត់មិនបានធ្វើឲ្យមាន -- មិនបានបញ្ជាក់ថា វាមានទំនាក់ទំនងនៅសវនាការទីនេះ តាំងពីអាទិត្យមុនមកទេ។ ដូច្នេះហើយ សូមតុលាការសម្រេច។

**លោក អេនឌ្រូ អ៊ីនូហ្ស៊ី៖**

ខ្ញុំឆ្លើយដោយសង្ខេប។ នេះគឺជាពាក្យដែលខ្ញុំប្រើនៅក្នុងសាលសវនាការ ចំពោះបុគ្គលដដែល

គឺថាមិនមែនជាលើកទីមួយទេ។ ជំហររបស់យើងខ្ញុំថា ពាក្យថា “កាយវិការរបស់រដ្ឋាភិបាលដ៏មិនគប្បីនេះ” គឺមានផលប៉ះពាល់ទៅលើការប្រព្រឹត្តិទៅនៃតុលាការ គឺថាបញ្ហាទាក់ទងទៅនឹងការជំនុំជម្រះដ៏យុត្តិធម៌។ នេះហើយជាជំហររបស់ខ្ញុំចង់ប្រកាន់យកការសួរសំណួរនេះ។

[១៤:១៧:១៤]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់និងសំអាងហេតុរបស់តំណាងសហព្រះរាជអាជ្ញាត្រឹមត្រូវ។ សេចក្តីជំទាស់នេះប្រសិទ្ធភាព។ អ្នកជំនាញមិនចាំបាច់ឆ្លើយតបទៅនឹងសំណួរចុងក្រោយរបស់មេធាវីអន្តរជាតិការពារក្តីលោក នួន ជា នេះទេ។

ហើយសូមជម្រាប រំឭកដល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីថា ប្រសិនបើលោកមានចេតនានៅក្នុងការជំទាស់ លោកធ្វើសេចក្តីជំទាស់ព្រមគ្នាជាមួយនឹងសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញា។ ហើយកាលណា ធ្វើសេចក្តីជំទាស់រួចហើយ ភាគីម្ខាងទៀតដែលទទួលរងសេចក្តីជំទាស់នោះ អាចឆ្លើយតបទៅនឹងសេចក្តីជំទាស់នោះបាន។ នេះជាការចប់នូវការបង្ហាញអំពីសំអាងហេតុនៃសេចក្តីជំទាស់។ ហើយអង្គជំនុំជម្រះនឹងសម្រេចហើយ មិនអាច អង្គជំនុំជម្រះស្តាប់សេចក្តីជំទាស់របស់ភាគីម្ខាងទៀត ហើយលោកងើបឈរដើម្បីមានបំណងនិយាយដូច្នេះទេ។

សូមអញ្ជើញតសំណួរ។

**លោក អេនច្រូ អ៊ីន្នូហ្សី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនមានសំណួរទេ មានយោបល់មតិដែលលើកឡើងនេះ គឺវាថាបានជម្រាប គឺថានិយាយសំដៅលោក ហ៊ុន សែន ហើយខ្ញុំដាក់នៅក្នុងសំណុំរឿង ហើយខ្ញុំមានឯកសារនៅក្នុងដៃហើយ ហើយតុលាការបានហាមមិនឱ្យយើងខ្ញុំយកមកប្រើនូវអត្តសញ្ញាណទេ។ ដូច្នេះខ្ញុំយកតែខ្លឹមសារ។ ហើយគឺថាយើងនឹងចែកទៅឱ្យភាគីមុនជាមុន ហើយខ្ញុំបានប្រើ -- ប្រឹងប្រែងដើម្បីទៅតាមវិធាន៨៧(៤) ដែលទាក់ទងទៅនឹងឯកសារ។ ដូច្នេះ គឺថាភាគីនៅខាងស្តាំដៃរបស់ខ្ញុំនេះ បញ្ជាក់ថាគាត់បានរក្សាសិទ្ធិ ដើម្បីពិនិត្យមើល និងសួរដេញដោលប្រសិនបើឯកសារហ្នឹងត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង គាត់នឹងសួរដេញដោយផ្ទាល់អ្នកជំនាញរូបនេះ។ សូមអរគុណ។

[១៤:១៩:១៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណឥឡូវនេះដល់ពេល--

*(មិនបើកក្បាលមីក្រូហ្វូន)*

[១៤:១៩:២៧]

**អ្នកបកប្រែ៖**

លោកប្រធាន មីក្រូហ្វូនលោកប្រធានអត់បើក បាទ។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសមល្មមសម្រាកដែរហើយ ហើយជាការសម្រួលដល់ក្រុមមេធាវីការពារក្តីបន្ទាប់ផងក្នុងការតាំងសំណួរ ដែលមានពេលវេលាជាប់គ្នា ប្រសិនបើយើងបន្តទៅទៀត ពេលវេលាខ្លី ហើយនិងសម្រាកនាពេលខាងមុខដដែល។ ដូច្នេះអង្គជំនុំជម្រះសម្រេចសម្រាក២០នាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបីខ្វះម្ភៃនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់អ្នកជំនាញដល់អ្នកជំនាញ និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មវិញនៅវេលាម៉ោងដែលបានកំណត់អម្បាញ់មិញនេះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:២០ នាទី ដល់ម៉ោង ១៤:៤១ នាទី)*

[១៤:៤១:១០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្ត កិច្ចដំណើរការនីតិវិធីសវនាការ។ ជាបន្តនេះអង្គជំនុំជម្រះ សូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីមានឱកាសតាំងសំណួរដេញដោល ចំពោះអ្នកជំនាញ ដេវីដ ឆេនដ៍ល័រ។ សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

សូមគោរព លោក លោកស្រីចៅក្រមជាទីគោរព ទាំងអស់លោក លោកស្រី នៅក្នុងបន្ទប់សវនាការ និងក្រៅបន្ទប់សវនាការ ជាពិសេសសូមគោរពសួស្ដីលោក សាស្ត្រាចារ្យ ដេវីដ ឆេនដ៍ល័រ។

[១៤:៤១:៥៦]

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ខ្ញុំជាមួយនឹងលោក អាង ឧត្ដម យើងតំណាងការពារក្ដីលោក អៀង សារី។ កាលពីព្រឹកមិញ ខ្ញុំកត់សម្គាល់ឃើញសំណួរបានសួរលោកទៅកាន់លោក ទាក់ទងទៅនឹងការទម្លាក់គ្រាប់បែកឆ្នាំ៧៣។ ហើយនៅចំណុចនោះ លោកឈប់ឆ្លើយ ហើយលោកមើលអង្គជំនុំជម្រះសាលាដំបូង ហើយលោកសួរអង្គជំនុំជម្រះ ថាតើលោកត្រូវបានអនុញ្ញាតឲ្យនិយាយអំពីសម័យកាលនោះដែរឬទេ? លោកមិនបានធ្វើដូច្នេះកាលពីសប្ដាហ៍មុន នៅពេលដែលសហព្រះរាជអាជ្ញាសួរលោក អំពីអំឡុងពេលឆ្នាំ១៩៦០ ដែលវាស្ថិតនៅក្រៅវិសាលភាពនៃការជំនុំ -- នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងការសួររបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅទសវត្សរ៍ឆ្នាំ៤០ និង៥០ ក៏លោកមិនបានធ្វើដូច្នេះ។ ខ្ញុំសួរលោកនឹងចំណុចនេះ ហើយលោកមិនចាំបាច់ចូលក្នុងសៀវភៅទេ ដោយសារតែលោកដឹងចំណុចនេះហើយ។ ខ្ញុំចង់សួរលោកហេតុអ្វីបានជាលោក សុំការអនុញ្ញាតទៅអង្គជំនុំជម្រះ នៅពេលដែលមេធាវីការពារក្ដីសួរ ក៏ប៉ុន្តែមិនសុំការអនុញ្ញាតដូច្នេះផងដែរទៅ កាលពីសហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណីសួរនោះ?

[១៤:៤៣:២៥]

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** ចម្លើយរបស់ខ្ញុំឆ្លើយទៅនឹងសំណួរនោះគឺថា សំណួរវាពាក់ព័ន្ធទៅនឹងបញ្ហាមុនឆ្នាំ៧៥ តាមអ្វីដែលខ្ញុំចាំ។ ខ្ញុំមិន -- ខ្ញុំគិតថាវាមិនស្ថិតនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ដែលខ្ញុំបានផ្ដោតសរសេរនោះទេ។ ដូច្នេះហើយ ខ្ញុំមិនអ្នកជំនាញទៅលើសម័យកាលទម្លាក់គ្រាប់បែករបស់អាមេរិកនោះទេ ខ្ញុំពាក់ព័ន្ធ និងសរសេរតែទៅលើសម័យកម្ពុជាប្រជាធិបតេយ្យតែប៉ុណ្ណោះ។ ដូច្នេះហើយអ្វីដែលខ្ញុំធ្វើដូច្នេះមិនមែនថា ខ្ញុំមិនស្ទាក់ស្ទើរក្នុងការនិយាយអំពីបញ្ហាទម្លាក់គ្រាប់បែកអាមេរិក និងសម័យកម្ពុជាប្រជាធិបតេយ្យនោះឡើយ ក៏ប៉ុន្តែខ្ញុំមិនចង់យកចំណុចបញ្ហាអំណាចបរទេសនោះ ដែលមិនបានយកមកពិភាក្សាដេញដោលនៅទីនេះ។ ដូច្នេះហើយ ខ្ញុំគិតថាវាមិនមែនជាអ្វីដែលវាខុសនោះទេ ហើយខ្ញុំផ្ដល់ចម្លើយតាមអ្វីដែលខ្ញុំអាចធ្វើតែប៉ុណ្ណោះ។

[១៤:៤៤:២០]

**ស៖** សូមអរគុណ។ លោកអាចឃើញហើយ ថាខ្ញុំព្យាយាមគិតអំពីគោលបំណងដែលលោកធ្វើដូច្នោះ គឺដោយសារតែលោកគិតថា ទំនងជាចង់គាំទ្រទៅខាងសហព្រះរាជអាជ្ញា ជាជាងខាងមេធាវីការពារក្តី។ នេះជាចំណុចដែលខ្ញុំយល់ថាដូច្នោះ។

**ឆ៖** ខ្ញុំមិនមែនជាមនុស្សដែលមានគោលបំណង និងចេតនាធ្វើដូច្នោះនោះទេ។ ខ្ញុំគិតថា ចំណុចនេះគឺជាមិនគួរលើកឡើងដូច្នោះឡើយ។

**ស៖** ពាក់ព័ន្ធទៅនឹងប្រភពដែលលោកបានពិនិត្យមើល។ កាលពីព្រឹកមិញ នៅពេលដែលលោកឆ្លើយសំណួរមួយចំនួននោះ ខ្ញុំនឹងសួរសំណួរបន្តទៀត ដោយសារសំណួរកាលពីព្រឹកមិញមិនទាន់សួរលម្អិតជ្រៅនៅឡើយ។ តើលោកអាចជម្រាបដែរឬទេ លោកបានទាក់ទងជាមួយនរណាគេមុនពេលដែលលោកមកផ្តល់សក្ខីកម្មនៅទីនេះ? តើលោកបានធ្វើទំនាក់ទំនងជាមួយអ្នកណាគេខ្លះ មុនពេលមកផ្តល់សក្ខីកម្មនៅទីនេះ? ខ្ញុំមិនមែនសួរតែទៅលើករណីសំណុំរឿង០០២ នោះទេ និង ០០១ ផងដែរ។ តើលោកមានធ្វើទំនាក់ទំនងជាមួយបុគ្គលណាជាមុនដែរឬទេ មុនមកផ្តល់សក្ខីកម្មនៅទីនេះ? តើលោកមានទាក់ទងជាមួយខាងការិយាល័យសហព្រះរាជអាជ្ញា ឬការិយាល័យសហចៅក្រមស៊ើបអង្កេតជាមុនដែរឬទេ?

[១៤:៤៥:៤៨]

**ប្រធានអង្គជំនុំ៖**

លោកអ្នកជំនាញកុំអាលទាន់ឆ្លើយតប ចាំស្តាប់អង្គជំនុំជម្រះសម្រេចលើសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណួរចុងក្រោយរបស់មេធាវីអន្តរជាតិការពារក្តីលោក អៀង សារី ជាមុនសិន។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថាវីក៖**

ខ្ញុំក្រោកឈរមុនពេលដែលមេធាវីការពារក្តីបញ្ចប់ការលើកឡើងរបស់ខ្លួន។ យើងមិនជំទាស់នឹងគោលការណ៍ធ្វើសំណួរនោះទេ ក៏ប៉ុន្តែការដែលសួរថា តើខាងលោកសាស្ត្រាចារ្យមាននិយាយជាមួយនឹងលោកព្រះរាជអាជ្ញា ឬក៏ការិយាល័យចៅក្រមស៊ើបអង្កេត នោះគួរតែសួរឲ្យបានជាក់លាក់ជាងនេះ។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ខ្ញុំនឹងសួរសំណួរជាក់លាក់មុនពេលខ្ញុំសួរសំណួរទូទៅ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ខ្ញុំចង់ដឹងថា គាត់បានជាមួយនឹងបុគ្គលណាខ្លះមុនមកផ្តល់សក្ខីកម្មនៅទីនេះ។ តើលោកមានបានទទួលឱកាសនិយាយជាមួយនឹងលោក ហេដឌ័រ ដែរឬទេ មុនពេលមកផ្តល់សក្ខីកម្មនៅទីនេះ?

[១៤:៤៧:០៣]

**លោក ដេវីដ ឆេនដ័លឺរ៖**

**ឆ៖** បាទ គឺខ្ញុំបាននិយាយ។

**ស៖** តើលោកពិភាក្សាតាមរយៈអ៊ីម៉ែលឆ្លើយឆ្លងគ្នាទៅវិញទៅមកហ្នឹងញឹកញយប៉ុនណាដែរ?

**ឆ៖** នៅក្នុងឆ្នាំនេះ ឬក៏ឆ្នាំណា?

**ស៖** ចាប់ផ្តើមពីពេលដែលគាត់នោះ ចាប់ធ្វើការងារជាមួយនឹង អ.វ.ត.ក នេះ។ មុនដំបូង គាត់ធ្វើការងារជាមួយនឹងខាងសហព្រះរាជអាជ្ញា បន្ទាប់មកគឺធ្វើការងារឲ្យសហចៅក្រមស៊ើបអង្កេត ដើម្បីផ្ទៀងផ្ទាត់ថាអ្វីដែលគាត់សរសេរជាសេចក្តីព្រាងនោះត្រឹមត្រូវដែរឬទេ? ខ្ញុំចង់ដឹងថាតើលោកទាក់ទងជាមួយនឹងលោក ហេដឌ័រ ហ្នឹងនៅពេលណាដែរ? គឺនៅក្នុងឆ្នាំ២០០៥ ឬ២០០៦?

[១៤:៤៧:៥១]

**ឆ៖** ការងាររបស់គាត់ជាចំណុចចាប់អារម្មណ៍របស់ខ្ញុំ ក៏ប៉ុន្តែគាត់មិនត្រូវ គាត់មិន -- ខ្ញុំមិនចាប់អារម្មណ៍ទៅលើការស្រាវជ្រាវរបស់ខ្ញុំដោយផ្អែកទៅលើអ្វី ដែលគាត់លើកឡើងនោះទេ។ ខ្ញុំគ្រាន់តែចង់ស្វែងយល់ថាមានហេតុការណ៍កើតឡើងខ្លះនៅក្នុងទីក្រុងភ្នំពេញ ហើយនិងដើម្បីនិយាយអំពីវិធីសាស្ត្រផ្តល់សក្ខីកម្មរបស់ខ្ញុំ។ ហើយខ្ញុំមិនមែនទាក់ទងគាត់ថា ខ្ញុំគួរតែនិយាយអ្វី ធ្វើអ្វីខ្លះ មុនពេលមកផ្តល់សក្ខីកម្មនោះទេ។ ខ្ញុំគ្រាន់តែផ្តោតទៅលើឯកសារដែលវាមានសម្រាប់ខ្ញុំតែប៉ុណ្ណោះ។

**ស៖** តើសំណុំរឿង០០១ គឺលោកបានធ្វើដូច្នោះដែរមែនដែរឬទេ? ហើយសំណុំរឿង០០២ លោកក៏បានទាក់ទងជាមួយនឹងគាត់ដូច្នេះដែរ តើអ៊ីចឹងទេ? សំណុំរឿង០០១ គឺពាក់ព័ន្ធទៅនឹង ឌុច តើខ្ញុំ ខ្ញុំគិតលោកមានបញ្ហាទេ ស្តាប់ភាសាអង់គ្លេសខ្ញុំអត់បាន ឬក៏យ៉ាងណា? ដោយសារខ្ញុំឃើញលោកមានការស្ទាក់ស្ទើរ ហើយរង់ចាំឆ្លើយ?

**ឆ៖** សំណុំរឿង០០១ នោះគឺថាខ្ញុំមិនសូវមានការរៀបចំច្រើនដូចសំណុំរឿងនេះទេ ដោយសារខ្ញុំ

បានយកសៀវភៅរបស់ខ្ញុំមកមើលតែប៉ុណ្ណោះ។ ក៏ប៉ុន្តែសំណុំរឿង០០២ នេះគឺថា ខ្ញុំបានផ្តោតទៅលើឯកសារច្រើន ខ្ញុំត្រូវមើលឯកសារជាច្រើនឡើងវិញ។

[១៤:៤៩:២៣]

**ស៖** លោក ដេវីដ ឆេនដ៍ល័រ លោកសូមឆ្លើយជាមួយនឹងសំណួររបស់ខ្ញុំ។ ខ្ញុំចង់សួរការទំនាក់ទំនងរបស់លោកជាមួយលោក ហេដឌ័រ ហើយថាតើលោកមានទាក់ទងជាមួយលោក ហេដឌ័រ នៅពេលដែលលោកមកផ្តល់សក្ខីកម្មលើករណី ឌុច ដែរឬទេ? តើលោកបានទាក់ទងជាមួយគាត់ដែរឬទេ? ទាក់ទង ឬក៏អត់?

**ឆ៖** បាទ ខ្ញុំទាក់ទង ប៉ុន្តែទាក់ទងតិចតួចតែប៉ុណ្ណោះ។

**ស៖** ពាក់ព័ន្ធទៅនឹងករណីសំណុំរឿងនេះ តើលោកមានការធ្វើទាក់ទង -- មានទាក់ទងជាមួយនឹងលោក ហេដឌ័រ នៅពេលដែលលោក ហេដឌ័រ នោះធ្វើការងារនៅការិយាល័យសហព្រះរាជអាជ្ញានៅពេលដែលគាត់ហ្នឹងរៀបចំសេចក្តីព្រាងដីកាបញ្ជូនរឿងទៅស៊ើបសួរ ជាមួយនឹងសមាជិកផ្សេងទៀតនៅក្នុងក្រុមរបស់គាត់ដែរឬទេ?

[១៤:៥០:១២]

**ឆ៖** គឺបាទ ខ្ញុំទាក់ទងមែន ក៏ប៉ុន្តែមិនមែនព្យាយាមថា តើមានអ្វីកើតឡើងនោះទេ គឺខ្ញុំមិនបានគិតថា ហើយចង់បានព័ត៌មានណាពីគាត់នោះទេ គ្រាន់តែចង់ដឹងព័ត៌មានមួយចំនួនតែប៉ុណ្ណោះ។

**ស៖** ខ្ញុំចង់សួរលោក មិនមែនសួរថាលោកយកព័ត៌មានអ្វីពីគាត់នោះទេ ក៏ប៉ុន្តែថាតើខ្ញុំចង់សួរថា តើៗលោកមានការធ្វើទំនាក់ទំនងជាមួយនឹងគាត់ដែរឬទេ? ថាតើធ្វើដោយរបៀបណា? ហើយនៅពេលដែលលោកនិយាយថា គាត់បាន -- លោកបានធ្វើទំនាក់ទំនងជាមួយគាត់ផ្លាស់ប្តូរឯកសារនោះ តើឯកសារណាខ្លះដែលគេបានបញ្ជូន និងផ្តល់ជូនលោកនោះ នៅពេលនោះ?

**ឆ៖** គឺឯកសារបោះពុម្ពដែលខ្ញុំមិនបានអានច្រើន ដូចនឹងអ្វីដែលគាត់អាន។ ក៏ប៉ុន្តែ ខ្ញុំបានធ្វើទំនាក់ទំនងជាមួយគាត់អ៊ីចឹងមែន។

**ស៖** ឯកសារសម្ភារៈជាសាធារណៈ ដែលលោក -- ដែលគាត់ផ្តល់ជូនលោកនោះ គឺវាពាក់ព័ន្ធទៅនឹងការងារ ដែលគាត់ធ្វើការជូនទៅការិយាល័យសហព្រះរាជអាជ្ញានៅពេលនោះ តើអ៊ីចឹងដែរឬទេ?

**ឆ៖** មិនពាក់ព័ន្ធដោយផ្ទាល់នោះទេ គឺវាពាក់ព័ន្ធទៅនឹងតួនាទីរបស់គាត់ ដូចជាឯកសារព្រឹកមិញគឺឯកសារឆ្នាំ១៩៨៩ ដែលខ្ញុំគិតថា មិនមែនជាឯកសារតុលាការនោះទេ ខ្ញុំមិនដែលធ្លាប់ឃើញ

ឯកសារតុលាការផ្ដល់ជូនមកឲ្យខ្ញុំនៅពេលមុននោះឡើយ។

**ស៖** តើត្រឹមត្រូវដែរឬទេ យុត្តិធម៌ដែរឬទេ នៅពេលដែលយើងនិយាយថា ហេដឌ័រ នោះក៏បានផ្ដល់ឯកសារជូនលោកនូវព័ត៌មានបឋមផងដែរ គឺឯកសារដែលលោក ហេដឌ័រ នោះមាន ហើយដែលលោកហ្នឹងមិនមាន ហើយមិនបានដឹងអំពីឯកសារទាំងអស់នោះ។ តើអ៊ីចឹងដែរឬទេ?

[១៤:៥២:០៣]

**ឆ៖** មិនមែនអ៊ីចឹងទេ គឺគាត់មិនបានផ្ដល់ឯកសារចម្បងបឋម មកឲ្យខ្ញុំនោះទេ។

**អ្នកបកប្រែ៖**

លោកប្រធាន សូមអនុញ្ញាតឲ្យមេធាវី និងលោកសាក្សីរង់ចាំបន្តិច ដើម្បីការបកប្រែបញ្ចប់ជាមុនសិន។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** នៅពេលដែលលោក ហេដឌ័រ ធ្វើការងារជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត តើលោកបានធ្វើការទាក់ទងជាមួយនឹងគាត់ដែរឬទេ? ហើយប្រសិនបើបានទាក់ទងនោះថាតើលោកទាក់ទងហ្នឹង ទាក់ទងអំពីអ្វីដែរ?

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** ខ្ញុំពិបាកនិយាយណាស់ គឺការទាក់ទងហ្នឹងគឺ ដោយសារតែយើងជាមិត្តភ័ក្តិហ្នឹងគ្នាជាង ៣០ឆ្នាំប៉ុណ្ណោះ។ ប៉ុន្តែខ្ញុំមិនមែនទាក់ទងសួរអំពី -- បាទ ខ្ញុំសូមនិយាយម្ដងទៀត ការទាក់ទងនោះគឺមិនពាក់ព័ន្ធទៅនឹងព័ត៌មាន ដែលមិនមែនជាសាធារណៈនោះឡើយ គឺការងារដែលពាក់ព័ន្ធនឹងការស្រាវជ្រាវរបស់ខ្ញុំ។ ខ្ញុំសួរអំពីវឌ្ឍនភាពនៃតុលាការនេះ យ៉ាងម៉េចយ៉ាងម៉ាតែប៉ុណ្ណោះ។ គាត់និយាយថា ចំណុចមួយចំនួនដែលខ្ញុំមិនអាចយកមកនិយាយនៅពេលនេះទេ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី ម៉ែខល កាណាវាស សូមឲ្យឃ្លាតបន្តិច ដើម្បីអ្នកបកប្រែហ្នឹងបកទាន់បាទ។

សូមអរគុណបាទ។ សូមអញ្ជើញ!

[១៤:៥៣:២៧]

**លោក ម៉ែខល កាណាវាស៖**

ខ្ញុំសូមអធ្យាស្រ័យលោកប្រធាន។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** នៅពេលដែលលោកនិយាយថា ព័ត៌មានមិនអាចលាតត្រដាងមកនោះ ថាតើលោកបានន័យយ៉ាងម៉េច? តើយើងអាចនិយាយថា មានការសរសេរឆ្លើយឆ្លងអ៊ីម៉ែលទាក់ទងទៅនឹងការងាររបស់ហេដឌ័រ ដែលលោកគិតថា មិនអាចលាតត្រដាងជាសាធារណៈមែនដែរឬទេ? ហើយលោកមិនអាចយកមកបង្ហាញជូននៅពេលនេះ នៅក្នុងថ្ងៃនេះ តើអ៊ីចឹងដែរឬទេចំពោះចម្លើយរបស់លោក?

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** គឺគាត់បានបញ្ជាក់យ៉ាងច្បាស់ថា គាត់មិនចង់ឲ្យខ្ញុំយកព័ត៌មានទាំងអស់នោះ យកមកសរសេរនោះទេ។ ដូច្នេះ ហើយគឺព័ត៌មានទាំងអស់នោះ គាត់មិនចង់ -- គាត់មិនឲ្យខ្ញុំយកមកសរសេរនៅក្នុងសៀវភៅហ្នឹងឡើយ។

**ស៖** គាត់មិនចង់ឲ្យលោកយកព័ត៌មានដែលពិភាក្សាជាមួយគាត់នោះ យកមកសរសេរក្នុងសៀវភៅ។ ដូច្នេះ ខ្ញុំសន្និដ្ឋានថា គាត់កំពុងតែធ្វើការស្រាវជ្រាវរៀបចំសេចក្ដីព្រាង សម្រាប់ការិយាល័យសហចៅក្រមស៊ើបអង្កេត។ ដូច្នេះហើយទើបគាត់នោះ បានពិភាក្សាជាឯកជនជាមួយនឹងលោក ហើយលោកលើកឡើងថ្ងៃនេះថា មិនអាចយកព័ត៌មានទាំងអស់នោះមកពិភាក្សាជាសាធារណៈបាន។ តើអ៊ីចឹងដែរឬទេ?

[១៤:៥៤:៥៤]

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយតបទៅនឹងសំណួររបស់មេធាវីអន្តរជាតិការពារក្ដីឲ្យលោក អៀង សារី រង់ចាំអង្គជំនុំជម្រះសម្រេចលើសេចក្ដីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាទៅលើសំណួរនេះជាមុនសិន។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ចារីក៖**

យើងគិតថា មេធាវីការពារក្ដីគឺព្យាយាមសួរសំណួរដែលអាចទាញចម្លើយ ពាក់ព័ន្ធទៅនឹងលោកសាស្ត្រាចារ្យ ឆេនដ៍ល័រ។ ជាពិសេស ការសិក្សាស្រាវជ្រាវរបស់គាត់ បើសិនជាសំណួរបែបនេះ គឺយើងខ្ញុំជំទាស់។ មេធាវីការពារក្ដីនៅពេលនេះ ព្យាយាមសួរការ -- ព័ត៌មានពាក់ព័ន្ធទៅនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលចាត់ទុកថាជាព័ត៌មានមិនបានកត់ត្រា ហើយចែកចាយជូនទៅដល់បុគ្គល

ផ្សេង។ ដូច្នេះ មិនពាក់ព័ន្ធនោះទេសំណួរទាំងអស់នេះ។ ប្រសិនបើមេធាវីការពារក្តីចង់សួរថា តើព័ត៌មានណាខ្លះដែលលោកសាស្ត្រាចារ្យទទួលបាន? ហើយតើព័ត៌មានណាខ្លះ ដែលគាត់យល់យ៉ាងម៉េចយ៉ាងម៉ានោះ គឺវាអាចពាក់ព័ន្ធ។ ក៏ប៉ុន្តែប្រសិនបើវាជាការសួរសំណួរ សួរទៅដល់បុគ្គលឯកជនមួយនោះ គឺថាយើងគិតថា វាមិនពាក់ព័ន្ធ ហើយមិនអាចធ្វើបាននោះទេ។

[១៤:៥៦:១៦]

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមធ្វើការឆ្លើយតបជាសង្ខេប លោកប្រធាន។ ជាការពិត ប្រសិនបើលោក ហេដឌ័រ ធ្វើការងារឱ្យសហចៅក្រមស៊ើបអង្កេត។ ដូច្នេះ គឺគាត់មិនអាចពិភាក្សាបញ្ហាការងាររបស់គាត់ជាមួយនឹងបុគ្គលណាផ្សេងនោះទេ។ ករណីនេះក៏ដូចនឹងការងារដែលគាត់ធ្វើឡើងនៅក្នុងសហក្រមស៊ើបអង្កេតនោះផងដែរ។ ដូច្នេះ ខ្ញុំមិនដឹងថាប្រព័ន្ធតុលាការនៅទីនេះ -- ប្រព័ន្ធការងារនៅទីនេះធ្វើយ៉ាងម៉េចនោះទេ។ ចំណុចមួយទៀត លោក ហេដឌ័រ គឺគាត់ជាប្រវត្តិវិទូ គាត់បានបញ្ជាក់ហើយ គាត់ធ្វើការឱ្យខាងសហព្រះរាជអាជ្ញា បន្ទាប់មកខាងចៅក្រមស៊ើបអង្កេត។ ហើយប្រសិនបើលោក ហេដឌ័រ បាននិយាយជាមួយនឹងលោក ឆេនដ័ល័រ មែននោះ ហើយលោក ឆេនដ័ល័រ ដឹងថាគាត់នឹងមកផ្តល់សក្ខីកម្ម ហើយហេដឌ័រ ហ្នឹងដឹងថាលោក ឆេនដ័ល័រ នឹងមកផ្តល់សក្ខីកម្មនៅទីនេះផងនោះ។ បញ្ហាទំនាក់ទំនងគ្នានេះនឹងបង្កើតជាបញ្ហា។ ដូច្នេះហើយ ទើបខ្ញុំសួរសំណួរទាំងអស់នេះឡើង។

កាលពីសប្តាហ៍មុន គឺថាយើងសួរលោក ដេវីដ ឆេនដ័ល័រ ហើយៗលោក ឆេនដ័ល័រ គាត់បានបញ្ជាក់ថា ព័ត៌មានរបស់គាត់ដែលបានដឹង បានធ្វើឡើងនោះ វាអាចចេញមកពីការធ្វើទំនាក់ទំនងជាមួយនឹងបុគ្គលមួយចំនួន។ ដូច្នេះហើយយើងព្យាយាមធ្វើការសាកសួរអំពីភាពទុកចិត្តបាន ទៅលើបុគ្គលនេះ។ ហេតុដូច្នេះហើយ ទើបយើងខ្ញុំសួរសំណួរទាំងអស់នេះ យកមកពិភាក្សា។

[១៤:៥៧:៤២]

អេតឆេសាន់, លោក ឡាខាត និង ហេដឌ័រ នោះ ក៏ពាក់ព័ន្ធទៅនឹងធ្វើទំនាក់ទំនងជាមួយលោក ឆេនដ័ល័រ ផងដែរ ដែលគាត់ទាំងអស់នោះ គាត់ធ្វើការងារជាមួយនឹងខាងការិយាល័យសហព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេត។ ដូច្នេះ ប្រសិនបើការធ្វើទំនាក់ទំនងអ៊ីចឹងមែននោះ វាមិនត្រឹមត្រូវនោះឡើយ។ ហើយយើងដឹងហើយថា បុគ្គលមួយចំនួននោះ អាចជាសាក្សីសក្តានុពល។ នៅក្នុងរឿងក្តីនេះ គឺយើងឃើញមានការបង្ហាញឯកសារជូនលោកសាស្ត្រាចារ្យ។ វាអាចបង្កើតឱ្យមានបញ្ហា

ទៅដល់ការគិតគូរពិចារណាមួយចំនួន ហើយៗយើងក៏បង្ហាញឲ្យយើងឃើញបុគ្គលដែលធ្វើការនៅក្នុងស្ថាប័ននេះមួយចំនួននោះ កំពុងតែធ្វើការងារលេងសើចទៅលើដំណើការការងាររបស់គាត់។

[១៤:៥៨:៣៣]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:០១:៥១]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រគល់ភារកិច្ចជូនទៅលោកចៅក្រម ហ្សង់ម៉ាក ដើម្បីបង្ហាញអំពីសេចក្ដីសម្រេចទៅលើសេចក្ដីជំទាស់ និងសំណួរចុងក្រោយរបស់មេធាវីអន្តរជាតិការពារក្ដីលោក អៀង សារី ចំពោះអ្នកជំនាញ។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះសូមទាក់ទាញចំណាប់អារម្មណ៍លោក កាណាវាស ទៅលើចំណុចដែលថា អ្វីដែលយើងចាប់អារម្មណ៍នៅថ្ងៃនេះ នៅក្នុងសាលសវនាការនេះ គឺការចោទប្រកាន់ទៅលើជនជាប់ចោទនៅក្នុងសំណុំរឿង០០២។ ហើយច្បាស់ជាងនេះទៅទៀតនោះ គឺយើងព្យាយាមពិនិត្យទៅលើអ្វីដែលពាក់ព័ន្ធទាក់ទិនទៅនឹងអង្គហេតុនៃសំណុំរឿង០០២/១ នេះ។ រាល់សំណួរទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងរបៀបនៃការស៊ើបសួរនៅក្នុងសំណុំរឿង០០១នោះ គឺវាមិនមានភាពពាក់ព័ន្ធទៅនឹងសវនាការនេះទេ។

[១៥:០៣:០៣]

ដូច្នេះគោលគំនិតនៃការសួរបែបនេះ គឺអង្គជំនុំជម្រះមិនអនុញ្ញាតនោះឡើយ ពីព្រោះថាវាមិនមានភាពពាក់ព័ន្ធនោះទេ។ ដូច្នេះជាថ្មីម្ដងទៀត អង្គជំនុំជម្រះសូមបញ្ជាក់ថា សូមឲ្យលោកផ្ដោតទៅលើសំណួរដែលមានភាពពាក់ព័ន្ធ ដើម្បីអាចវាយតម្លៃទៅលើភស្តុតាងនៃសំណុំរឿង០០២។

**លោក ម៉ៃខល កាណាវាស៖**

ចំពោះសាក្សីរូបនេះ គឺថាមានភាពពាក់ព័ន្ធទោះបីជានៅក្នុងប្រព័ន្ធ*អង់គ្លូសាក់ស៊ុង* ក៏ដោយ។ លោកបានបញ្ជាក់ថា លោកបានមើលដីកាដំណោះស្រាយ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** លោកសាក្សី លោកអ្នកជំនាញសូមលោកប្រាប់ខ្ញុំមើល៍ ថាតើលោកអានទាំងស្រុង ឬក៏លោកអានតែមួយផ្នែកណាទេ?

**លោក ដេវីដ ឆេនដ័ល័រ៖**

**ឆ៖** ខ្ញុំបានអានអត្ថបទនៃដីកាដំណោះស្រាយ។ ខ្ញុំសូមជម្រាបថា ខ្ញុំមិនច្បាស់ទេសំណួរខាងដើម។ ខ្ញុំមិនបានឃើញដីកាដំណោះស្រាយនេះទេ មុនខ្ញុំមកភ្នំពេញពីអាទិត្យមុននេះ។ គេបានបង្ហាញខ្ញុំគឺថាហើយខ្ញុំត្រូវឲ្យអានឲ្យបានលឿន គឺថាឲ្យបាន -- ខ្ញុំអានលេខយោងមួយចំនួនដែលខ្ញុំមើលទៅឃើញថាតើព័ត៌មានមកពីណា ពេលខ្លះខ្ញុំមិនដឹងថា វាមានប្រភពមកពីណាទេ។ នេះខ្ញុំអាចឆ្លើយ។

[១៥:០៤:៣១]

**ស៖** ឥឡូវនេះខ្ញុំសូមឲ្យលោកបញ្ជាក់អំពីសក្ខីកម្ម ចម្លើយរបស់លោក ថាត្រូវ ឬមិនត្រូវ? នៅពេលដែលលោកមកភ្នំពេញ មកធ្វើសក្ខីកម្មជាលើកដំបូង ដែលលោកទទួលបានដីកាដំណោះស្រាយ។ តើអ៊ីចឹងឬ?

**ឆ៖** បាទ។

**ស៖** តើជាឯកសារលើក្រដាស ឬក៏ជាឯកសារជាអេឡិចត្រូនិក?

**ឆ៖** ជាឯកសារលើក្រដាស។

**ស៖** នៅពេលដែលលោកមើលលេខយោង តើលោកទៅរកប្រភពដើមដែលលោកយោងទៅនៅក្នុង -- លេខយោងនោះតាមអ្វីដែលខ្ញុំយល់ លោកមានលទ្ធភាពតិចតួចណាស់ដើម្បីបើកមើលឯកសារនោះតើអ៊ីចឹងឬ? អ្វីដែលគេយោងក្នុងលេខយោងនោះ?

**ឆ៖** ខ្ញុំមិនអាចបើកមើលឯកសារដើមណានោះបានទេ។ ខ្ញុំនៅភ្នំពេញនេះ ខ្ញុំមិនអាចរកឃើញទេ នៅពេលដែលខ្ញុំអានឯកសារផ្នែកនេះ។

**ស៖** មុនពេលដែលលោកមកភ្នំពេញ ខ្ញុំយល់ថាលោកទទួលបានឯកសារមួយចំនួនពីអង្គជំនុំជម្រះសាលាដំបូង ដើម្បីពិនិត្យមើល។ លោកទទួលដំណឹងថាភាគីចង់សួរដេញដោលពីឯកសារមួយ -- មួយចំនួន តើអ៊ីចឹងទេ?

[១៥:០៥:៥៣]

**ឆ៖** បាទ។

**ស៖** ក្រៅពីឯកសារទាំងនោះ តើលោកបានមើលឯកសារអ្វីផ្សេងទៀតទេ? ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ តើប្រភពដើម ឯកសារប្រភពដើមលោកបានមើលទេ? បានឃើញទេ?

**ឆ៖** ខ្ញុំឆ្លើយថា ទេ។ នៅពេលដែលលោកថា ប្រភពដើមភាសាខ្មែរ ខ្ញុំមិនបានធ្វើស្រាវជ្រាវភាសាខ្មែរទេ។

**ស៖** តើគេបកប្រែទៅជាអង់គ្លេស -- ខ្ញុំចង់ដកចេញនូវអត្ថបទសារព័ត៌មានជាកម្រិតបណ្ឌិតសភា ហើយចង់និយាយតែឯកសារដែលលោកបានទទួល ដែលយើងមានបញ្ជី។ ខ្ញុំចង់ដឹងថាតើលោកបានមើលប្រភពចម្បងៗផ្សេងទៀតដែរឬទេ? ជាពិសេសជាភាសាខ្មែរ ប៉ុន្តែមិនចាំបាច់តែប្រភពដើមខ្មែរ ប៉ុន្តែអត្ថបទបកប្រែពីខ្មែរហ្នឹងលោកបានមើលទេ?

[១៥:០៦:៥៧]

**ឆ៖** ខ្ញុំមើល ក្រៅពីឯកសារទាំងនោះ ចំពោះឯកសារដែលបោះពុម្ពដែលផលិតឡើងដោយការសិក្សាអំពីសាលាក្ដី ដោយ ចន ខេរី ហើយនិងបេក្ខជនប្រាំពីររូបដែលត្រូវរងការចោទប្រកាន់ ខ្ញុំបានអានសៀវភៅនោះឡើងវិញ ហើយមានឯកសារមួយចំនួនខ្ញុំមិនអាចអានទាំងអស់ទេ។ ខ្ញុំបានទទួលដំណឹងអំពីសប្ដាហ៍មុន ហើយខ្ញុំអានមួយចំនួនអ្វីៗដែលតុលាការផ្ញើជូនខ្ញុំ។

**ស៖** សៀវភៅមួយដែលនិយាយពីបេក្ខជនប្រាំពីររូបត្រូវរកការចោទប្រកាន់នោះ គឺសៀវភៅរបស់ ស្ទីវ ហេដឌ័រ ដែល ហេដឌ័រ ហ្នឹងគាត់បានដាក់ឈ្មោះជនជាប់ចោទនៅក្នុងប្រមាណ តើអ៊ីចឹងឬ?

**ឆ៖** បាទ អ៊ីចឹងមែន។

[១៥:០៧:៥២]

**អ្នកបកប្រែ៖**

លោកប្រធាន លោកមេធាវីគាត់មិនបើកមីក្រូហ្វូនបាទ ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** នៅក្នុងឱកាសមួយចំនួន យើងអាចនឹងចូលទៅដល់ចំណុចនេះ ថ្ងៃស្អែកដែលលោកបានអានដីកាដំណោះស្រាយហើយ ហើយវាមានភាពស៊ីសង្វាក់គ្នា ប៉ុន្តែគឺជាការកំណត់ឃ្លាថា លោកបានអានដីកាដំណោះស្រាយ ហើយលោកបានឈានដល់សេចក្ដីសន្និដ្ឋាន ហើយលោកបានកែតម្រូវការគិតគូរ ឬក៏ជំហរចម្លើយរបស់លោកក្នុងឋានៈជាអ្នកជំនាញ។ ដោយបានស្ដាប់ថា ដូចដែលលោកឆ្លើយអំមិញនេះ បានឮដូចដែលលោកឆ្លើយអំមិញ តើខ្ញុំអាចសន្មតបានឬទេថា ដោយលោកថា លោកមិនមាន

លទ្ធភាពទៅមើលឯកសារដើមដែលគាំទ្រដីកាដំណោះស្រាយទេ? ហើយលោកក៏មិនបានទទួលឯកសារដើមហ្នឹងពីអង្គជំនុំជម្រះដែរ។ ប៉ុន្តែនៅពេលដែលលោកនិយាយថា លោកបានអានដីកាដំណោះស្រាយ តើលោកនិយាយពីអត្ថបទនៃដីកាដំណោះស្រាយហ្នឹងឬ?

[១៥:០៩:០២]

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** មែនហើយ។

**ស៖** ម្យ៉ាងទៀត ដែលខ្ញុំមិនព្យាយាមចង់ផ្តញ់លោកទេ។ ខ្ញុំក៏មិនចង់ព្យាយាមដាក់ការបន្ទោសទៅលើរូបលោកក្នុងន័យណាមួយដែរ។ ប៉ុន សូមលោកកុំយល់ដូច្នោះ នេះគឺជាដំណើរការនៃការសួរសំណួរក្នុងតុលាការ គឺគេសួរបែបនេះ គឺសូមឲ្យលោកមានអារម្មណ៍ធម្មតា។ ហើយលោកពឹងផ្អែកលើអត្ថបទដែលៗលោកត្រូវពិនិត្យមើលទៅតាមការប្រុងប្រយ័ត្នត្រឹមត្រូវ គឺឯកសារដែលលោកយោងថា តើដូចដែលលោកយោងដែរឬទេ? ត្រឹមត្រូវ ពេញលេញ ហើយគាំទ្រទៅនឹងគំនិតការលើកឡើងរបស់ដីកាដំណោះស្រាយនោះ?

**ឆ៖** សូមអរគុណ ចំពោះដែលលោកញញឹមដាក់ខ្ញុំនេះ។ ចំណុចមួយដែលខ្ញុំកែពាក្យរបស់លោក ខ្ញុំមិនដែលនិយាយថា ឲ្យខ្ញុំឈានដល់សេចក្តីសន្និដ្ឋានដើម្បីកែជំហរគំនិតរបស់ខ្ញុំ។ ព័ត៌មានថ្មីដែលខ្ញុំចាត់ទុកថា ចាប់អារម្មណ៍ដែលថា ដើម្បីយកគំនិតថ្មីហ្នឹងទៅបន្ថែមនៅក្នុងសៀវភៅរបស់ខ្ញុំដែល យោងទៅរកសេចក្តីថ្លែងការណ៍របស់សម្តេច សីហនុ ដែលបាននិយាយជាមួយ ប៉ុល ពត ជាដើមហ្នឹង។ សូមកុំនិយាយថា កុំនិយាយថា កុំនិយាយអ្វីដែលខ្ញុំមិនបាននិយាយ ដែលថាឲ្យខ្ញុំប្តូរគំនិតរបស់ខ្ញុំ ខ្ញុំមិនដែលនិយាយអ៊ីចឹងទេ។ ដីកាដំណោះស្រាយមិនបានប្តូរនូវគំនិតរបស់ខ្ញុំទេ។ គ្មានចំណុចណាមួយដែលខ្ញុំពិនិត្យផ្ទៀងផ្ទាត់ថា តើឯកសារហ្នឹងត្រូវ មិនត្រូវ យោងក្នុងដីកាដំណោះស្រាយ។ ខ្ញុំមិនធ្វើដូច្នោះទេនៅភ្នំពេញនៅអូតែល។ ហើយបើធ្វើដូច្នោះ ខ្ញុំមិនអាចអានឯកសារហ្នឹងចប់ទេ។

[១៥:១០:៥២]

**ស៖** សូមអភ័យទោស ប្រសិនបើខ្ញុំនិយាយខុស ឬក៏ដកស្រង់ខុស។ ខ្ញុំកែសម្រួលឃ្លាមិនត្រឹមត្រូវ។ សូមអរគុណដែលលោកកែខ្ញុំ។ បើខ្ញុំល្មៀងទៀត សូមលោកកែខ្ញុំតាមធម្មតា។ យើងធ្វើយ៉ាងណាឲ្យបានត្រឹមត្រូវតាមដែលអាចធ្វើទៅបាន។ ឥឡូវនេះខ្ញុំចង់បន្តទៅទៀត ខ្ញុំមិនចង់ឲ្យសន្និដ្ឋានថា ត្រូវពិនិត្យផ្ទៀងផ្ទាត់ ព័ត៌មានហ្នឹងត្រូវ មិនត្រូវទេ។ ប៉ុន្តែចង់ឲ្យខ្ញុំយល់លោកឲ្យច្បាស់ថា នៅពេលដែល

លោកនិយាយថា ផ្អែកលើដីកាដំណោះស្រាយ។ ឥឡូវនេះយើងដឹងថា -- តើលោកយោងទៅរកអត្ថបទនៃដីកាដំណោះស្រាយ ឬក៏យោងទាំងលេខយោង។ បានន័យថា ដើងទំព័រនៃឯកសារទាំងនោះផង ដើម្បីគាំទ្រថា អ្វីដែលអះអាងនៅក្នុងដីកាដំណោះស្រាយនោះត្រូវ ឬមិនត្រូវ? តើលោកយល់ស្របជាមួយខ្ញុំអ៊ីចឹងដែរឬទេ? ត្រូវទេ?

[១៥:១១:៤៩]

**ឆ៖** បាទ ត្រូវហើយ យើងយល់ស្របគ្នាអ៊ីចឹង។

**ស៖** សូមអរគុណច្រើន។ ឥឡូវនេះ ខ្ញុំនឹងព្យាយាមញញឹម ដើម្បីឱ្យលោកមានការងាយស្រួលក្នុងការឆ្លើយ។ ឥឡូវនេះ ខ្ញុំសូមឱ្យលោកត្រឡប់បន្តិចទៅរករយៈកាលមួយដែលយោងពីខាងដើមព្រឹកនេះនេះ អំពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក។ ខ្ញុំមិនចង់សាឡើងវិញនោះទេ គឺគ្រាន់តែចង់ដឹងបរិបទប្រវត្តិសាស្ត្រ។ តើលោកយល់ស្របជាមួយខ្ញុំដែរឬទេ? លោកសាស្ត្រាចារ្យ ឆេនដ៍ល័រ បរិបទនោះ គឺមានសារៈសំខាន់ណាស់នៅពេលដែលយើងចង់យល់អំពីហេតុការណ៍ប្រវត្តិសាស្ត្រ ឬក៏នៅក្នុងតុលាការហ្នឹងក៏ដូចគ្នាដែរ? តើលោកយល់ស្របជាមួយខ្ញុំអ៊ីចឹងទេ?

**ឆ៖** ពិតហើយ។

**ស៖** ចំពោះបរិបទវិញ តើលោកអាចប្រាប់តុលាការបានទេ នៅក្នុងឆ្នាំណាដែលការទម្លាក់គ្រប់បែកបានចាប់ផ្តើមឡើងនៅកម្ពុជានោះ? លោកនិយាយពីឆ្នាំ១៩៧៣ ប៉ុន្តែប្រហែលពេលបីបួនឆ្នាំមុននឹងបានចាប់ផ្តើមហើយ។ តើត្រូវដែរឬទេ?

**ឆ៖** បាទ មែនហើយ គឺខ្ញុំបញ្ជាក់នៅព្រឹកមិញនេះ គឺចាប់ផ្តើមពីឆ្នាំ១៩៦៧ មក។

**ស៖** ឥឡូវនេះ ខ្ញុំចង់ឱ្យលោកតាមលំដាប់លំដោយ។ សូមលោកមានសេចក្តីអំណត់ សូមអរគុណបើលោកបានធ្វើដូច្នេះ។ ពេលខ្លះលោកមានអារម្មណ៍ធុញទ្រាន់ ឬក៏ខ្មាសអៀន ប៉ុន្តែនេះជាមូលហេតុដែលថា ហេតុអីបានជាមានការទម្លាក់គ្រប់បែកហ្នឹង។ ហេតុអ្វីដែលយោង ដែលថាសហរដ្ឋអាមេរិកត្រូវតែទម្លាក់គ្រាប់បែកនោះ លោកដឹងទេ ហេតុអី?

[១៥:១៣:៤៥]

**ឆ៖** ហើយខ្ញុំ គឺថាមានតែអាមេរិកាំងទេដែលអាចឆ្លើយ ប៉ុន្តែខ្ញុំអាចឆ្លើយថា គឺថាដើម្បីគាំទ្រសង្គ្រាមរបស់គេនៅវៀតណាមខាងត្បូង ដែលគេច្បាំងប្រឆាំងនឹងវៀតណាមខាងជើង ប្រឆាំងនឹងខាងត្បូងហ្នឹង គឺថាមិនទម្លាក់គ្រប់បែកកម្ពុជាទេ វាជាធាតុផ្សំនៃសង្គ្រាមជាមួយវៀតណាម ដែលវៀតណាម

ដែលគេមិនហៅថា គេចាត់ទុកថាសង្គ្រាមហ្នឹង មិនមែនប្រឆាំងនឹងវៀតណាមទេ ប៉ុន្តែសង្គ្រាមប្រឆាំងនឹងភាគីមួយចំនួននៅក្នុងតំបន់។

**ស៖** សូមអភ័យទោស បើសិនជាសំណួររបស់ខ្ញុំស្មុគស្មាញ សូមលោកប្រាប់ខ្ញុំ។ ឥឡូវនេះមុនពេលទម្លាក់គ្រប់បែក ដែលថាចាប់ផ្តើមឡើងដូចលោកបានបញ្ជាក់។ សូមលោកប្រាប់តុលាការមើល៍បានទេ ថាបរិបទនៃការទម្លាក់គ្រាប់បែកនេះ តើសម្តេច សីហនុ តាមដែលខ្ញុំយល់ជាប្រមុខរដ្ឋ ហើយសូមលោកប្រាប់ខ្ញុំមើល៍ថា តើមានរឿងអ្វីកើតឡើងនៅកម្ពុជាដែលជំរុញឲ្យសហរដ្ឋអាមេរិកទម្លាក់គ្រាប់បែកនៅកម្ពុជានោះ?

[១៥:១៤:៥៧]

**ឆ៖** មិនមានអ្វីទាក់ទងទៅនឹងរដ្ឋាភិបាលកម្ពុជាទេដែលជាមូលហេតុនោះ ដែលថាពិភពលោកដឹងថា អ្វីដែលគេទម្លាក់គ្រាប់បែកនោះ គេទម្លាក់គ្រាប់បែកគឺទម្លាក់គ្រាប់បែកទាក់ទងទៅនឹងផ្លូវលំហូជីមិញ ដែលវៀតណាម និងឡាវ វាចូលពាក់ព័ន្ធក្នុងសង្គ្រាមមួយនេះ។

**ស៖** លោកនិយាយថា ផ្លូវលំហូជីមិញហ្នឹង តើលោកនិយាយថា សម្តេច សីហនុ បានមានការទាក់ទងជាមួយចិន ដើម្បីអនុញ្ញាតឲ្យមានអាវុធឆ្លងតាមរយៈកម្ពុជា ដើម្បីជួយវៀតណាមខាងជើង ជាវៀតណាមកុម្មុយនីស្ត ដែលកាលនោះជា -- ដែលច្បាំងជាមួយវៀតណាមខាងត្បូង។ តើអ៊ីចឹងដែរឬទេគំនិតដែលលោកនិយាយអំមិញនេះ?

**ឆ៖** ដើម្បី -- ចំណុចមួយខ្ញុំចង់ត្រឡប់ទៅសៀវភៅរបស់ខ្ញុំ នេះហើយវាមានការទាក់ទងគ្នាចំណុចនេះ។ សម្តេច សីហនុ គឺថាវាមានឃ្លាមួយគឺថា គេប្រើឃ្លាជាញឹកញាប់គឺថា ដើម្បីឲ្យមានតុល្យ-ភាពខាងនយោបាយរបស់គាត់។ ជួនកាលគាត់កាន់ខាងចិន ជួនកាលខាងវៀតណាម បែបនេះ។ នៅពេលដែលសង្គ្រាមនោះវាធ្ងន់ធ្ងរ -- មិនត្រឹមត្រូវទេ។ នៅក្នុងឆ្នាំ១៩៦៨ ហើយគាត់ -- ព្រះអង្គយល់ថាចង់ផ្តាច់ទំនាក់ទំនងជាមួយសហរដ្ឋអាមេរិកជាកំហុស ហើយក៏គាត់ព្រះអង្គផ្សារទំនាក់ទំនងជាមួយប្រទេសផ្សេង។ ប៉ុន្តែយើងមិនច្បាស់ប្រាកដទេ ប៉ុន្តែគឺជាស្ថានភាពទៅតាមបច្ចុប្បន្ន ដែលថា ៗទំនាក់ទំនងផ្តាច់ -- ទំនាក់ទំនងជាមួយសហរដ្ឋអាមេរិកហ្នឹង គឺថាមិនទាន់ផ្តាច់ទាំងស្រុងទេ ប៉ុន្តែវាមានការទម្លាក់គ្រាប់បែកហ្នឹងគឺថា សង្កត់ធ្ងន់ទៅលើផ្លូវលំហូជីមិញនេះ គឺថា គឺវាមានរឿងករណីសង្គ្រាមក្នុងព្រៃ ហើយជាមួយវៀតណាមជាដើមហ្នឹង។ ដូច្នេះហើយគឺថា វាពាក់ព័ន្ធនឹងចំណុចហ្នឹង។

[១៥:១៦:៥៥]

**សៈ** ក្នុងឋានៈជាប្រវត្តិវិទូ តើអ្នកនយោបាយកម្ពុជានៅសម័យកាលនោះ តើសម្តេច សីហនុ តើព្រះអង្គបានធ្វើអ្វីចំពោះអ្នកប្រឆាំងនឹងនយោបាយរបស់ព្រះអង្គហ្នឹង?

**ឆៈ** សំណួរនេះជាជំពូកមួយទាំងស្រុងនៅក្នុងសៀវភៅប្រវត្តិសាស្ត្ររបស់ខ្ញុំ ដែលថា តួនាទីរបស់ព្រះអង្គទាក់ទងទៅនឹងអ្នកជំទាស់របស់ព្រះអង្គ គឺថាមានការពិភាក្សាជាច្រើនទៅករណីនៅសំឡូត គឺថាវាមានការបង្ក្រាបដោយឃោរឃៅ ហើយជាការបង្ក្រាបធ្ងន់ធ្ងរណាស់ ដូចជា ខៀវ សំផន, អៀង សារី ហ្នឹង គឺថាបើមិនមានការបង្ក្រាបទេ គាត់មិនចាកចេញទៅជនបទទេ។ ដូច្នេះ គឺខ្ញុំបានសរសេរផ្នែកនេះ លោកដឹងហើយ។

[១៥:១៧:៣៨]

**សៈ** សូមលោកប្រាប់បន្ថែមទៀត គឺថាមានការទម្លាក់គ្រាប់បែក ហើយយើងបានដឹងតិចតួចពីអ្វីនៅភ្នំពេញ ប៉ុន្តែនៅខាងក្រៅនៅជនបទ ថាតើមានផលប៉ះពាល់ សូមរៀបរាប់ជម្រាបតុលាការមើល៍បានដែរឬទេ? ថា តើវាអាចមានស្ថានភាពដូចម្តេចចំពោះប្រជាជនសាមញ្ញកម្ពុជានៅតាមតំបន់ជនបទនោះ? បាទ ប្រសិនបើលោកបានសិក្សាលម្អិតពីករណីសម័យនោះ ក្នុងការសរសេរសៀវភៅនោះ?

**ឆៈ** នេះជាសំណួរដែលខ្ញុំមិនអាចឆ្លើយតាមអ្វីដែលខ្ញុំចង់ឆ្លើយឲ្យពិស្តារបានទេ។ ប៉ុន្តែនៅតាមព្រំដែន អង្កាល់នោះគឺថាមានការលំបាកណាស់ ដោយសារថាមានទាហានវៀតណាមនៅក្បែរហ្នឹង។ ទោះបីជាវៀតណាមគេប្រកាន់វិន័យល្អក៏ដោយទ័ពគេនោះ។ ប៉ុន្តែមានប្រហែលជានៅក្នុងខែកុម្ភៈ ឆ្នាំ១៩៦៨ ដែលថា គេចាប់ផ្តើម សង្គ្រាមចាប់ពីវៀតណាមខាងត្បូងមកហ្នឹង គឺថា ហើយពេលនោះគឺថាគេមិនបានទទួលស្គាល់ទេ ប៉ុន្តែគឺការចរចាការទូតនោះគឺត្រូវបានបរាជ័យ។ វៀតណាមខាងជើង គឺបានចូលមកដល់ព្រំដែន ហើយៗវៀតណាមខាងត្បូងក៏ចាប់ផ្តើមមានសង្គ្រាមច្រើនឆ្នាំកន្លងមកហើយ។ នេះជាហេតុការណ៍ដ៏លំបាក គឺថាការវាយប្រយុទ្ធកាន់តែធ្ងន់ធ្ងរទៅ ហើយសម្តេច សីហនុ ក៏មានបញ្ហាមិនច្បាស់លាស់ថា តើយកមូលដ្ឋាននយោបាយមួយណា។ ព្រះអង្គដូចមាន -- មិនមានស្ថិរភាពទេនៅក្នុងឆ្នាំ១៩៦៦ សភារបស់ព្រះអង្គហ្នឹងគឺថាបង្កើតឡើងដោយមនុស្សចាត់តាំងទេ គឺថាអ្នកដែលចាត់តាំងហ្នឹងមិនមែនជាមនុស្សរបស់ព្រះអង្គ។ ហើយព្រះអង្គមានការភ័យខ្លាច ហើយយើងមានឯកសារមួយចំនួនដែលបង្ហាញពីរឿងហ្នឹង។

[១៥:១៩:៣៣]

ហើយបញ្ហាហ្នឹងក៏បានកើតឡើង គឺថាវាមានការតស៊ូប្រឆាំងនឹងការគ្រប់គ្រងអំណាច គឺថាមាន

ការបះបោរ ហើយសេដ្ឋកិច្ចក៏មិនបានដំណើរការល្អនៅតាមជនបទ។ ហើយជនបទនោះ ប្រជាជនប្រឈមមុខនឹងសង្គ្រាមរុញឡើងរុញចុះ នេះហើយជាបញ្ហាស្មុគស្មាញ ប៉ុន្តែជាស្ថានភាពមិនល្អទេកាលនោះនោះ។

**ស៖** ហើយបញ្ហានោះបន្តឡើងក្នុងរយៈកាលមួយមកដល់ឆ្នាំ១៩៧០ មានរដ្ឋប្រហារ ប៉ុន្តែការទម្លាក់គ្រាប់បែកនៅតែបន្តរហូតមកដល់ពេលដែលលោកបានលើកឡើងព្រឹកមិញនេះ គឺបន្តមកដល់ឆ្នាំ១៩៧៣។ តើលោកបានដឹងទេនៅពេលនោះ តើការទម្លាក់គ្រាប់បែកមានផលប៉ះពាល់អ្វីនៅតាមតំបន់ជនបទនោះ? យើងនិយាយអំពីការប៉ះពាល់ដោយផ្ទាល់ជារូបវន្តទៅលើអ្នកភូមិ សត្វ ឬក៏គោ ក្របី ឬក៏ផលដំណាំជាដើម?

**ឆ៖** គឺថាខ្ញុំបានឆ្លើយសំណួរនេះច្រើនហើយ ព្រឹកមិញនេះ ខ្ញុំមិនបានសង្កេតមើលផ្ទាល់ទេ ព្រោះយើងផ្អែកទៅលើឯកសារ ដូចដែលមេធាវីខាងដើមនោះ គឺថាវាមានការអន្តរាយដ៏ធ្ងន់ធ្ងរ ហើយខ្ញុំយល់ថា អ៊ីចឹងខ្ញុំមិនដឹងថាវាមានអន្តរាយកម្រិតណា ធ្ងន់ធ្ងរកម្រិតណានោះទេ។ ហើយខ្ញុំបញ្ជាក់ថានៅក្នុងឆ្នាំ១៩៧០, ៧១, ៧២ ហ្នឹងគឺថាទម្លាក់គ្រាប់បែកតាមបណ្តោយផ្លូវលំហូជីមិញ ប៉ុន្តែពេលនោះគឺថាអាចប្តូរទៅទម្លាក់គ្រាប់បែកនៅតំបន់មួយចំនួន គឺថាគឺជាការទម្លាក់គ្រាប់បែកគឺនៅជុំវិញតំបន់មួយចំនួននៅភ្នំពេញនេះដែរ។ ខ្ញុំនិយាយថាវាមានការអន្តរាយ ប៉ុន្តែវាមានធ្ងន់ប៉ុនណា ខ្ញុំមិនអាចបញ្ជាក់បានទេ។ ខ្ញុំបានជជែកជាមួយអ្នកភូមិតែម្នាក់ពីរនាក់តែប៉ុណ្ណោះទេ។

[១៥:២១:៣៧]

**ស៖** ក្រៅពីផលប៉ះពាល់លើរូបវន្ត ឬការហិនហោចទ្រព្យសម្បត្តិនោះ គឺថាក្នុងឋានៈដែលលោកជាអ្នកប្រវត្តិវិទូ ហើយបានសម្ភាសមនុស្សមួយចំនួន តើលោកអាចប្រាប់តុលាការអំពីផលប៉ះពាល់លើផ្លូវចិត្ត ទៅលើអ្នកទាំងអស់នោះបានដែរឬទេ? ខ្ញុំមើលឃើញថាមានការជំទាស់ លោកសាស្ត្រាចារ្យ ឆេនដ័ល័រ សូមលោករង់ចាំបន្តិច។

**ប្រធានអង្គជំនុំ៖**

លោកសាស្ត្រាចារ្យកុំអាលទាន់ឆ្លើយតបទៅនឹងសំណួរ ពីព្រោះមានសេចក្តីជំទាស់ មានការជំទាស់ពីក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

បាទ សូមអញ្ជើញមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[១៥:២២:២៣]

**លោក អូលីវីយេ បាហ្ស៊ីញ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ទៅនឹងសំណួរដែលបានចោទសួរនេះ គឺពាក់ព័ន្ធទៅនឹង -- ដែលថាការជម្លៀសនេះ គឺមានបញ្ហាចិត្តសាស្ត្រ ហើយខ្ញុំបានយោងទៅយុត្តិសាស្ត្រកាលពីម្សិលមិញនេះ គឺបញ្ជាក់ថាលោក ឆេនដ៍ល័រ គាត់មិនមានសមត្ថភាពក្នុងការផ្តល់យោបល់ពាក់ព័ន្ធទៅនឹងបញ្ហាចិត្តសាស្ត្រនោះទេ។

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមអនុញ្ញាតឆ្លើយតប។ ហើយយើងនឹងចូលទៅដល់ចំណុចនោះនៅពេលមួយ ហើយខ្ញុំមិនសូមឲ្យមានការវិភាគខាងផ្លូវចិត្តសាស្ត្រនោះទេ។ ថាគាត់បានជួបជាមួយបុគ្គលម្នាក់ៗ ហើយអ្នកភូមិជាជនរងគ្រោះនោះបានរៀបរាប់ប្រាប់គាត់ថា តើផលប៉ះពាល់លើជីវិតរបស់ពួកអ្នកទាំងអស់នោះដូចម្តេច? នេះហើយជាខ្ញុំ -- ចំណុចដែលខ្ញុំចង់សួរ មិនមែន ខ្ញុំមិនឲ្យគាត់វិភាគទៅលើផលប៉ះពាល់លើផ្លូវចិត្តសតិបញ្ញា ក្រោយមកនោះទេ។ ហើយ នេះហើយជាសំណួរដែលខ្ញុំចង់បានចម្លើយ បើសិនជាលោកអ្នកជំនាញអាចឆ្លើយបាន។

[១៥:២៣:៣២]

**ប្រធានអង្គជំនុំ៖**

បាទ សូមអ្នកជំនាញអាចឆ្លើយតបនឹងសំណួរដែលសួរកែសម្រួលចុងក្រោយនេះ មិនមែនឆ្លើយនឹងសំណួរដែលបានតាំងសំណួរដំបូងទេ។

**លោកដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** ខ្ញុំអាចឆ្លើយនូវចម្លើយពីមុន ខ្ញុំមិនបាននិយាយជាក់ស្តែងពិស្តារទេ ប៉ុន្តែខ្ញុំអាចនិយាយថាផលប៉ះពាល់នោះគឺថាវាមានលក្ខណៈ *ខាសត្រូស្ត្រហ្វិក* គឺវាមានលក្ខណៈមហន្តរាយ។

**ស៖** នៅថ្ងៃទី២០ កក្កដា ឆ្នាំ២០១២ នៅទំព័រ៩៨ ជាសេចក្តីព្រាងប្រតិចារិករបស់តុលាការលោកបាននិយាយដូចខាងក្រោមនេះ៖ ខ្ញុំសូមអាន ខ្ញុំនឹងអានយឺតៗទេ។ ខ្ញុំនឹងផ្តល់ជូនឯកសារជាក្រដាស គឺថាមិនមានឧបសគ្គអ្វីទេ។ លោកបាននិយាយថា នៅទំព័រ -- នៅបន្ទាត់ទី១២ទំព័រ៩៨ ជាភាសាខ្មែរ៖ "ប្រជាជន គេទទួលដំណឹងថាការទម្លាក់គ្រាប់បែកនៅភ្នំពេញ ប្រជាជនមានភស្តុតាងជាច្រើនអំពីបញ្ហានេះ។ កងកម្លាំងដែលចូលមកភ្នំពេញខ្លះនៃអ្នកទាំងនោះដែលបានចូលមកពីបាត់ដំបង គឺមានការខឹងសម្បាខ្លាំងណាស់ គេប្រាប់ឲ្យអ្នកទាំងអស់នោះមានកំហឹង គេប្រាប់ថា នេះជាកន្លែងដែល

មិនជា អាមេរិកាំងប្រចាំប្រទេស ជាកន្លែងដែលត្រូវតែកម្ទេចនៅក្នុងទីក្រុងនោះ។ ដូច្នេះ ទីក្រុងគឺជាកន្លែងនៃប្រជាជនថ្មី ហើយជាកន្លែងតាមនិយមន័យ ដែលប្រជាជនមិនបានចូលរួមជាមួយបដិវត្តន៍ ហើយដែលធ្វើឲ្យខ្មែរក្រហមចាត់ទុកថា មិនមែនពួកខាងខ្មែរក្រហមទេ គឺពួកខាងខ្មាំង អ្នកនៅក្រុងនោះ”។ សំណួរ ខ្ញុំសួរទៅលោកនោះ គឺដូចខាងក្រោមនេះ៖

មនុស្សដែលទទួលការទម្លាក់គ្រាប់បែកនោះ ដែលរងការទម្លាក់គ្រាប់បែក គឺភូមិមួយចំនួនត្រូវបានបំផ្លាញ សត្វពាហនៈ និងកុមារ គឺថាត្រូវបានស្លាប់ ហើយនិងពិការ។ តើគេដឹងទេ លោកសិក្សាខាងប្រវត្តិសាស្ត្រ តើលោកបានដឹងទេ ការទម្លាក់គ្រាប់បែកនោះ ជាគ្រាប់បែករបស់សហរដ្ឋអាមេរិកនោះ?

**ឆ៖** ខ្ញុំមិនអាចឆ្លើយសំណួរនេះភ្លាមទេ។ បាទមែនហើយគឺ ខ្ញុំយល់ថា គឺកងកម្លាំងខ្មែរក្រហមអាចទាក់ទងអ្នកទាំងអស់ហ្នឹង ប្រាប់ទាំងអស់ហ្នឹងគឺថា គេប្រាប់ថា នេះជាគ្រាប់បែករបស់សហរដ្ឋអាមេរិក។

**ស៖** តើពួកគេដឹងដែរឬទេថា រដ្ឋាភិបាលរបស់កម្ពុជា ទាំងរបស់ សីហនុ ហើយទាំងរដ្ឋាភិបាល លន់ នល់ អនុញ្ញាតឲ្យរដ្ឋាភិបាលសហរដ្ឋអាមេរិក ទម្លាក់គ្រាប់បែកនៅតំបន់នោះដែរឬទេ? តែគេដឹងដែរឬទេ ផ្អែកតាមការសិក្សាប្រវត្តិសាស្ត្ររបស់លោកនោះ?

[១៥:២៦:២៨]

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំទាន់អាលឆ្លើយតបនឹងសំណួររបស់មេធាវីការពារក្ដីលោក អៀង សារី។ ចាំស្ដាប់អង្គជំនុំជម្រះសម្រេចលើសេចក្ដីជំទាស់ របស់តំណាងសហព្រះរាជអាជ្ញាជាមុនសិន។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមជំទាស់។ មូលហេតុនោះសាមញ្ញទេ គឺសំណួរនេះ គឺសុំចង់ឲ្យអ្នកជំនាញឆ្លើយសន្មតទៅលើហេតុការណ៍នេះ ដែលថា តំបន់ជនបទរបស់កម្ពុជានៅក្នុងឆ្នាំ១៩៧៣-៧៤ នោះគឺថា សំណួរនោះគប្បីសួរឡើងវិញ ថាតើមានព័ត៌មាន ឬក៏ថា ឯកសារអ្វីដែលកម្មាភិបាលបានឆ្លើយនោះ ដូចជាចំណុច ក, ខ, គ អ៊ីចឹង ទើបអាចសួរលម្អិតបែបនេះបាន។

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំនឹងរៀបសំណួរឡើងវិញបាទ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** លោកបានជម្រាបតុលាការថា ការទម្លាក់គ្រាប់បែកចាប់ផ្តើមនៅឆ្នាំ១៩៦៧ ហើយចាប់ផ្តើម ប្រហែលជាប្រាំមួយឆ្នាំ ហើយប្រជាជនអាចដឹងបានថាការទម្លាក់គ្រាប់បែក គឺធ្វើឡើងដោយសហរដ្ឋអាមេរិក។ តើលោកដឹងថា ក្នុងសម័យកាលហ្នឹងប្រជាជនកម្ពុជានៅក្រៅភ្នំពេញអាចបានដឹងទេថារដ្ឋាភិបាលរបស់កម្ពុជាក្រោមរបប លន់ នល់ និង សីហនុ គឺធ្វើការសហការជាមួយសហរដ្ឋអាមេរិក។ តើប្រជាជនគេដឹងអ៊ីចឹងទេ?

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** នេះជាបញ្ហា វិធីដែលគេអាចដឹង ថាតើនរណាខ្លះដឹង។ ប្រជាជននោះគឺបានដឹងថា -- ប៉ុន្តែអ្នកដែលមិនបានព័ត៌មានច្បាស់នោះ គឺគេអាចនឹងស្មាន។ នេះហើយគឺថា អាចជាការឃោសនា។ នេះជាឧបករណ៍ដ៏មានតម្លៃដែលខ្មែរក្រហមពន្យល់ថាៗ ហើយរដ្ឋាភិបាលនេះបានក្បត់ប្រជាជន ហើយឲ្យមានការទម្លាក់គ្រាប់បែក។ ខ្ញុំចង់បញ្ជាក់ឡើងវិញបន្តិច ដែលខ្ញុំមិនចង់ឲ្យកំណត់ត្រាតុលាការ កត់ថាការទម្លាក់គ្រាប់បែកនៅកម្ពុជានោះ គឺថា ជាការទម្លាក់គ្រាប់បែកគ្របដណ្តប់គ្រប់តំបន់មួយចំនួននោះគឺថាៗ អាចបន្តរហូតមកដល់ -- ពីឆ្នាំ១៩៦៧ គឺថាៗមិនបន្ត គឺថានៅខាងផ្លូវលំហូជីមិញនោះ គឺថាមានព្រៃឈើច្រើនណាស់ គឺថាបើនិយាយពីឆ្នាំ១៩៧៣ គឺក្រោយតែពីវៀតណាមបានដកការគាំទ្រពីខ្មែរក្រហមទៅហើយ ហើយបទឈប់បាញ់គ្នារវាងសហរដ្ឋអាមេរិកនិងវៀតណាមបានឈប់ហើយ។ ខ្មែរក្រហមបានកាន់ក្តាប់លើសង្គ្រាមស៊ីវិលជាងពាក់កណ្តាលទៅហើយ។ ឧបករណ៍តែមួយគឺសង្គ្រាមចិត្ត-សាស្ត្រដែលត្រូវបាន ត្រូវប្រាប់ ដែលកន្លែងណាដែលរងផលប៉ះពាល់ពីការទម្លាក់គ្រាប់បែកនោះ ដើម្បីឈ្នះខាងនយោបាយរបស់ខ្លួន។

[១៥:៣០:៥៧]

ហើយការពិតនោះ គឺវាមិនមែនពិតអ៊ីចឹងទេ គឺថា ដែលគេប្រាប់ថាយន្តហោះហ្នឹងចេញមកពីភ្នំពេញ ប៉ុន្តែតាមពិត គឺថាមិនដែលយកគ្រាប់បែកចេញពីភ្នំពេញទេ ប៉ុន្តែរដ្ឋាភិបាលគឺថា អនុញ្ញាតឲ្យ -- រដ្ឋាភិបាលទេ ដែលអនុញ្ញាតឲ្យយន្តហោះ ហោះមកចូលក្នុងស្រុកខ្មែរ។

**ស៖** ប៉ុន្តែយន្តហោះទម្លាក់គ្រាប់បែកហ្នឹង គឺមិនមែនចេញពីភ្នំពេញទេ ចេញពីហ្គ័ម ប៉ុន្តែតើរដ្ឋាភិបាលសម័យនោះ អនុញ្ញាតឲ្យមានការទម្លាក់គ្រាប់បែកនៅភូមិដែលស្លាប់ប្រជាជន គោក្របីរបស់គេទេ គេដឹងទេ? សូមលោកអាចឆ្លើយម្តងទៀត ដោយសារមីក្រូហ្វូនមិនទាន់បើកក្រហមទេអំមិញបាទ។

**ឆ៖** ខ្ញុំមិនឆ្លើយអ៊ីចឹងទេ ប៉ុន្តែវាជាតាក់ទិក ជាយុទ្ធសាស្ត្រមួយដែលថា ដែលគេពិបាកក្នុងការទទួលស្គាល់ណាស់ គឺថារដ្ឋាភិបាលជួយ ឬក៏អនុញ្ញាតឲ្យទម្លាក់គេ។ ដូច្នេះ គេជឿខ្មែរក្រហមជាង ដូច្នេះមួយផ្នែកគឺថា បរទេស ចំពោះថាតើប្រជាជនយល់ថារដ្ឋាភិបាលខ្លួនឯងធ្វើអ៊ីចឹងទេ។ ការដែលធ្វើបែបនោះ គឺថាអាចធ្វើឲ្យប្រជាជនមានកំហឹងគឺថា ដូចជា ផលប៉ះពាល់ដូចជាខ្យល់ព្យុះទីហ្វុងដែរ ប៉ុន្តែអ្នកដែលត្រូវខឹង គឺខឹងទៅអ្នកណានោះ។

[១៥:៣១:២៤]

**ស៖** ថាតើរដ្ឋាភិបាលអនុញ្ញាតឲ្យសហរដ្ឋអាមេរិកបំផ្លាញទីជនបទអ៊ីចឹង គឺថាដែលអ្នកដែលផ្តល់ព័ត៌មានខុសហ្នឹងជា គេប្រើជាឧបករណ៍។ អ៊ីចឹងហើយថាតើសហរដ្ឋអាមេរិក គប្បីតែដឹងពីរឿងហ្នឹងដែរឬទេ ដែលគេយកអង្គហេតុនេះទៅនិយាយប្រាប់ប្រជាជនមិនត្រឹមត្រូវបែបនេះនោះ?

**ឆ៖** នេះមិនមែនជាសំណួរនាំមុខទេ។ គឺថាលោកបាននាំឲ្យខ្ញុំឆ្លើយទៅដល់សំណួរដែលខ្ញុំបានឆ្លើយពីមុនហើយ។ ហើយខ្ញុំមិនចង់ទាញការចាប់អារម្មណ៍គឺថា វាជាការឈឺចាប់ដ៏មហន្តរាយមួយ ការទម្លាក់គ្រាប់បែកនេះ ខ្ញុំមិនអាចនិយាយអ្វីខុសពីហ្នឹងបាទទេ។

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅដល់ផ្នែកមួយទៀត អំពីការវិភាគពីផ្លូវចិត្តសាស្ត្រ។ សៀវភៅរបស់លោក នៅក្នុងសៀវភៅដែលមានចំណងជើងថា "បងទី១"។ ប្រហែលជាលោកអាចពន្យល់បន្ថែមពីឃ្លាមួយនៅក្នុងកន្លែងនេះ។ ខ្ញុំយោងទៅរកឯកសារ E3/17។ ខ្ញុំអាចជូនឯកសារលើក្រដាសទៅលោកនូវឯកសារនេះ លើកលែងតែលោកមានសៀវភៅនោះរួចទៅហើយ គឺជាសៀវភៅបោះពុម្ពកែតម្រូវ ទំព័រទី៩ ERN គឺ 00392923, អត្ថបទភាសាខ្មែរ 00821673 ហើយខ្ញុំមិនជឿថា ឯកសារនេះត្រូវបានបកប្រែជាភាសាបារាំងទេ។ សូមអភ័យទោស។

ខ្ញុំសូមដកស្រង់ឃ្លាមួយចំនួននៅក្នុងសៀវភៅនេះ៖ "យើងឃើញមាន ស មានការភ័យខ្លាចទៅនឹងវិន័យ និងមានការភ័យខ្លាចចំពោះវត្តអារាម"។ នេះគឺជាការវិភាគចិត្តសាស្ត្រទៅលើ ប៉ុល ពត។

[១៥:៣៤:០១]

**ឆ៖** ខ្ញុំថា គួរតែប្រើពាក្យថា "យល់" ជាជាងពាក្យ "វិភាគ"។

**ស៖** នៅពេលនេះ គឺថាលោក ខ្ញុំឲ្យលោកផ្តល់ជាចម្លើយទូទៅ ទំព័រទី១០ លេខ ERN ជាភាសាខ្មែរ 00821674, អង់គ្លេសគឺ 00392924។ លោកបាននិយាយថា "វាមានការងាយស្រួល ក្នុងការគិតថា សាឡុត ស នៅក្នុងឆ្នាំ១៩៣០ កំពុងតែធ្វើការពិនិត្យមើលទៅលើស្ថានភាព ហើយមានការបណ្តុះ

បណ្ដាលពីបងប្អូនជីដូនមួយរស់នៅជាមួយនឹងបងប្អូន ហើយកំពុងតែមើលទៅលើការសម្ដែងសិល្បៈរបស់មីងរបស់ខ្លួន"។ ខ្មែរ ERN គឺ 00821675 ទំព័រ១២, ជាភាសាអង់គ្លេស 00392926។ "វាពិបាកនឹងនិយាយ ថាតើរាជវាំងនោះ គឺវាធ្វើឱ្យ សាឡុត ស ហ៊្នឹង ចងចាំយ៉ាងម៉េច នៅពេលដែលខ្លួនកាន់អំណាចនោះឡើយ។ គាត់ប្រហែលជាគិតអំពីអ្នករាំរបាំ ឬក៏កសិករគាត់ដែលជួបនាពេលក្រោយ។ គាត់ប្រហែលគិតអំពីជីវិតកុមារភាពរបស់ខ្លួន ហើយនិងគិតអំពីទីក្រុងដែលមានភាពមិនសមរម្យចំពោះគាត់"។

ទំព័រ៥០ លេខ ERN ជាភាសាខ្មែរ 00821678, 00392929 ត្រង់ទំព័រលេខ១៥។ "អ្វីដែលសំខាន់ជាងនោះ គឺថាគ្រួសាររបស់គាត់ គឺមានជីវិតរស់នៅគេចផុតពីជីវិតក្រីក្រ ហើយមានជីវិតផ្លូវចិត្តល្អ ហើយវាធ្វើឱ្យអ្នកសង្កេតសង្កាមានការចាប់អារម្មណ៍ចំពោះជីវិតរបស់គាត់"។

ខ្មែរ ERN គឺ 00821682, ទំព័រ៩ ជាភាសាអង់គ្លេស 00392933។ "ដោយគិតអំពីការទទួលជោគជ័យរបស់ សាឡុត ស ក្នុងនាមជាគ្រូ វាជាការល្អដែលយើងត្រូវមើល វ៉ាន់ ស៊ីវន ដែលជាគំរូទីមួយដែល ប៉ុល ពត ពិនិត្យមើល និងចង់យកគំរូតាម"។

ខ្មែរ 00821688--

[១៥:៣៧:២៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំមិនចង់ក្រោកឈរនោះទេ នៅពេលនេះ គឺថាយើងមានការដកស្រង់សម្ដី។ ដូច្នេះធ្វើយ៉ាងណាឱ្យមានការរៀបចំឱ្យបានល្អប្រសើរជាងនេះ។ យើងឃើញថា មានការដកស្រង់សម្ដីពីរបីរួចមកហើយដូច្នេះហើយ គឺចង់ឱ្យលោកសាស្ត្រាចារ្យគាត់ចង់ធ្វើការផ្ដល់ចម្លើយឆ្លើយតបទៅនឹងការដកស្រង់សម្ដីទាំងអស់នោះ។ ដូច្នេះហើយ វាមានការពិបាកណាស់សម្រាប់លោកសាស្ត្រាចារ្យ ហើយមិនអាចជួយជ្រោមជ្រែងផ្ដល់ការពិតដល់អង្គជំនុំជម្រះនោះឡើយ។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធានជាទីគោរព! យើងឃើញថា អ្នកជំនាញសរសេរនូវអត្ថបទជាច្រើនដែលល្អៗហើយគាត់គឺជាប្រវត្តិវិទូ។ ការជំទាស់ចំពោះការវិភាគទៅលើផ្លូវចិត្ត យើងឃើញថាមានការលើកឡើង

ហើយខ្ញុំគ្រាន់តែចង់សួរអ្នកជំនាញ ថាតើនេះជាវិធីដែលប្រវត្តិរូប -- អ៉ំ! ប្រវត្តិវិទូបានសរសេរនៅក្នុងសៀវភៅរបស់ខ្លួន ឬក៏គាត់សរសេរក្នុងសៀវភៅជាលក្ខណៈសៀវភៅប្រលោមលោកតែប៉ុណ្ណោះ។ ខ្ញុំគ្រាន់តែចង់សួរគាត់អំពីទំនាក់ទំនងរវាងការរៀបរាប់ទៅលើប្រវត្តិសាស្ត្រ ជាមួយនឹងសៀវភៅ "បងធំទី១" នេះគឺជាគោលបំណងដែលយើងខ្ញុំចង់ចង្អុលយោងទៅលើការដកស្រង់សម្ដីមួយចំនួនចេញពីសៀវភៅរបស់លោកសាស្ត្រាចារ្យ ដេវីដ ឆេនដ៍ល័រ ជាពិសេសសៀវភៅ "បងធំទី១" នេះ។

[១៥:៣៩:០៣]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៣៩:៤៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន ហើយសូមលោកមេធាវីរៀបចំនឹងសំណួរជាក់លាក់ ដើម្បីសួរទៅដល់អ្នកជំនាញអំពីបញ្ហានេះ។

[១៥:៤០:០០]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** តាមរយៈឯកសារនេះ ដែលខ្ញុំទើបតែបានអានអម្បាញ់មិញនេះ។ ជាបឋមតើឯកភាពជាមួយខ្ញុំដែរឬទេ? ការដកស្រង់អម្បាញ់មិញនេះ គឺអាចឃើញមាននៅក្នុងសៀវភៅរបស់លោកតើមាន ឬក៏មិនមានអ្វីដែលខ្ញុំអានអម្បាញ់មិញនេះ? តើលោកចង់មើលដែរឬទេ?

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** ខ្ញុំដឹងថាមាន សរសេរនៅក្នុងសៀវភៅរបស់ខ្ញុំអ៊ីចឹងមែន។

**ស៖** ខ្ញុំគ្រាន់តែឲ្យយើងយល់ទាំងអស់គ្នា ថាយើងនឹងយល់អ៊ីចឹងជារួម ហើយខ្ញុំគិតថា លោកក៏ប្រហែលជាមានការទើសចិត្តបន្តិចដែរ ទៅលើអ្វីដែលខ្ញុំសួរនេះ។ បន្ទាប់មកលោកវិភាគទៅលើបញ្ហាចិត្ត ផ្លូវចិត្ត។ ដូច្នេះហើយនេះគឺជាការដែលលោកព្យាយាមវិភាគទៅលើប្រវត្តិសាស្ត្រ តាមរយៈការសរសេរជារឿងប្រជាប្រិយ ជាជាងការសរសេរប្រវត្តិសាស្ត្រ។

[១៥:៤១:០៤]

**ឆៈ** ខ្ញុំមិនចង់ឲ្យមានការឆ្លើយដាក់ និងនិយាយអ៊ីចឹងនោះទេ។ វាជាប្រវត្តិរូបរបស់បុគ្គលម្នាក់។ វាជាសៀវភៅប្រវត្តិរូប ប្រវត្តិរូបគឺមិនមែនយើងសរសេរអំពីកាលប្បវត្តិរបស់ ប៉ុល ពត ឬក៏សរសេរអំពីជីវប្រវត្តិរបស់បុគ្គល ប៉ុល ពត នេះពីដំណាក់កាលមួយ ដំណាក់កាលមួយនោះទេ។ ទោះបីយ៉ាងណាក៏ដោយ ខ្ញុំមិនចង់ធ្វើអ៊ីចឹង។ ក៏ប៉ុន្តែនៅក្នុងនេះ គឺៗយើងបានសរសេរអំពីឥទ្ធិពលពាក់ព័ន្ធទៅនឹងបុគ្គលរូបនេះ នៅពេលដែលគាត់ឆ្លងកាត់ និងជួបបុគ្គលមួយចំនួនដែលគាត់ធ្លាប់ជួប។ ខ្ញុំបាននិយាយជាមួយនឹង គ័ន ស៊ីផាន លោកគ្រូនៅទីនោះ ហើយគាត់បាននិយាយថា ហ៊ូ នឹម, ខៀវ សំផន បានរៀននៅទីនោះ។ ដូច្នេះហើយភស្តុតាងទាំងអស់នេះ គឺជាជំរុញមួយទៅដល់ សាឡុត ស និង ប៉ុល ពត (ស៊ីក)។ ហើយមុនពេលដែលគាត់ហ្នឹងក្លាយទៅជាគ្រូដូចដែលលោកបានលើកឡើង។

ចំណុទីពីរ វាជាចំណុចមួយរលូន ហើយស្អាតស្អំ គឺវាជាអ្វីដែលលោកយកគំរូ តាមថានៅពេលដែលអង្អែលស្បែកទៅ គឺថាឃើញទៅវាស្អាតស្អំ។ ដូច្នេះហើយនេះគឺអ្វីដែលខ្ញុំព្យាយាមនិយាយ សរសេរកើតចេញពីការធ្វើទំនាក់ទំនងនៅក្នុងគ្រួសាររបស់គាត់។

[១៥:៤២:២៨]

ដូច្នេះ នៅក្នុងសៀវភៅនេះ ខ្ញុំចង់ឲ្យមានការអ្នកអាននោះឲ្យយល់។ ក៏ប៉ុន្តែវាមិនមែនជាការធ្វើពិសោធន៍ទៅលើជីវប្រវត្តិរបស់បុគ្គលរូបនោះទេ។ ខ្ញុំមិនព្យាយាមសរសេរថា តើនៅក្នុងគំនិតរបស់បុគ្គលម្នាក់នោះយ៉ាងណានោះឡើយ។ ខ្ញុំមិនព្យាយាមស្វែង រុករកព័ត៌មានស៊ីជម្រៅទៅលើបុគ្គលនេះឡើយ។ ក៏ប៉ុន្តែជាការព្យាយាមបង្ហាញអ្វីដែលកើតចេញពីបុគ្គលនេះ ហើយអ្វីដែលពាក់ព័ន្ធទៅនឹងបុគ្គលនេះ។ យើងត្រូវតែធ្វើការទស្សន៍ទាយផងដែរទៅលើជីវិតរបស់បុគ្គលនេះមួយចំនួន ដូចដែលខ្ញុំបានសរសេរ។ ខ្ញុំគិតថា វាហាក់ដូចជាយើងប្រៀបធៀបនៅក្នុងបន្ទប់អ៊ីចឹង នៅពេលនេះថាគាត់កំពុងមើលខ្ញុំ ប៉ុន្តែខ្ញុំមើលអត់ឃើញគាត់នោះទេ។ ទោះបីយ៉ាងណាព័ត៌មាននេះ មិនមែនថាវាមិនពាក់ព័ន្ធនោះទេ។

**សៈ** ខ្ញុំសង្ឃឹមថា ខ្ញុំមិនមែនលើកឡើងថា ប្រវត្តិសាស្ត្រគួរតែប្រមូលព័ត៌មានឲ្យបានច្រើននោះទេ។ ក៏ប៉ុន្តែយើងសូមថ្លែងអំណរគុណចំពោះការសរសេរសៀវភៅរបស់លោកដែលល្អ។ ខ្ញុំសូមចូលទៅដល់អត្ថបទដកស្រង់មួយទៀតនៅក្នុងសៀវភៅរបស់លោក បន្ទាប់មកខ្ញុំប្តូរប្រធានបទ។

[១៥:៤៣:៣៧]

នៅក្នុងចំណុចមួយចំនួននោះ លោកហាក់ដូចជាសរសេរពាក្យទាយ ក្រោយពីអ្វីដែលលោកបានអាន។ លោកបាននិយាយអំពីសៀវភៅរបស់ ស្តាលីន ហើយលោកបានលើកឡើងថា៖ "វាទំនងថា

នៅត្រឹមឆ្នាំ១៩៥២ ស គាត់ទទួលគំនិតរបស់គាត់ចេញពីបក្សកុម្មុយនីស្តបារាំង"។ បន្ទាប់មកលោកសរសេរថា៖ "ស នោះគឺគាត់ក៏បានដឹង និងបានអានអំពីអត្ថបទ ស្តាលីន ដែលបានចែកផ្សព្វផ្សាយអំពីកុម្មុយនីស្តរបស់សូវៀតផងដែរ"។ បន្ទាប់មកលោកសរសេរទៀតថា៖ "វាជាការព្យាយាមបង្ហាញសាឡុត ស ដែលគាត់បានពិនិត្យមើលឯកសារជាច្រើន ហើយគាត់បានទាញយកទស្សនៈពិភពលោក ហើយធ្វើការពិនិត្យទៅលើទស្សនៈទាំងអស់នោះក្នុងលក្ខណៈរឹងប៊ឹងមួយ។ ក៏ប៉ុន្តែវាជាការយល់ច្រឡំមួយ ប្រសិនបើយើងគិតថាសកម្មភាពរបស់គាត់នោះ គឺវាស៊ីសង្វាក់ ហើយវាមានលក្ខណៈមហិច្ឆតា"។ ខ្ញុំអានចេញពីលេខ ERN ជាភាសាខ្មែរ 00821695, អង់គ្លេស 00392946 ទំព័រ៣២។

[១៥:៤៤:៥៨]

ខ្ញុំសួរថាតើអ្វីដែលលោកសរសេរនៅក្នុងនោះ គឺការស្មានរបស់លោក ឬក៏យ៉ាងម៉េច? ដោយយើងកុំទាន់អាលគិតអំពីឃ្លាដែលថា គាត់នុំងព្យាយាមធ្វើអីចេះអីចុះ។ ដូច្នេះអ្វីដែលលោកបានសរសេរនោះ ក្នុងនាមលោកជាប្រវត្តិវិទូ តើលោកបានធ្វើការសន្និដ្ឋានដែរឬទេនៅក្នុងសៀវភៅរបស់លោកការសរសេរដូច្នេះនេះ?

**ឆ៖** លោក -- យើងត្រូវតែលើកឡើងការគំនិតជំទាស់របស់លោកទៅលើចំណុចហ្នឹង ក៏ប៉ុន្តែអ្វីដែលខ្ញុំសរសេរ គឺក្រោយពីខ្ញុំបាននិយាយជាមួយនឹងបុគ្គលស្ថិតនៅក្នុងសមាជិកគណបក្សកុម្មុយនីស្តបារាំងនៅពេលនោះ។ បរិយាកាសនៅពេលនោះ គឺថាវាមានស្ថានភាពរបប ស្តាលីន ហើយរដ្ឋាភិបាលកុម្មុយនីស្តពេលនោះវាគ្របដណ្តប់ទៅលើស្ថានភាព។ ដូច្នេះ អ្វីដែលយើងព្យាយាមធ្វើនៅថ្ងៃនោះ គឺយើងព្យាយាមអានទៅលើឯកសារទាំងឡាយដែលពាក់ព័ន្ធទៅនឹងបញ្ហានេះ។ ហើយខ្ញុំក៏ត្រូវតែពិនិត្យមើលឯកសារទាំងអស់នេះដែរ។

[១៥:៤៦:១៤]

ប្រវត្តិរូបរបស់ ស្តាលីន ហើយនិងបញ្ហាបក្សកុម្មុយនីស្តនៅពេលនោះ ក៏ទាមទារឲ្យយើងពិនិត្យមើល ហើយយើងត្រូវការសិក្សាទៅលើអត្ថបទ។ ខ្ញុំសន្មតថា ប៉ុល ពត នោះក៏គាត់ធ្វើអ៊ីចឹងដែរ គឺគាត់មើលទៅលើឯកសារទាំងអស់នោះ ហើយដោយសារគាត់គឺជាសមាជិករបស់បក្សកុម្មុយនីស្តបារាំង។ យើងបានឃើញទៅលើឯកសារទាំងអស់នេះ នៅក្នុងឆ្នាំ១៩៨០ គឺខ្ញុំបានចូលទៅអគារមួយ ហើយខ្ញុំបានឃើញទៅលើស្ថានភាពទាំងអស់នេះ។ ហើយខ្ញុំបានមើល សិក្សាទៅលើឯកសារទាំងអស់នេះ។

**ស៖** សូមអរគុណលោកសាស្ត្រាចារ្យ ឆេនដ៍ល័រ។ នៅពេលដែលយើងនិយាយថា លោកបាន

សន្មតដូច្នេះ តាមអ្វីដែលខ្ញុំយល់ចម្លើយរបស់លោកនោះ គឺការងាររបស់លោកមួយផ្នែក គឺថាក្រោយពេលពិនិត្យមើលឯកសារមួយចំនួនហើយនោះ គឺត្រូវ លោកត្រូវធ្វើការសន្មតទៅតាមហេតុផលដែលត្រឹមត្រូវ។ តើលោកពិតជាបានធ្វើដូច្នេះដែរឬទេ? ហើយខ្ញុំសន្មត គិតដូច្នេះត្រឹមត្រូវដែរឬទេ?

[១៥:៤៧:២៨]

**ផ៖** បាទ ខ្ញុំពិតថា លោកសន្និដ្ឋានត្រឹមត្រូវហើយ។ លោកយល់ត្រឹមត្រូវហើយ។

**ស៖** ដូច្នេះ នៅពេលដែលយើងនិយាយទៅលើចំណុចនេះ នៅពេលដែលលោកធ្វើការសន្មតផ្អែកទៅលើភស្តុតាងដែលលោកមាន។ ខ្ញុំសូមសួរលោក តាមបទពិសោធន៍របស់លោកយ៉ាងហោចណាស់ប្រវត្តិវិទូ ពេលខ្លះទៅគឺសន្មតខុស គិតខុសផងដែរ ដោយសារតែពួកគេសន្និដ្ឋាន ឬក៏សន្មតច្រើនពេកផ្អែកទៅតាមព័ត៌មានដែលពួកគេមាន។

**ផ៖** នេះគឺជាចំណុចដែលបង្ហាញដូច្នេះមែន ជាការពិត។

**ស៖** ប្រធានបទមួយទៀតដែលខ្ញុំចង់ពិភាក្សាបន្តិចបន្តួចនោះ គឺតួលេខមួយចំនួនដែលលោកបានលើកឡើងនៅក្នុងសៀវភៅ។ ឧទាហរណ៍ថា ចំនួនមរណៈនៅក្នុងសៀវភៅរបស់លោកនោះ។ នៅពេលដែលខ្ញុំបានពិនិត្យមើលសៀវភៅមួយចំនួនដែលលោកបានបោះពុម្ពផ្សាយកាលពីអតីតកាល។ ខ្ញុំមិនមែនថា ជំហររបស់លោកមានការប្រែប្រួល និងផ្លាស់ប្តូរនោះទេ ក៏ប៉ុន្តែតួលេខរបស់លោកជាទូទៅវាមានការកែប្រែខុសគ្នាបន្តិចបន្តួចមកទល់បច្ចុប្បន្ន។ មុនពេលយើងចូលទៅពិនិត្យតួលេខពិតប្រាកដ តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេ? តើលោកទស្សន៍ទាយចំនួនអ្នកស្លាប់មុនថ្ងៃ១៧ មេសា ឆ្នាំ៧៥ នោះ តើលោកទស្សន៍ទាយចំនួនអ្នកស្លាប់ហ្នឹងមានចំនួនប៉ុន្មានដែរ មុនបែកភ្នំពេញនោះ? ដោយយើងគិតពិចារណាអំពីការទម្លាក់គ្រាប់បែករហូតមកដល់ឆ្នាំ៧៥? តើលោកមានតួលេខ លោកចាំទេតួលេខចំនួនអ្នកស្លាប់ប៉ុន្មានដែរ?

[១៥:៤៩:៣២]

**ផ៖** ប្រហែលជាកន្លះលាន ប៉ុន្តែវាមិនមែនផ្អែកតាមការស្រាវជ្រាវរបស់ខ្ញុំនោះទេ។ ចំនួនតួលេខនេះ វាចំនួនខ្ពស់ ក៏ប៉ុន្តែវាផ្អែកតាមការស្រាវជ្រាវរបស់ខ្ញុំ។

**ស៖** សូមអរគុណ។ តើនេះជាតួលេខតាមប្រជាសាស្ត្រ ឬក៏តួលេខតាមការសិក្សាប្រវត្តិវិទូ?

**ផ៖** វាជាតួលេខដែលខ្ញុំយកមកតាមអ្នកដែលសិក្សាទៅលើប្រជាសាស្ត្រ។

**ស៖** ប្រសិនបើលោកគិតថា ពីប្រជាវិទ្យាសាស្ត្រនោះ អ្នកសិក្សាចំនួនប្រជាជន តើលោកអាច

ផ្តល់ឈ្មោះបានឬទេ ពីអ្នកណាដែលតួលេខដែលលោកយកមកហ្នឹង?

**ឆ៖** ខ្ញុំមានការស្ទាក់ស្ទើរដោយសារតែភ្លើងវាមិនទាន់ចេញ។ គឺដោយបុគ្គលប៉ូឡូញ *ឡារ៉ែនស្គីផាទ្រិកអេវ៉រលីន* ដែលគាត់សរសេរអត្ថបទមួយ។ តួលេខ គឺមាននៅក្នុងសៀវភៅមួយ ឬក៏ពីរដែលគាត់បានសរសេរនោះ។

**សៈ** នៅពេលដែលមើលអត្ថបទរបស់គាត់នោះ តើលោកមានពិនិត្យមើលប្រភពដែលគេប្រើប្រាស់នៅក្នុងសៀវភៅនោះដែរឬទេ មុនពេលដែលគេយកមកកំណត់ជាតួលេខនោះ?

[១៥:៥០:៥៥]

**ឆ៖** ខ្ញុំមើលទៅលើចំណុចដែលគេដកស្រង់ចេញពីប្រភពដែរ ក៏ប៉ុន្តែខ្ញុំមិនអាចផ្ទៀងផ្ទាត់មើលបាននោះទេ។

**សៈ** តើលោកគោរពទៅលើបុគ្គលនេះ ជឿជាក់លើបុគ្គលនេះដោយសារតែគាត់ជាអ្នកល្បី ឬក៏ដោយសារគាត់បានចេញសៀវភៅផ្សព្វផ្សាយ ឬក៏លោកបានគ្រាន់តែឮថាបុគ្គលហ្នឹង គាត់សរសេរអំពីចំនួនប្រជាជនតែប៉ុណ្ណោះ។

**ឆ៖** កម្រិតលម្អិតនៅក្នុងហ្នឹង គឺថាដោយសារខ្ញុំជឿជាក់ទៅលើការអប់រំរបស់បុគ្គលរូបនោះ។

**សៈ** តើលោកគិតថាមានការវិភាគណាមួយដែលគេបានសរសេរដែលឬទេ? ហើយថាតើចំនួនមនុស្សស្លាប់ហ្នឹងមុនឆ្នាំ៧៥ហ្នឹង តើប៉ុន្មានទៅ តើលោកបានដឹងដែរឬទេ?

**ឆ៖** នៅក្នុងឆ្នាំ១៩៦២ គឺជាឆ្នាំដែលគេបង្ហាញថាចំនួនមានស្លាប់ប៉ុន្មាន ហើយគេបានយកតួលេខនៅក្នុងឆ្នាំមកធ្វើការប្រៀបធៀបទៅលើចំនួនដែលមនុស្សស្លាប់។ ដូច្នេះចំនួន៦លាន គឺចំនួនប្រជាជនដែលគេថា គិតវានៅឆ្នាំ១៩៦២។

[១៥:៥២:១០]

**សៈ** ថាតើចំនួនតួលេខនេះ គឺអ្នកដែលគេសិក្សាទៅលើចំនួនប្រជាជននោះ គឺគេយកមកគិតគូរដែរឬទេនៅក្នុងឆ្នាំ១៩៧០ ដល់៧៥ ថាចំនួននោះគឺជាចំនួនប្រជាជននៅក្នុងចន្លោះឆ្នាំហ្នឹង? នៅពេលដែលគេនិយាយអំពីចំនួនមនុស្សដែលស្លាប់រហូតទៅដល់កន្លះលាននោះក្នុងចន្លោះហ្នឹង?

**ឆ៖** គឺគេក៏អាចដកស្រង់ចេញពីសៀវភៅ *មេហ្គតស៊ី* ដែលជាជនជាតិបារាំង។ ខ្ញុំខានអានសៀវភៅហ្នឹងជាច្រើនឆ្នាំមកហើយ ក៏ប៉ុន្តែបុគ្គលរូបនេះ គឺបានសរសេរអំពីចំនួនតួលេខនេះផងដែរ។ ដូច្នេះហើយខ្ញុំក៏បានផ្អែកទៅលើឯកសារមួយនេះផងដែរ។

**ស៖** តើលោកបានមើលសៀវភៅរបស់បុគ្គលមួយនេះដែរឬទេ? បុគ្គលឈ្មោះអម្បាញ់មិញនេះ *ហ្វៃហ្វនដេម៉ាន* នេះ?

**ឆ៖** បាទ គឺ មេហ្គតស៊ី។

**ស៖** តើលោកបានមើលសៀវភៅនេះដែរឬទេ? តើលោកផ្អែកទៅលើបុគ្គលណាខ្លះដែលគេសរសេរអំពីចំនួនមរណៈនោះ?

**ឆ៖** ខ្ញុំមិនមានជំនាញខាងវិទ្យាសាស្ត្រនោះទេ។ ដូច្នេះហើយ ខ្ញុំត្រូវតែផ្អែកទៅលើអ្នកផ្សេង។

**លោក ម៉ែខល កាណាវាស៖**

ដូច្នេះហើយ ទើបខ្ញុំសួរចំណុចហ្នឹង។ នៅពេលដែលយើងមើលតារាង យើងមានជាភាសាខ្មែរផងដែរ។ ខ្ញុំសូមបញ្ជាក់ជូនអង្គជំនុំជម្រះសាលាដំបូងថា នៅពេលដែលយើងប្រៀបធៀបតារាងនេះ គឺយើងមានប្រភពព័ត៌ជាច្រើនដែលមិនមាននៅក្នុងសំណុំរឿង ទោះបីជាសរសេរដោយលោក ដេវីដ ឆេនដ៍ល័រ ក៏ដោយ។ យើងមិនព្យាយាមដាក់ឯកសារនោះទេ ក៏ប៉ុន្តែដើម្បីជាគោលបំណងនៃការជំនុំជម្រះនេះ គឺយើងនឹងបង្ហាញអំពីជំហរខុសៗគ្នារបស់លោក ដេវីដ ឆេនដ៍ល័រ នៅក្នុងពេលជាច្រើនផ្សេងៗគ្នា។

[១៥:៥៤:២៦]

ដោយសារតែឯកសារនេះ វាមានច្រើន យើងខ្ញុំមិនជំទាស់ក្នុងការផ្តល់ឯកសារនេះជាក្រដាសទៅដល់លោក ដេវីដ ឆេនដ៍ល័រ ឲ្យគាត់ពិនិត្យមើលនោះទេ។ បន្ទាប់មកយើងនឹងអាចសួរទៅកាន់លោក ដេវីដ ឆេនដ៍ល័រ នៅព្រឹកថ្ងៃស្អែកបាន។ ហើយវាជាការល្អ និងងាយស្រួលសម្រាប់លោក ដេវីដ ឆេនដ៍ល័រ ឲ្យគាត់មើលជាមុនទៅ។ ដូច្នេះ វាជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ ជាការសម្រេចទៅលើបញ្ហានេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១៥:៥៤:៥៥]

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំក្រោកឈរដើម្បី -- ប្រសិនបើឯកសារនេះផ្តល់ជូនទៅដល់លោកសាស្ត្រាចារ្យ គួរតែផ្តល់ដល់អង្គជំនុំជម្រះនិងភាគីទាំងអស់ផងដែរ។ ហើយយើងគួរតែយោងទៅលើឯកសារដើម ដែលដកស្រង់តួ

លេខនេះ។ ខ្ញុំគ្មានការជំទាស់ទេ ប្រសិនបើផ្តល់ឯកសារ ហើយការផ្តល់ឯកសារអាចធ្វើឡើងក្នុងករណីគោរពតាមលក្ខខណ្ឌ ដូចដែលខ្ញុំបានលើកឡើងអម្បាញ់មិញនេះ។

**លោក ម៉ៃខល កាណាវាស៖**

ជាការពិតយើងខ្ញុំអាចផ្តល់បាន។ ភាគីទាំងអស់អាចទទួលបានឯកសារនេះ ខ្ញុំសូមអធ្យាស្រ័យដែលយើងខ្ញុំមិនបានចែកឯកសារនេះជាក្រដាសជូនដល់អស់លោក លោកស្រីទាំងអស់គ្នា។

លោកប្រធានយើងខ្ញុំផ្តល់ឯកសារជាក្រដាសជូនបាន ហើយខ្ញុំភ្លេចឯកសារជាបារាំងទៅហើយ យើងមានឯកសារជាបារាំង ហើយយើងមានមេធាវីបារាំងធ្វើការងារជាមួយយើងខ្ញុំផងដែរ។ យើងខ្ញុំនឹងផ្តល់ជូនឯកសារជាភាសាបារាំងបាន។ អ្វីដែលយើងអាចធ្វើបាន យើងនឹងមើលឯកសារនេះឡើងវិញនៅថ្ងៃស្អែកហើយយើងខ្ញុំនឹងផ្តល់ព័ត៌មានពាក់ព័ន្ធនឹងប្រភពឯកសារនេះ នៅមុនពេលដែលយើងបញ្ចប់នូវការងាររបស់យើង។ ដូច្នេះហើយយើងខ្ញុំសូមបន្តការសួរលើឯកសារនេះនៅព្រឹកស្អែកសម្រាប់ឲ្យយើង -- ដើម្បីឲ្យយើងមានភាពងាយស្រួល។ សូមអរគុណ។

[១៥:៥៦:២៦]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីអាចបញ្ជាក់អំពីអត្តសញ្ញាណនៃឯកសារដែលលោកមាន ប៉ុនប៉ងក្នុងការដាក់មកដេញដោលនៅមុខអង្គជំនុំជម្រះនេះដែរឬទេ? ហើយឯកសារនោះលោកបានបង្ហាញអំពីការដាក់ស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅពេលណា? ហើយបាន -- អង្គជំនុំជម្រះបានសម្រេចហើយឬនៅលើបញ្ហាឯកសារដែលលោកប៉ុនប៉ងជូនទៅលោកសាស្ត្រាចារ្យ និងអង្គជំនុំជម្រះ និងភាគី ក្នុងបំណងដេញដោលនៅព្រឹកថ្ងៃស្អែកនេះ? សូមលោកបង្ហាញពីបញ្ហានេះ ដើម្បីអង្គជំនុំជម្រះមានមូលដ្ឋានក្នុងការពិចារណាសម្រេចទៅលើឯកសារ ដែលត្រូវដាក់ពិភាក្សាដេញដោលតាមនីតិវិធីនៃវិធានជាធរមាន ដែលអនុវត្តនៅ អ.វ.ត.ក នេះ។

[១៥:៥៧:២១]

**លោក ម៉ៃខល កាណាវាស៖**

ជាបឋម ខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់លាស់ ប្រហែលជាខ្ញុំមិនបានបង្ហាញជំហររបស់យើងខ្ញុំឲ្យបានច្បាស់លាស់។ យើងបានមើលឯកសារផ្សេងៗគ្នាមួយចំនួននៅក្នុងសំណុំរឿង មួយចំនួនមិនមាននៅក្នុងសំណុំរឿងនោះទេ ដែលបង្កើតឡើងសរសេរឡើងដោយលោក ដេវីដ ឆេនដ៍ល័រ។ ហើយចេញពី

ឯកសារទាំងអស់នេះហើយ យើងបានរកឃើញឯកសារតារាងមួយ ដែលវាបង្ហាញភស្តុតាងជូនអស់លោកលោកស្រី។ ឯកសារនេះ ដែលយើងយោងអម្បាញ់មិញនេះ គឺ ERN វាមានលេខ ERN ក៏ប៉ុន្តែមិនមាននៅក្នុងសំណុំរឿងនោះទេ គឺឯកសារ ស្តីពីប្រឈមនឹងអតីតកាលប្រទេសកម្ពុជា លេខ ERN ភាសាអង់គ្លេស 00822745, 00822754។ បន្ទាប់មកអត្ថបទដកស្រង់ចេញពីសៀវភៅ "សោកនាដកម្មនៃប្រវត្តិសាស្ត្រកម្ពុជា" គឺបោះពុម្ពផ្សាយឆ្នាំ៩៣ យើងមានមានលេខ ERN ជាភាសាបារាំង, ERN ជាភាសាអង់គ្លេស 00193077, បារាំងគឺ 00824486។

[១៥:៥៩:០៣]

ជាថ្មីម្តងទៀត ឯកសារដដែលនៅក្នុងឯកសារដដែលនេះ នៅត្រង់សេចក្តីផ្តើម លេខ ERN 00 193084, បន្ទាប់មកនៅទំព័រ២៣៦, 00193319, បន្ទាប់មកទំព័រ២៧១ 00193354។ នេះគឺឯកសារដកស្រង់ចេញពីសៀវភៅលោក ដេវីដ ឆេនដ៍ល័រ សៀវភៅចំណងជើងថា "សោកនាដកម្មនៃប្រវត្តិសាស្ត្រប្រទេសកម្ពុជា នយោបាយ សង្គ្រាម"។ សៀវភៅនេះបោះពុម្ពឆ្នាំ១៩៩៣ និង៩៤។ ហេតុផលដែលថាឯកសារនេះមិនមាន -- ឯកសារដែលមិនមាននៅក្នុងសំណុំរឿងគឺ សៀវភៅ *អេដវើថាយ* ផ្សាយផ្សាយនៅក្នុងទស្សនាវដ្តីឆ្នាំ៩៤ យើងមានជាភាសាទាំងបី ខ្មែរគឺ 00828094, អង់គ្លេស 00813915, បារាំង 00823369។ សៀវភៅអម្បាញ់មិញមានចំណងជើងថា "បណ្តាំខ្មែរក្រហម"។ ហើយសៀវភៅមួយទៀតគឺ D108/98/2 បោះពុម្ពឆ្នាំ១៩៩៩ ខ្មែរ ERN 00191825, អង់គ្លេស 00192672, បារាំង 00357259។

[១៦:០១:១៩]

បន្ទាប់មកសៀវភៅ ស្តីអំពី "បងធំទី១" បោះពុម្ពផ្សាយឆ្នាំ៩២ ទំព័រពាក់ព័ន្ធខ្មែរ ERN 00821668, អង់គ្លេស 00818412។ សៀវភៅចំណង "បងធំទី១" ដដែលឯកសារបោះពុម្ពឆ្នាំ៩៩ ERN អង់គ្លេស 00392918។ អត្ថបទ មានអត្ថបទមួយទៀតផងដែរ ដែលថា "*អេទីក* នៅក្នុង *អ៊ីនធឺណាស្យូណាល់អាហ្វែរ*" អត្ថបទសរសេរឡើងដោយបណ្ឌិត ឆេនដ៍ល័រ ថាតើនឹងមានការជំនុំជម្រះសម្រាប់ខ្មែរដែរឬទេ? វាមានមិនមែនជា ឯកសារនៅក្នុងសំណុំរឿងនោះឡើយ។ ក៏ប៉ុន្តែឯកសារនេះមានដូច្នេះបុគ្គលរាល់គ្នា ឬក៏ភាគីនីមួយៗអាចមើលឯកសារនេះបាន ទំព័រខ្មែរ ERN--

**ប្រធានអង្គជំនុំ៖**

លោក១មេធាវី ហាក់ដូចជាមានភាពច្របូកច្របល់មួយ យើងជាប្រធានអង្គជំនុំជម្រះហ្នឹង ក្តាប់

មិនទាន់ទេ។ យើងបានសួរលោកថា តើឯកសារដែលលោកប៉ុនប៉ងដាក់ជូនទៅអ្នកជំនាញ ដេវីដ ឆេនដ៏ល័រ ហើយនិងចម្លងជូនដល់អង្គជំនុំជម្រះនិងភាគី ដែលបំណងដាក់សួរដេញដោល អ្នកជំនាញនៅថ្ងៃស្អែកនេះ តើជាប្រភេទឯកសារដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះហើយឬនៅ? ហើយការរៀបរាប់របស់លោក មានពីរចំណុចដែលមិនច្បាស់។

[១៦:០៣:៣០]

ទីមួយ គឺលោកបានបង្ហាញមានការចូលគ្នារវាងឯកសារ ដែលបានបង្ហាញមានលក្ខណៈថា មាននៅក្នុងសំណុំរឿងហើយ ហើយនិងឯកសារមួយទៀតដែលគ្មាននៅសំណុំរឿង។ បញ្ហាទីពីរ គឺឯកសារដែលលេខ ERN ដែលបញ្ជាក់មិនបានច្បាស់លាស់ថា តើឯកសារលេខ ERN ដែលលោកហៅហ្នឹងជាភាសាខ្មែរ ឬក៏ភាសាអង់គ្លេស ឬក៏ជាភាសាបារាំង។ ដើម្បីឲ្យបានច្បាស់លាស់ ពីព្រោះបញ្ហានេះត្រូវគោរពនូវអ្វីដែលជាអនុស្សរណៈ អង្គជំនុំជម្រះបានណែនាំភាគីរួចហើយ អំពីការអនុវត្តនូវការដាក់ឯកសារដេញដោលចំពោះមុខអង្គជំនុំជម្រះ ប្រសិនបើជាឯកសារថ្មីត្រូវគោរពតាមវិធាន៨៧ អនុវិធាន ៤ គឺធ្វើសំណើសុំមកអង្គជំនុំជម្រះ ដើម្បីអង្គជំនុំជម្រះសម្រេចលើសំណើសុំនោះថាតើដោយគោរពតាមវិធាន៨៧(៣) ថាតើដាក់ឲ្យដេញដោល ឬក៏អត់។

បញ្ហាបញ្ហាផ្សេងទៀត ដែលលោកគិតថា មាននៅក្នុងសំណុំរឿងគួរតែបញ្ជាក់ផងដែរ ថានៅក្នុងបញ្ជីឯកសារភាគីណាមួយ ដែលបានដាក់រួចហើយនៅចំពោះមុខអង្គជំនុំជម្រះ។

[១៦:០៤:៤៥]

នេះគឺកុំឲ្យវាមានការយឺតពេល បើពុំដូច្នេះទេ គឺយើងឃើញការរៀបរាប់នេះយ៉ាងវែងរវាង -- ឡូកឡំគ្នារវាងឯកសារដែលលោកបញ្ជាក់ថា មិនមាននៅក្នុងសំណុំរឿង ហើយនិងឯកសារមាននៅក្នុងសំណុំរឿង។ គួរតែលោករៀបចំបញ្ជីនេះឲ្យបានច្បាស់លាស់ ហើយនិងបង្ហាញឲ្យបានច្បាស់លាស់ដើម្បីចំណាយពេលវេលាខ្លី ដើម្បីមានប្រយោជន៍នៅក្នុងការអង្គជំនុំជម្រះជាចុងក្រោយនៅថ្ងៃនេះ អំពីសំណើសុំរបស់លោក អំពីការពិនិត្យឯកសារ ក្នុងបំណងសម្រេចដាក់ដេញដោលចំពោះអ្នកជំនាញរូបនេះ នៅព្រឹកថ្ងៃស្អែក។

បាទ សូមលោកស្រី ស៊ីលវៀ ខាតវ៉ាយថ៍ បើមិនមានចំណុចណាមានការមិនច្បាស់លាស់ សូមលោកស្រីអាចបញ្ជាក់បន្ថែមទៀតលើបញ្ហានេះ ដើម្បីឲ្យការចំណាយពេលវេលាលើកឡើងអំពីឯកសារមេធាវីរូបនេះ បានជាក់ច្បាស់ ហើយនិងមានប្រយោជន៍នៅក្នុងឲ្យអង្គជំនុំជម្រះពិចារណា

សម្រេចនាពេលខាងមុខនេះ ហើយនិងមានប្រយោជន៍សម្រាប់ពិភាក្សាដេញដោលនៅព្រឹកថ្ងៃស្អែក។

[១៦:០៥:៥៣]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ លោក កាណាវាស លោកបានអានបញ្ជីឯកសារហ្នឹងវែងណាស់។ មុននឹងចូល លោកអាចប្រើឯកសារនេះ ថ្ងៃស្អែកបាន អង្គជំនុំជម្រះត្រូវតែដឹង ថាតើឯកសារទាំងអស់នោះ នៅក្នុងសំណុំរឿងដែរឬអត់ ហើយថាតើបានដាក់មកដេញដោល ឬមិនដេញដោលនោះ។ ដោយហេតុថា ដូចលោកបានជ្រាបហើយ អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចបន្តបន្ទាប់។ ប្រសិនបើមិនបានដាក់ចំពោះមុខអង្គជំនុំជម្រះទេ គឺថាវិធាន៨៧(៤) ត្រូវស្នើសុំជាលាយលក្ខណ៍អក្សរ ដើម្បីដាក់ឯកសារថ្មី។

អង្គជំនុំជម្រះសូមៗកាត់សំណើដ៏វែងបែបនេះ ដើម្បីឲ្យយើងថា រកចំណុចឯកសារណាមួយដែលអាចប្រើដោយសមស្រប តាមផ្លូវច្បាប់ ដើម្បីសួរទៅសាក្សី។ ហើយខ្ញុំគិតថា លោកប្រធានចង់ព័ត៌មានឲ្យច្បាស់ មុនពេលដែលលោកចាប់ផ្តើមព្រឹកស្អែក។ បន្ទាប់នោះ លោកអាចយល់ហើយថាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះនោះ លើឯកសារណាដែលមិនទាន់បានដាក់ពីមុន។ ដូច្នេះហើយយើងត្រូវគោរពទៅតាមសំណើ តាមវិធាន៨៧(៤) ទៅតាមការងារឯកសារប្រចាំថ្ងៃ។ លោកស្នើមួយថ្ងៃម្តងៗ មិនអាចទៅរួចទេ។

[១៦:០៧:២០]

**លោក ម៉ៃខល កាណាវាស៖**

សូមលោកស្រីចៅក្រមបំភ្លឺ គឺថាយើងនឹងកែសម្រួលតារាងឯកសាររបស់យើងខ្ញុំ ដើម្បីឆ្លើយតបទៅនឹងការណែនាំរបស់លោក លោកស្រីចៅក្រម។ ដោយសន្មតថា ឯកសារនោះមិនដាក់នៅក្នុងសំណុំរឿង ថាតើយើងអាចប្រើ អាចសួរសំណួរទៅលោកសាស្ត្រាចារ្យបាន មិនបានទេ ទៅលើឯកសារផ្សេងជាពិសេស ដែលលោកចៅក្រមបានចុចហើយ។ ចំណុចមួយ, ពីរ ដូចថា ១.៣លាន ឬក៏ មួយប្រាំលាននាក់។ គឺទាក់ទងនឹងមនុស្សស្លាប់នេះ តើយើងខ្ញុំទទួលបានការអនុញ្ញាតឲ្យសួរបែបនេះដែរឬទេ នៅក្នុងឯកសារផ្សេងទៀតនោះ? ប្រសិនបើលោកអ្នកជំនាញនឹងផ្តល់សក្ខីកម្មនូវអ្វីដែលគាត់បានសរសេរនៅក្នុងនោះ គឺថាយើងអាចកំណត់មូលដ្ឋានដែលទាក់ទងទៅនឹងតួលេខនៅក្នុងប្រជាសាស្ត្រ ដែលគាត់បានធ្វើការសន្និដ្ឋានពីចំនួនមនុស្សស្លាប់ ឬក៏ចំនួនប្រជាជនក្នុងឆ្នាំណានោះ។

ដោយហេតុថា គាត់បានប្រើលេខ តួលេខខុសៗគ្នា នៅក្នុងឱកាសផ្សេងៗគ្នា ដើម្បីសួរ ដើម្បីឱ្យគាត់បានឱកាសឆ្លើយពន្យល់។ ប៉ុន្តែនេះជាសំណើ លោកចៅក្រមអាចសម្រេចទៅតាមឆន្ទានុសិទ្ធិ។

[១៦:០៨:៣៥]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

គឺថាអង្គជំនុំជម្រះបានសម្រេចពីខាងដើមហើយ លោកអាចប្រើឯកសារដែលមិនបានដាក់ចំពោះអង្គជំនុំជម្រះ ជាមធ្យោបាយ ឬក៏ជាមូលដ្ឋាននៃការសួរសំណួរទៅអ្នកជំនាញ។ ប៉ុន្តែលោកមិនបាច់កំណត់អត្តសញ្ញាណឯកសារទេ។ បើមិនអ៊ីចឹងទេ យើងត្រូវនឹងមើលវិធី ដើម្បីបញ្ជាក់យថាភាពឡើងវិញ ដើម្បីពិនិត្យមើលទៅលើបញ្ហាទាំងអស់នោះ ដើម្បីហើយយើងត្រូវជូនដំណឹងទៅភាគីទៀត។ ដូច្នេះ លោកអាចប្រើជាមូលដ្ឋានសម្រាប់សួរសំណួរ។ គឺមិនប្រើលើសពីហ្នឹងទេ។ ហើយខ្ញុំមិនកម្រិតដំណឹង នេះជាស្ថានភាពមួយ ដែលថាយើងត្រូវធ្វើការជាមួយឯកសារដ៏ធំធេង ហើយច្រើន ដែលយើងកំពុងប្រជុំ។ ហើយភាគី ក៏ប្រឈមមុខនឹងឯកសារច្រើននេះដែរ។

[១៦:០៩:២៧]

អ្វីដែលយើងចង់បាន គឺថាសូមឱ្យលោកឱ្យបញ្ជីខ្លីថ្ងៃនេះ ជាជាងចំណាយពេលច្រើនមុនពេលយើងសួរលោកសាក្សីនៅថ្ងៃស្អែកនោះ។ សូមអរគុណ។

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំយល់ពីបញ្ហានេះ ប៉ុន្តែវាយឺតបន្តិចសម្រាប់ខ្ញុំ។ តាមការសម្រេចរបស់លោកស្រីចៅក្រមនេះ ខ្ញុំនឹងកែ ព្យាយាម ប៉ុន្តែតាមអនុភាពនៃការសម្រេចនេះ គឺថាយើងនឹងពិនិត្យកែសម្រួលឡើងវិញ។ ចំណុចមួយខ្ញុំចង់បំភ្លឺ គឺថាដើម្បីភាគីច្បាស់ ហើយនិងសាស្ត្រាចារ្យ ឆេនដ័ល័រ ដើម្បីកុំឱ្យយើងដាក់អ្វីនឹងចូល។ តើខ្ញុំសូមអនុញ្ញាតដើម្បីឱ្យជូនឯកសារក្រដាស ដើម្បីជូនលោកជំនាញ ដើម្បីគាត់បានអាន ដើម្បីគាត់មើលថា នេះជាតួលេខដែលគាត់បានយកមកសរសេរ។ នេះក៏អាចដោះស្រាយបានដែរ។ សូមតុលាការជ្រាប។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

អត់អាចធ្វើបែបនេះបានទេ លោកត្រូវតែធ្វើសំណើដើម្បីដាក់ឯកសារនេះចំពោះមុខអង្គជំនុំជម្រះដើម្បីឱ្យយកឯកសារនេះ ហើយលោកផ្តល់ជាទឡ្ហីករណ៍ អះអាងគាំទ្រនៅពេលក្រោយ។

សូមអរគុណ។

[១៦:១០:៥២]

**លោក អាប់ឌុលឡាក់ ថារីក៖**

ហើយការយោងទៅរកការដាក់បញ្ចូលឯកសារនេះ យើងពិនិត្យមើលឯកសារមួយចំនួន មេធាវីនេះបានលើកសំណើ E172/24/3 យោងទៅរកអ្វីដែលយើងអាចបាន គឺថាឯកសារពីរ គឺជាសំណើដែលត្រូវធ្វើឡើងតាមវិធាន៨៧(៤)។ នេះជាឯកសារ E174/ -- 172/243 គឺថា E -- ឯកសារ E324 គឺថាមិនទាក់ទងទៅនឹងឯកសារដែលយោងនេះទេ ហើយខ្ញុំដើម្បីជាអត្ថប្រយោជន៍ដល់ភាគីទាំងអស់នោះ បាទ។

[១៦:១១:១៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:១៥:២៩]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយដែរ ប៉ុន្តែដោយសារមានបញ្ហាលើកឡើងដោយមេធាវីអន្តរជាតិការពារក្តីលោក អៀង សារី អំពីឯកសារពាក់ព័ន្ធនឹងឯកសារមួយចំនួនដែលខ្លួនមានបំណងដាក់សួរដេញដោលចំពោះអ្នកជំនាញនៅព្រឹកថ្ងៃស្អែក ដោយសារការយឺតយ៉ាវក្នុងការបង្ហាញអំពីបញ្ជីឯកសារ និងភាពពាក់ព័ន្ធនឹងបញ្ហាផ្សេងៗទៀតដែលបង្ហាញក្នុងការដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះនេះ។ ដូច្នេះអង្គជំនុំជម្រះសម្រេចថា បញ្ហានេះសូមឲ្យលោកមេធាវីការពារក្តីលោក អៀង សារី រៀបចំនៅបញ្ជីឯកសារដែលលោកមានបំណងដាក់ពិភាក្សាដេញដោលចំពោះអ្នកជំនាញនេះផ្តល់ជូនមកអង្គជំនុំជម្រះតាមរយៈក្រឡាបញ្ជីសវនាការនៅព្រឹកថ្ងៃស្អែក ឲ្យបានមុនពេលដំណើរការពិភាក្សាដេញដោល។

សូមអរគុណលោកសាស្ត្រាចារ្យ។ ឥឡូវនេះឃើញថា ពេលវេលាអស់ច្រើនហើយរហូតដល់ម៉ោងបួនដប់ប្រាំនាទីហើយ។ អង្គជំនុំជម្រះថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកសាស្ត្រាចារ្យដែលបានខិតខំប្រឹងប្រែង ហើយឆ្លើយនឹងសំណួរជាច្រើនក្នុងរយៈពេលកន្លងមកនេះ ហើយជាពិសេសថ្ងៃនេះដែលពេលវេលាឃើញថា មានការយឺត ១៥នាទី។ ហើយកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះគឺដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ៍ ទី២៤ ខែកក្កដា ឆ្នាំ២០១២ ដោយចាប់ផ្តែក

ពីវេលាម៉ោងប្រាំបួនព្រឹក ហើយសវនាការនៅថ្ងៃស្អែកនេះនឹងចាប់បន្តធ្វើ ដោយការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ ដេវីដ ឆេនដ៍ល័រ ដោយក្រុមមេធាវីការពារក្តីលោក អៀង សារី ហើយសូមភាគី និងសាធារណជនជ្រាប។

[១៦:១៧:២៤]

ហើយលោកសាស្ត្រាចារ្យ ដេវីដ ឆេនដ៍ល័រ ការស្តាប់សក្ខីកម្មរបស់លោកអ្នកជំនាញមិនទាន់ចប់នៅឡើយទេ។ សវនាការនឹងបន្តធ្វើនៅថ្ងៃស្អែកទៀត ដូច្នេះអង្គជំនុំជម្រះសូមអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មទៀត។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ក្នុងការបញ្ជូនអ្នកជំនាញវិលត្រឡប់ទៅទីកន្លែងដែលគាត់ស្នាក់នៅ និងឲ្យអញ្ជើញគាត់ត្រឡប់មកកានកន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែក ដែលនៅវេលាម៉ោងប្រាំបួន។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់សាលសវនាការនេះវិញនៅព្រឹកថ្ងៃស្អែក ថ្ងៃអង្គារ ទី២៤ ខែកក្កដា ឆ្នាំ២០១២ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:១៨ នាទី)*